ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Oct-2016, 15:22
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅជំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤៣៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

កញ្ញា ស្តាវរូឡា រ៉ាបាឌូពូលូស
*(Ms Stavoroula Rapadopoulos)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

កញ្ញា សុង ឆវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លឺវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក ហង់រី ឡូកា (2-TCE-90) | អង់គ្លេស, បារាំង |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ហង់រី ឡូកា** (2-TCE-90)


សួរបន្តដោយលោក ពេជ អង្គ ផ្តើមពី....................................................................... ទំព័រ ៣

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................................................................... ទំព័រ ៩

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី................................................................. ទំព័រ ៥១

# កិច្ចដំណើរការនីតិវិធី

[០៩:០១:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ហង់រី ឡូកា។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ៊ាង លើករាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និង បុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ អ្នកជំនាញដែលត្រូវមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក ហង់រី ឡូកា លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០២:១៥]

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ជា ស៊ីវហ៊ាង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់តវ៉ាទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះខ្លាំង ពិសេសពេលអង្គុយយូរ វិលមុខ ពេលមានការបំលាស់ប្ដូរស្ថានភាព និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ គឺពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៤:០៨]

មុននឹងផ្ដល់វេទិកាជូនទៅភាគីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ អង្គជំនុំជម្រះចេញសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់របស់មេធាវីការពារក្ដី នួន ជា អនុលោមតាមវិធាន៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ មេធាវីការពារក្ដី នួន ជា បានស្នើសុំឲ្យទទួលជាឯកសារភស្តុតាងនូវមាតិកានៃនិក្ខេបបទបណ្ឌិតរបស់អ្នកជំនាញ ហង់រី ឡូកា ដែលមានចំណងជើងថា "ទស្សនៈវិស័យនៃការសម្លាប់រង្គាល និងមនោគមន៍វិជ្ជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩" ដែលមានលេខ ERN 01307958 រហូតដល់ 01307961 និងអត្ថបទមួយទៀត ដែលគាត់បាននិពន្ធមានចំណងថា "ចរិតលក្ខណៈនៃការកៀបសង្កត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" ដែលមានលេខ ERN 01307962 រហូតដល់ 01307971។ លោក ហង់រី ឡូកា បានផ្ដល់ឯក-សារទាំងពីរនេះមកឲ្យអង្គជំនុំជម្រះ ហើយត្រូវបានដាក់ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅថ្ងៃទី២៦ ខែ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

កក្កដា ឆ្នាំ២០១៦។

អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់របស់ភាគីនានាលើសំណើនេះ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ហើយភាគីផ្សេងៗទៀតមិនបានជំទាស់ចំពោះសំណើសុំនេះទេ។ អង្គជំនុំជម្រះកត់សម្គាល់ពីលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣) និង៨(៤) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចតាមសំណើសុំរបស់មេធាវីការពារក្តី នួន ជា។

មាតិកានៃនិក្ខេបបទបណ្ឌិតរបស់លោក ហង់រី ឡូកា ដាក់លេខសម្គាល់ E3/10641 ហើយអត្ថបទដែលនិពន្ធឡើងដោយលោក ហង់រី ឡូកា នោះ នឹងដាក់លេខសម្គាល់ E3/10642។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសួរបញ្ចប់ចំពោះអ្នកជំនាញ តាមកាលវិភាគសម្រាប់ផ្តល់ឲ្យខ្លួន។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរដល់លោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនទៀតសម្រាប់សួរនៅពេលនេះដល់លោក។ សំណួររបស់ខ្ញុំជាដំបូងពេលនេះ គឺចង់សួរថា -- ដោយសារលោកបានសិក្សាអំពីសន្តិសុខនានាដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ខ្ញុំចង់ដឹងថាមន្ទីរសន្តិសុខដែលបង្កើតឡើងនៅក្នុងសម័យ៧៥ដល់៧៩នោះ ថាតើគេរៀបចំយ៉ាងដូចម្តេច? គេរៀបចំតាមថ្នាក់ស្រុក ថ្នាក់ខេត្ត ឬក៏ថ្នាក់ឃុំ ឲ្យមានមន្ទីរសន្តិសុខហ្នឹង?

[០៩:០៨:០៥]

**លោក ហង់រី ឡូកា៖**

**ឆ៖** ដូចដែលខ្ញុំបានពន្យល់នៅក្នុងឯកសារជាច្រើន ដែលខ្ញុំបានបោះពុម្ពផ្សាយនោះ <> ហើយខ្ញុំក៏បានអាន<ដោយខ្លួនឯង គឺប្រព័ន្ធ>គុក<> គឺថាមានទីតាំងនៅតាមស្រុក។ ស្រុកគឺអាចជាផ្នែករដ្ឋបាលមួយដ៏សំខាន់របស់របបកម្ពុជាប្រជាធិបតេយ្យ ក្នុងនោះរួមមានទាំងសហករណ៍នៅតាមថ្នាក់ឃុំ ដែលរបបនោះ គឺថាចង់ឲ្យសហករណ៍នេះកាន់តែធំទៅៗ ដោយដាក់បញ្ចូនភូមិជាច្រើន ដើម្បីរាប់ទៅជាសហករណ៍នីមួយៗ។ ហើយដូចដែលបានបង្ហាញជូនចំពោះមុខតុលាការកាលពីសប្តាហ៍មុនហើយ ហើយឯក

សារជាច្រើនបង្ហាញជូនមកខ្ញុំពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់។ យើងដឹងហើយថា វាជាកាតព្វកិច្ចរបស់ <មន្ត្រី>បីនាក់ដែលត្រូវចាត់ចែងការងារ<សហករណ៍> ហើយដែលត្រូវកំណត់ មុខសញ្ញាខ្មាំង។ អ្នកជនរងគ្រោះទាំងនោះ ត្រូវចាប់បានចាប់ខ្លួនដោយឈ្លប ហើយគេយកទៅកាន់កន្លែងឈ្លបនៅកម្រិតសហករណ៍នីមួយៗ។ ហើយយោងតាមការសួរចម្លើយ គឺថាអ្នកខ្លះអាចត្រូវបានគេដោះលែងឲ្យរួចខ្លួនដែរ ក៏ប៉ុន្តែភាគច្រើននោះ គេបញ្ជូនទៅដាក់នៅគុកថ្នាក់ស្រុក ពីព្រោះថាគុកនេះ គឺថាជាមិនមានអ្វីឲ្យសង្ស័យទេ គឺថាជាស្ថាប័នរដ្ឋបាលមួយដ៏សំខាន់នៅថ្នាក់ស្រុក។

[០៩:០៩:៥៧]

**ស៖** ការបង្កើតមជ្ឈមណ្ឌលសន្តិសុខនេះ ថាតើវាអាចជាការបង្កើតដែលចេញពីសេចក្តីសម្រេចថ្នាក់ណា?

**ឆ៖** ពិបាកនឹងឆ្លើយបន្តិច លោកចង់សួរត្រឹមកម្រិតណា។ នៅចំពោះមុខតុលាការយើងនេះ រយៈពេល៨ឆ្នាំកន្លងមកហើយនេះ បានរកឃើញភស្តុតាងកាន់តែច្រើនឡើងៗ ដែលថាមន្ទីរសន្តិសុខមានភារកិច្ចមួយចម្បងណាស់ សម្រាប់រដ្ឋបដិវត្តន៍នាពេលនោះ ឬក៏ថារដ្ឋដែលដឹកនាំដោយបក្សនាពេលនោះ។ ហេតុដូច្នេះ សេចក្តីណែនាំនានា គឺថាចេញពីថ្នាក់កំពូល ដោយបញ្ជាទៅតាមស្ថាប័ននានានៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យអង្គភាពទាំងអស់នោះ កំណត់មុខសញ្ញាខ្មាំងប្រឆាំងនឹងបដិវត្តន៍។ ជាការពិតហើយនេះជាគំនិតផ្តួចផ្តើមរបស់មជ្ឈិម ហើយបញ្ជាចុះទៅក្រោម គឺទៅភូមិភាគ ទៅតំបន់ ទៅស្រុក និងទៅសហករណ៍។

**ស៖** នៅក្នុងដំណើរការនៃមជ្ឈមណ្ឌលសន្តិសុខទាំងអស់នេះ ថាតើ សំណួររបស់ខ្ញុំថាតើវាមានទំនាក់ទំនងជាមួយថ្នាក់លើដែរឬទេ? ដំណើរការនៃមជ្ឈមណ្ឌលសន្តិសុខទាំងអស់នេះ អាចមានទំនាក់ទំនងជាមួយនឹងថ្នាក់លើដែរឬទេ?

**ឆ៖** បាទ ដូចដែលយើងបានឃើញហើយ ចំពោះករណីស្រុកត្រាំកក់ ខ្ញុំគិតថាសិទ្ធិៗក្នុងការកម្ទេចខ្មាំងគឺថាត្រូវបានផ្ទេរអំណាចនេះប្រគល់សិទ្ធិអំណាចនេះពីមជ្ឈិម។ បាទ ដូចខ្ញុំបានពន្យល់វែងឆ្ងាយមកហើយ គឺថាដំបូងបញ្ជាពីមជ្ឈិមនេះចុះទៅភូមិភាគ ហើយមិនដឹងថាតើ ភូមិភាគដើរតួនាទីសំខាន់យ៉ាងណា -- ទៅតំបន់ (បាទ សូមទោស) ហើយបន្ទាប់មកបានចុះពីតំបន់ទៅស្រុក ហើយនៅថ្នាក់ស្រុកនេះសោតទៀត សេចក្តីសម្រេចក្នុងការសម្លាប់ ឬក៏ដោះលែង ឬក៏បញ្ជូនទៅមន្ទីរអប់រំកែប្រែ គឺគេធ្វើឡើងសម្រេចនៅថ្នាក់ស្រុកនេះ។ យើង ដូចបានឃើញហើយ គឺថាមានសេចក្តីសម្រេចនានានៅ

សល់ នៅឯគុកក្រាំងតាចាន់។

**ស៖** បុគ្គលដែលគេបញ្ជូនទៅមន្ទីរសន្តិសុខ ឬក៏អាចនិយាយថាជាអ្នកទោស។ តើពួកគាត់ជាមនុស្សប្រភេទណាដែលត្រូវបានគេយកគាត់យកទៅមន្ទីរសន្តិសុខទាំងនោះ?

[០៩:១៣:៤៤]

**ឆ៖** បាទ ដូចដែលខ្ញុំបានលើកឡើងម្ដងហើយម្ដងទៀត នៅក្នុងដំណើរការសវនាការដ៏វែងឆ្ងាយនេះ ហើយអ្វីដែលខ្ញុំបានរកឃើញតាំងពីដើមឆ្នាំ១៩៨៩ នៅពេលដែលខ្ញុំជួប មឿង សុន ហើយនិងប្រពន្ធរបស់គាត់ឈ្មោះ ផល្លី នៅលីយ៉ុង។ មឿង សុន នេះគឺថាដូចដែលខ្ញុំបានពន្យល់ហើយ គឺថា<នៅ>ក្នុងសៀវភៅ<របស់គាត់> និងកំណត់ត្រាចងចាំរបស់គាត់ ហើយខ្ញុំពន្យល់នៅក្នុងសំណេររបស់ខ្ញុំ ហើយខ្ញុំក៏បានផ្ដល់សក្ខីកម្មជូនអង្គជំនុំជម្រះរួចមកហើយ នៅពេលគាត់<បានទៅ>ដល់តានៃ<នៅពេលយប់ហើយព្រឹកឡើង>គាត់ក្រឡេកមើលជុំវិញខ្លួន <ពេលនោះគាត់ជាប់>ខ្នោះ ហើយគាត់ស្គាល់កម្មាភិបាលដែលមកពីកំពង់សោម ពីក្រុងព្រះសីហនុ ហើយគាត់ក៏ចំណាំបានអតីតសង្ឃ។ <និយាយម្យ៉ាងទៀត> ដូចដែលខ្ញុំបានប្រើ<នៅក្នុង>ពាក្យ<ស្លោករបស់ខ្ញុំ>ថា ជាជន*អេលីត*មួយកាលពីអតីតកាលហ្នឹង គឺថាអ្នកដែលមានកម្រិតជីវភាពខ្ពស់។ <បដិវត្តន៍កុម្មុយនីស្ដទំនងជាផ្លាស់ប្ដូរពួកអេលីត សម្លាប់> កម្ទេចអ្នកទាំងអស់នេះ ឬក៏<>និរទេសខ្លួន ឬក៏<ចាប់ដាក់គុក ឬក៏ធ្វើអ្វីក៏ដោយទៅលើពួកវរជនចាស់ៗនោះហើយជំនួសដោយវរជនថ្មីៗវិញ។> នេះគឺជាស្ថានភាពនៅក្នុងឆ្នាំ១៩៧៥ និង៧៦។ នេះករណីរបស់មឿង សុន។ ហើយនៅពេលដែលគាត់<>ត្រូវបានចាប់ខ្លួនជាលើកទី២នៅចុងបញ្ចប់នៃឆ្នាំ៧៧ នៅកោះខ្យង គឺថាគាត់មានការភ្ញាក់ផ្អើលមែនទែន ដែលគាត់បានឃើញនៅជុំវិញខ្លួនគាត់ហ្នឹង គឺ<>មានកម្មាភិបាលខ្មែរក្រហម<មួយចំនួនតូច> រួមទាំង<មនុស្ស>ដែលគាត់ធ្លាប់បានជួបនៅឯគុកតានៃ មានកងទ័ពហើយក្រៅពីនោះ អាចជាប្រជាជនថ្មី ឬជាប្រជាជនចាស់ ឬអាចនិយាយម្យ៉ាងទៀតបានថា គឺ<>មាន<គ្រប់>វណ្ណៈ<>សង្គម<ទាំងអស់ ហើយជាពិសេស គឺភាគរយសំខាន់>គឺ<>ខ្មែរក្រហមខ្លួនឯង<>។ អ៊ីចឹងសម្រាប់ខ្ញុំ គឺថាការបោសសម្អាតផ្ទៃក្នុងនេះ គឺៗហាក់បីដូចជាវាហួសពីការអាចនឹងគ្រប់គ្រងត្រួតពិនិត្យបានហើយ ពីព្រោះថ្នាក់ខាងលើ ឬក៏អង្គការខាងលើនេះ បានមានការសម្រេចហើយ វាសង្ស័យកាន់តែច្រើនឡើងៗចំពោះខ្មាំងជួរបក្ស ហើយក៏បានចាប់គេយកមកដាក់នៅតាមគុកនានាៗ<តាំងពី>ស-២១ និងគុកនៅតាមបណ្ដាស្រុកនានាផងដែរ។

[០៩:១៦:៤៧]

**ស៖** លោកបានមានប្រសាសន៍អម្បាញ់មិញ មនុស្សដែលជាប់សង្ស័យ ត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខ។ ហេតុអី ហេតុអ្វីបានជាមនុស្សដែលជាប់ការសង្ស័យហ្នឹង ទៅជាកម្មវត្ថុនៃការបញ្ជូនទៅមន្ទីរសន្តិសុខទាំងនោះ?

**ឆ៖** វាជារឿងមួយឆ្ងល់ដែរ <ហេតុអ្វីបានជាមនុស្សភាគច្រើនមិនត្រូវបានគេសម្លាប់។ វាហាក់ដូចជាចំណាយពេលឥតប្រយោជន៍ កម្លាំងជាច្រើន ថាមពល និង>ធនធាននានាសម្រាប់របបនោះដែល<រំខានដោយ>ពាក្យថា "មហាលោតផ្លោះ <មហាអស្ចារ្យ>"នោះ គឺថាធ្វើម៉េចឲ្យប្រទេសហ្នឹងមានភាព<សម្បូរសប្បាយរុងរឿងឆាប់រហ័សលឿនជាង>ប្រទេសដទៃទៀតនៅក្នុងពិភពលោក។ <ហេតុផលគឺថា លក្ខណៈបុគ្គលឯកជនលែងមានទៀតហើយហៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។> បុគ្គលម្នាក់ៗ ដូចដែលខ្ញុំបានពន្យល់នៅជំពូកចុងក្រោយ ស្តីអំពីការចងក្រងសុភាសិតរបស់ខ្ញុំនេះ គឺថាត្រូវតែរួមរស់ជាសមូហភាព អ្វីៗទាំងអស់ត្រូវតែជាសមូហភាព។ បុគ្គលម្នាក់នេះ គ្រាន់តែជាផ្នែកមួយតូចនៃម៉ាស៊ីនមួយទេ។ ម៉ាស៊ីននេះ គឺអង្គការនេះឯង។ ហេតុដូច្នេះ នៅពេលដែលគេសង្ស័យទៅលើជនណាម្នាក់ ឬក៏ថាអ្នកណាម្នាក់មិនពេញចិត្តនឹងរបប ឬព្យាយាមរត់គេចចេញពីរបបនោះ ឬក៏ធ្វើអ្វីមួយដែលខុសច្បាប់ <យោងទៅតាម>សីលធម៌<បដិវត្តន៍> គេ<មិន>អាចធ្វើ<សកម្មភាព>តែម្នាក់ឯងបាន<ទេ>។ សេចក្តីសម្រេចរបស់បុគ្គលម្នាក់ៗ អាចមិនត្រូវបានគេឮបាននោះទេ។ <ដូច្នេះហើយ គេចាំបាច់ត្រូវចូលរួមក្នុងគម្រោងការក្បត់ប្រឆាំងនឹងបដិវត្តន៍។> ដូច្នេះមុននឹងគេសម្លាប់បុគ្គលនោះ គឺថាទី១ បុគ្គលនោះត្រូវសារភាព បុគ្គលនោះត្រូវឆ្លើយដាក់ឈ្មោះដែលជាខ្សែបណ្តាញរបស់ខ្លួន។ <>នេះ គឺ<ជា>ដំណើរការ<>នៅស-២១។ <ដំណើរការដូចគ្នានេះដែរ>នៅតាម<ថ្នាក់>ស្រុក<>។ ដូច្នេះការសម្លាប់<មនុស្សក្រៅច្បាប់> គឺ<ជាការបាត់បង់ព័ត៌មានសំខាន់សម្រាប់>សន្តិសុខ <សុវត្ថិភាពរបស់បដិវត្តន៍>។

[០៩:១៩:៣៣]

**ស៖** លោកប្រហែលជាបានសិក្សាអំពីស្ថានភាពនៃអ្នកទោសនៅក្នុងមន្ទីរសន្តិសុខផ្សេងៗ។ ម្សិលមិញ លោកបានមានប្រសាសន៍អំពីរបបអាហារដែលពួកគាត់ទទួល ហើយក៏ខ្ញុំចង់សួរបញ្ជាក់អំពីការរស់នៅរបស់ពួកគាត់នៅក្នុងមន្ទីរសន្តិសុខ។ លោកអាចពិពណ៌នាបានទេ គាត់រស់នៅរបៀបយ៉ាងដូចម្តេច នៅក្នុងមន្ទីរសន្តិសុខនោះ?

**ឆ៖** បាទ និយាយឲ្យទូលំទូលាយបន្តិច <សម្រាប់ខ្ញុំ ក្រោយពីបានស្តាប់ព័ត៌មាន>លម្អិត

<អំពី>ស-២១ គឺថាស្ថានភាពនៃការរស់នៅ នៅក្នុងគុកតាមបណ្តា<>ខេត្តនានា អាក្រក់ជាងស-២១ ទៅទៀត។ ជាទូទៅ គឺថាអ្នកទោសហ្នឹង មិនត្រូវបានគេឲ្យងូតទឹកទេ។ <ជាការពិត វាពិបាកខ្លាំងណាស់ចំពោះការនិយាយជាសរុបអំពីកម្ពុជាប្រជាធិបតេយ្យ> ដូចខ្ញុំបានបន្តជម្រាប រៀបរាប់ជាហូរហែហើយ គឺថាវាមានភាព<ច្របូកច្របល់>មែនទែន។ គុកខ្លះ គឺថា<ត្រូវបានគេ>រៀបចំតាមរបៀបគេផ្សេង <ហើយគុកផ្សេងទៀតធ្វើខុសៗគ្នា។ ដូច្នេះ លោកបានដឹងបានឃើញហើយ ពេលខ្លះអ្នកទោស>ជាក់លាក់មួយចំនួននៅតាមបណ្តា<គុក>ស្រុកនានា គឺថាត្រូវបានគេអនុញ្ញាតឲ្យងូតទឹកស្ទឹង ទឹកអូរជាដើម <ទោះបីជាការងូតទឹកនោះបានតិចតួចក្តី> ប៉ុន្តែនិយាយសរុបជារួមនោះ គឺថាគេមិនអនុញ្ញាតឲ្យងូតទឹកទេ។ ហើយនៅស-២១នេះ គឺថាគេបាញ់ទឹក<ដាក់>អ្នកទោសហ្នឹងតែម្តង <ដូច្នេះយ៉ាងហោចណាស់ក៏គេបានងូតទឹកបន្តិចបន្តួចដែរ>។ <ធូលី និងភាពកខ្វក់ រួមទាំង>សត្វល្អិតអីផ្សេងនោះ គឺថា<ជាសុបិន>អាក្រក់មែនទែន <សម្រាប់អ្នកទោសទាំងអស់>នៅ<គុក>តាមបណ្តាខេត្តនានា<>។ ចំពោះចំណីអាហារវិញ<គឺសាមញ្ញបំផុត។ នៅពេញទូទាំងប្រទេសកម្ពុជាមានរបបអាហារដូចគ្នា> គឺថាហូបបបរាវៗមួយថ្ងៃបានរបបអាហារតែពីរដងទេ <> ហើយបានតិចតួចមែនទែន ហើយការដែលហូបរបបដ៏តិចតួចបែបនេះ <>តែ<>បី<បួន>សប្តាហ៍ទៅ អ្នកទោសលែងរស់ទៅកើតហើយ គឺថានឹងស្លាប់ហើយ។ <ដូច្នេះ នោះគឺជាការបង្អត់អាហារតែម្តង។>

ប៉ុន្តែវា គុកតាមបណ្តាខេត្តទាំងនេះ មិនអាក្រក់ដូច ស-២១ ទេ បើគិតពីរបបអាហារនេះ។ អ្នកទោសខ្លះអាចរស់បានរហូតទៅដល់បួន ប្រាំ ប្រាំមួយខែ ក៏ថាបានជាមួយនឹងរបបអាហារបែបនេះ។ អ៊ីចឹង <ខ្ញុំគិតថា ឌុច បាននិយាយថា -- ខ្ញុំគិតថា>នៅស-២១ របបអាហារនេះ គឺថា<មានលក្ខណៈត្រឹមត្រូវជាងគេបន្តិច>។ អ៊ីចឹង <តាមភស្តុតាងរបស់ខ្ញុំ តាមការស្រាវជ្រាវរបស់ខ្ញុំ> ខ្ញុំអាចសរុបមកវិញថា ស្ថានភាពរស់នៅ <ជាការពិតណាស់ គឺអត់មានពេទ្យព្យាបាលអ្វីទាំងអស់>នៅគ្រប់គុកទាំងអស់។ ដូច្នេះ ស្ថានភាពរស់នៅគឺថា គុកនៅតាមបណ្តាខេត្តនានា តាមមូលដ្ឋាននេះ គឺថាអាក្រក់ជាងស-២១ ទៅទៀត។

[០៩:២២:៣៩]

**ស៖** ខ្ញុំនៅមានសំណួរបន្តិចបន្តួចទេ។ ចង់សួរបន្ថែមអំពីការសម្រាក ការស្នាក់អាស្រ័យនៅតាមបណ្តាមន្ទីរឃុំឃាំងទាំងអស់នោះ ថាតើមានមុង មានភួយ មានគ្រែអីទេ ហើយលោកមានបានដឹងថា មានមន្ទីរសន្តិសុខណាមួយដែលផ្តល់សម្ភារៈទាំងអស់នេះ បែបនេះ ទៅដល់អ្នកជាប់គុកនោះដែរទេ?

**ឆ៖** មិនមានផ្តល់អ្វីទាល់តែសោះ ជាទូទៅអ្នកទោសដេកនៅលើឥដ្ឋការ៉ូ ដេកនៅផ្ទាល់នឹងដី ដូចករណីនៅគុកតានៃ គឺគុកដែល មឿង សុន គាត់បានជាប់នោះ។ គឺគុកនេះគេសាងសង់ឡើង -- គេធ្វើដូចជាខ្ទមអ៊ីចឹង គឺមិនមានមុង មិនមានភួយ ហើយអ្នកទោសទាំងអស់នេះត្រូវបានសត្វល្អិតខាំ ហើយ<ជាពិសេស ពួកគេបែកញើស ហើយ>កខ្វក់ផង។ អ្នកទោសរស់នៅ គឺថាដោយមិនមានអនាម័យអ្វីទាល់តែសោះ ហើយក៏សូមបញ្ជាក់ផងដែរថា ពាក់ព័ន្ធទៅនឹងការបត់ជើងនោះ គឺថាគេមិនឲ្យចេញទៅបត់ជើងឯណាទេ គឺគាត់បត់ជើង<ដាក់កំប៉ុង ឬធុង ហើយហុចបន្តគ្នា>។

**ស៖** ចុះចំពោះការព្យាបាលវិញ ថាតើមានការរៀបចំសម្រាប់ពួកគាត់ទេ?

**ឆ៖** ដូចដែលខ្ញុំបានឆ្លើយហើយ មិនមានឧទាហរណ៍ណាមួយថា មានការផ្តល់ព្យាបាលផ្នែកវេជ្ជសាស្ត្រទៅដល់អ្នកទោសនៅតាមបណ្តាខេត្តនានានោះទេ អ្នកទោសហ្នឹង គឺត្រូវគេឃុំឃាំងក្នុងរយៈពេលខ្លីជាងនៅស-២១។ ដូចខ្ញុំបានសរសេរហើយ គឺថាជាមធ្យមគេឃុំឃាំងប្រហែលជាបីសប្តាហ៍ទេ។ ហើយរបបអាហារនេះ គឺបបរនេះឯង គឺរាវកក្លូកតែម្តង។ គឺថាអ្នកទោសអាចរស់រានមានជីវិតបានតែបីបួនសប្តាហ៍ទៅមួយខែតែប៉ុណ្ណោះ ពាក់ព័ន្ធនឹងរបបអាហារប៉ុណ្ណេះ។ ហើយជាទូទៅគឺថា អ្នកទោសគឺស្លាប់<នៅពេលយប់>ដោយសារការអត់ឃ្លាននេះ ហើយដោយមានដៃជើងជាប់ខ្នោះតែម្តង ហើយព្រឹកឡើងបានខាងកម្មាភិបាលហ្នឹងគេមកដើរប្រមូលខ្មោចទាំងនោះ។

[០៩:២៥:៣៨]

**ស៖** បាទ សំណួរចុងក្រោយរបស់ខ្ញុំ អ្នកទោសដែលបានបញ្ជូនចូលមកក្នុងមន្ទីរសន្តិសុខតាមរយៈការសិក្សានិងវិភាគរបស់លោក លោកអាចប៉ាន់ប្រមាណបានទេ ថាពួកគាត់ស្លាប់ប៉ុន្មានភាគរយទៅលើចំនួនសរុបដែលបញ្ជូនចូលក្នុងមន្ទីរសន្តិសុខផ្សេងៗនោះ?

**ឆ៖** ចំនួនភាគរយអ្នកដែលបានស្លាប់ទៅគឺថា <>អាចស្លាប់ក្នុងរបៀបបី។ ទី១ <ស្លាប់>ដោយការអត់ឃ្លាន <ស្លាប់>ដោយដៃជើងជាប់ខ្នោះ។ ការស្លាប់ទី២ គឺស្លាប់ដោយការសួរចម្លើយ។ យើងមានឧទាហរណ៍ដូចជា អតីតអ្នកសួរចម្លើយដែលបានឆ្លើយថា បុគ្គលនេះ អ្នកទោសរូបនេះស្លាប់ដោយសារ តែគេវាយដំខ្លាំងពេក គេធ្វើទារុណកម្មខ្លាំងពេក ទើបអ្នកទោសទាំងនោះស្លាប់។ ហើយលោកក៏ប្រហែលជាចាំផងដែរ គឺថា ឌុច បាននិយាយថា អ្នកទោសគឺថា គាត់មិនអនុញ្ញាតឲ្យគេធ្វើទារុណកម្ម អ្នកទោសទៅដល់ស្លាប់នោះទេ។ ចំណុចនេះ មិនមែនដោយសារបញ្ហាមនុស្សជាតិ មនុស្សធម៌ទេ គឺបញ្ហាខ្លាចបាត់ព័ត៌មាន។ ហើយការស្លាប់ទី៣ <> គឺគេសម្លាប់នៅពេលយប់។ ការស្លាប់នេះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គឺការសម្លាប់នេះ ត្រូវសម្លាប់ឲ្យបានហ្មត់ចត់ ឲ្យបានស្អាតបាត ហើយត្រូវតែសម្លាប់ដោយសម្ងាត់បំផុត។ មានអ្នកទោសតិចតួចមែនទែន ដែលអាចនឹងរត់គេចខ្លួនបាន ប៉ុន្តែតិចណាស់។ ក៏ប៉ុន្តែបើនិយាយ ពាក់ព័ន្ធទៅនឹងចំនួនភាគរយនៃអ្នកទោសដែលត្រូវបានគេដោះលែងវិញនោះ ដូចដែលខ្ញុំបានឆ្លើយពីខាងដើមហើយ គឺថា នៅដើមដំបូងនៃរបបបដិវត្តន៍នោះ <មានចំនួនច្រើន>។ ក៏ប៉ុន្តែមកដល់ចុងក្រោយនៃរបបនោះ គឺមានឱកាសរស់តិចណាស់។ <ប៉ុន្តែខ្ញុំគិតថា គុក>នៅតាមមូលដ្ឋាននានាគឺ ខ្ញុំយល់ឃើញថា អ្នកទោសដែលត្រូវបានដោះលែងហ្នឹងមិនលើសពី បីទៅបួនភាគរយទេ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកអ្នកជំនាញដែលបានឆ្លើយចំពោះសំណួររបស់ខ្ញុំ។ សូមគោរពលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកចៅក្រម។ លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានសំណួរ? បាទ បើមិនមានសំណួរទេ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីដើម្បីមានឱកាសសួរដេញដោលចំពោះអ្នកជំនាញ។ ដំបូងនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីទាំងអស់។ អរុណសួស្តី លោក ឡូកា។ លោកប្រធាន ឥឡូវនេះ ខ្ញុំសូមជម្រាបអំពីម៉ោងគឺថា ខ្ញុំចាប់ផ្តើមនៅម៉ោងប្រាំបួន សាមសិបនាទីមានន័យថា យើងខ្ញុំត្រូវការពេលវេលាបន្ថែមនេះ គឺស្អែកនេះ គឺកន្លះម៉ោងទៀត។

[០៩:២៩:១៦]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ឡូកា ខ្ញុំចង់និយាយឡើងវិញជាមួយនឹងលោក អំពីប្រធានបទផ្នែកជំនាញរបស់លោក គឺវិធីសាស្ត្រដែលលោកបានប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវរបស់លោក។ ឥឡូវហ្នឹងខ្ញុំសូមនិយាយសង្ខេបទៅចុះ ថាតើជំនាញរបស់លោកហ្នឹងមានអ្វីខ្លះដែរ? តើលោកយល់ស្របជាមួយនឹងខ្ញុំទេដែលថាលោកនេះ មិនមែនជាអ្នកជំនាញខាងផ្នែកចិត្តសាស្ត្រទេ មែនទេ?

**លោក ហង់រី ឡូកា៖**

**ឆ៖** បាទ ត្រឹមត្រូវហើយ ខ្ញុំមិនមែនអ្នកជំនាញផ្នែកហ្នឹងទេ។

**ស៖** ដូច្នេះ លោកឆ្លើយថា នួន ជា អ្នកឃ្លានអំណាច ដោយសារតែគាត់ហ្នឹង ភ័យខ្លាចអ៊ីចឹង។ តើនេះជាយោបល់ផ្ទាល់ខ្លួនរបស់លោកទេឬ?

**ឆ៖** មិនតែជាគំនិតផ្ទាល់ខ្លួនខ្ញុំទេ។ នេះ ខ្ញុំបានលើកឡើងដដែលៗ នូវអ្វីដែលខ្ញុំបានអានពីអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់។ ហើយពាក់ព័ន្ធទៅនឹងផ្នែកចិត្តសាស្ត្រវិញនោះ គឺថាបាទ មានអ្នកជំនាញជនជាតិបារាំងម្នាក់និយាយប្រវត្តិរូបរបស់ រ៉ូប៊ីព្យែរ។ ពេលនេះ នឹកឈ្មោះគាត់អត់ទាន់ទេនេះ ក៏ប៉ុន្តែគាត់សរសេរវែងឆ្ងាយមែនទែន បញ្ហាចិត្តសាស្ត្រនេះ។ គាត់គឺថាជាអ្នកចិត្តសាស្ត្រ ហើយគាត់ជាប្រធានផ្នែក<ចិត្តសាស្ត្រ>នៃមន្ទីរពេទ្យមួយដ៏ធំនៅទីក្រុងបារីស ហើយគាត់ប្រើប្រាស់ពាក្យនេះតែម្តង។ ក្នុងករណីនេះ ខ្ញុំគ្រាន់តែចង់និយាយថា ការ -- ដោយខ្ញុំលើកឡើងអំពីការវិភាគរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ដទៃទៀត ឬក៏អ្នកចិត្តសាស្ត្រដទៃទៀតតែប៉ុណ្ណោះ។

[០៩:៣១:៣៦]

**ស៖** ហើយខ្ញុំដឹងថា លោកមិនមែនជាអ្នកដែលមានជំនាញខាងផ្នែកប្រជាសាស្ត្រដែរមែនទេ?

**ឆ៖** <សូមទោស ខ្ញុំបញ្ចប់ការឆ្លើយសំណួរពីខាងដើមនោះសិន។> បាទ ខ្ញុំបានលើកឡើង គឺមានវេជ្ជបណ្ឌិត ហ្សង់ អាក់តារិត – អេ-អ័រ-ធី-អេ-អ័រ-អាយ-ធី – ឈ្មោះ ឌុកទ័រ ហ្សង់ អាតារីត។ ខ្ញុំយោងនោះ គឺ<ជាសៀវភៅ>ល្បី<របស់គាត់អំពី> រ៉ូប៊ីព្យែរ <ដែលបានទទួលការកោតសរសើរបំផុតពីមេ>ដឹកនាំរបស់ខ្មែរក្រហម។ ពាក់ព័ន្ធទៅនឹងកត្តាប្រជាសាស្ត្រ គឺខ្ញុំមិនមែនជាអ្នកផ្នែកខាងកត្តាប្រជាសាស្ត្រទេ ខ្ញុំយកពាក្យពេចន៍របស់អ្នកសិក្សាស្រាវជ្រាវដទៃទៀត ដូចជា ម៉ារេក ស្លីវិនស្គី ដែលសរសេរអំពីប្រល័យពូជសាសន៍ដោយពួកខ្មែរក្រហម។ ខ្ញុំគ្រាន់តែយកពាក្យសម្តីរបស់អ្នកសិក្សាស្រាវជ្រាវ ទី១ គឺឈ្មោះ ស្លីវិនស្គី ហើយ<ទីពីរ គឺពាក្យដែលបានប្រើប្រាស់ក្នុងតុលាការនេះតែម្តង ក្នុងសំណុំរឿង ០០១> យកមកនិយាយឡើងវិញតែប៉ុណ្ណោះ។

**ស៖** តើលោកយល់ស្របជាមួយខ្ញុំទេ ដែលថាលោកក៏មិនមែនជាអ្នកជំនាញខាងផ្នែកវិទ្យាសាស្ត្រកសិកម្មអីដែរ មែនទេ? តើបើខ្ញុំនិយាយថាអ៊ីចឹង ត្រឹមត្រូវដែរទេ?

**ឆ៖** ត្រឹមត្រូវហើយ ខ្ញុំមិនមែនជាអ្នកជំនាញខាងផ្នែកកសិកម្មមែន បើទោះណាជាខ្ញុំ<>មានសួន ឬក៏ដាំបន្លែអីក៏ដោយ។ <ខ្ញុំពិតជាមិនមែនជាអ្នកជំនាញខាងកសិកម្មទេ។>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អ៊ីចឹង <នៅពេលដែលលោកនិយាយថា>គោលនយោបាយផលិតឲ្យ<បាន>៣តោនក្នុង១ហិកតានេះ គឺថា<ពិតជា>មិនមែនជាគោលនយោបាយ<របស់កម្ពុជាប្រជាធិបតេយ្យ ឬ>បក្សកុម្មុយនីស្តកម្ពុជា<ទេ នេះគឺគ្រាន់តែ>ជា<គំនិតផ្ទាល់ខ្លួនលោកតែប៉ុណ្ណោះ តើត្រឹមត្រូវ>ទេ?

**ឆ៖** <ទេ វាមិនមែនជាគំនិតផ្ទាល់ខ្លួននោះទេ។>នេះគឺថាជាការយល់ឃើញរបស់បុគ្គលម្នាក់ៗ<ដែលបាន>សរសេរ<អំពី>កម្ពុជាប្រជាធិបតេយ្យ។

**ស៖** តើលោក<យល់ស្របជាមួយខ្ញុំទេថា លោកមិនមែនជាអ្នកវិទ្យាសាស្ត្រនយោបាយ ឬក៏ជាអ្នក>ជំនាញខាង<វិទ្យាសាស្ត្រ>នយោបាយ<>ទេ?

**ឆ៖** អាចឆ្លើយថា បាទក៏បាន អត់ក៏បាន។ <បើឆ្លើយថា> បាទ គឺថាខ្ញុំ<មិន>ទទួលបានការសិក្សាខាងផ្នែកវិទ្យាសាស្ត្រនយោបាយ<ទេ>។ <>ខ្ញុំមិនមានសញ្ញាប័ត្រ<ដើម្បីផលិត>ខាងផ្នែកវិទ្យាសាស្ត្រនយោបាយ<ទេ>។ <ប៉ុន្តែបើឆ្លើយថា ទេ វិញ គេបានបង្រៀនខ្ញុំអំពី -- ដូចលោកបានដឹងហើយខ្ញុំគឺជាអ្នក>ជំនាញ<ខាងចក្រភព>អង់គ្លេស<>ទំនើប <ហើយ>ខ្ញុំ<បាន>បង្រៀន<ប្រវត្តិសាស្ត្រ>របស់ចក្រភពអង់គ្លេស ជាច្រើន<ទសវត្សរ៍>ដែរ។ <ហើយខ្ញុំបានបង្រៀនយ៉ាងជាក់លាក់អំពីប្រព័ន្ធនយោបាយចក្រភពអង់គ្លេស ហើយខ្ញុំខ្លួនឯងក៏មានមោទនភាពដែរ។> នៅពេលដែលខ្ញុំចាប់ផ្ដើមធ្វើការសិក្សាស្រាវជ្រាវអំពីកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៨៩ ជាង២៥ឆ្នាំកន្លងទៅហើយ គឺថាខ្ញុំបានសៀវភៅសំខាន់ៗអំពីរបបផ្ដាច់ការ ហើយខ្ញុំក៏បានបង្រៀននៅ<វិទ្យាស្ថាន>សិក្សាផ្នែកនយោបាយនៅទីក្រុងលីយ៉ុង ជាពិសេសវគ្គសិក្សារៀនសូត្រអំពីកម្ពុជាប្រជាធិបតេយ្យ ជាពិសេសគឺបង្រៀនសញ្ញាណនៃរបបផ្ដាច់ការ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះខ្ញុំអាចអះអាងថា <ទោះបីជា>ខ្ញុំមិនមានសញ្ញាប័ត្រ<ក៏ដោយ> ក៏ប៉ុន្តែខ្ញុំមានបទពិសោធន៍ និងការអនុវត្តជាក់ស្ដែង គឺថាយើងរៀនៗតាមៗការអនុវត្តជាក់ស្ដែង<ដូចដែល>ខ្មែរក្រហម<បាន>និយាយអ៊ីចឹងដែរ ថារៀនតាមការអនុវត្ត ផ្ទាល់តែម្ដង។ <ហើយក៏មានការជឿទុកចិត្តក្នុងរឿងនេះខ្លះដែរ។>

**ស៖** លោក ឡូកា--

**អ្នកបកប្រែ៖**

បាទ លោកប្រធាន សូមឲ្យសហមេធាវីសួរម្ដងទៀត។

**ប្រធានអង្គជំនុំ៖**

សួរៗម្ដងទៀត ដូចអត់បានមានការបកប្រែត្រឹមត្រូវទេ។

[០៩:៣៥:៥៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ហង់រី ឡូកា តើលោក<ធ្លាប់ឮ>ពាក្យថា ការៗវាយតម្លៃគ្នាទៅវិញទៅមកដែរទេ លោកដឹងរឿងនេះទេ?

**លោក ហង់រី ឡូកា៖**

**ឆ៖** ខ្ញុំមិនដឹងថាតើអ្នកបកប្រែយល់ពាក្យលោកច្បាស់ ឬក៏អត់ទេ លោកអាចប្រើពាក្យដោយប្រៀបធៀបក៏បានដែរ <គឺការវាយតម្លៃរបស់អ្នកសិក្សាផ្សេងទៀត។> ខ្ញុំដឹងអំពីរឿងនេះ។ យើងមានការ គេហៅថាការត្រួតពិនិត្យគ្នាទៅវិញទៅមក ជាពិសេសនៅពេលដែលខ្ញុំទទួលយកសញ្ញាប័ត្របណ្ឌិតរបស់ខ្ញុំ<នៅប្រទេសបារាំង។> គឺសៀវភៅដែលខ្ញុំបានសរសេរ ក៏ដូចជាអត្ថបទមួយចំនួនដែលខ្ញុំបានសរសេរ ហើយការស្រាវជ្រាវរបស់ខ្ញុំ គឺត្រូវបានអ្នកដទៃជួយពិនិត្យទៅវិញទៅមកជាបន្តបន្ទាប់។ ហើយកាលពីថ្ងៃសៅរ៍នោះ ខ្ញុំមានអ្នកសិក្សាស្រាវជ្រាវជនជាតិបារាំងដែលបានមកផ្ទះរបស់ខ្ញុំមកជួបខ្ញុំ ហើយស្នើខ្ញុំឲ្យខ្ញុំសរសេរសៀវភៅមួយក្បាលផ្សេងទៀត។ ដូច្នេះគឺពាក់ព័ន្ធទៅនឹងសុភាសិតខ្មែរក្រហមនោះគេមានគេពេញចិត្តពេញថ្លើមច្រើនណាស់ ហើយ<ទោះបីជា>ការបោះពុម្ពផ្សាយចុងក្រោយរបស់ខ្ញុំជាង១០ឆ្នាំកន្លងមកហើយ <ប៉ុន្តែ>លោក<នៅតែ>អាចរក<>ឃើញ<មានលក់>នៅតាមបណ្ដាតូបលក់សៀវភៅនានា<>។ ហើយខ្ញុំបានទទួលសារមកពីអ្នកដទៃមកថា គឺជាសៀវភៅមួយដែលគេចូលចិត្តអានណាស់និយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងគឺថា<ខ្ញុំ>មានអ្នកអាន<> អ្នកកាសែត <និង>អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់<ជួយត្រួតពិនិត្យខ្ញុំ>រយៈពេល២៥ ទៅ២៦ឆ្នាំ ដែល<> ខ្ញុំសិក្សាអំពី<>ខ្មែរ<>។

[០៩:៣៧:៥១]

**ស៖** ខ្ញុំនឹងសួរអំពីនិក្ខេបបទថ្នាក់បណ្ឌិតរបស់លោក ក៏ដូចជាសៀវភៅរបស់លោក ពាក់ព័ន្ធទៅនឹងសុភាសិតរបស់កម្ពុជាប្រជាធិបតេយ្យ។ <តើលោកធ្លាប់សរសេរ>អត្ថបទសិក្សាស្រាវជ្រាវជាន់ខ្ពស់ដែលថាត្រូវបានអ្នកដទៃជួយពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ<ទេ> គឺ<>និយាយ<>អំពីរបប<កុម្មុយនីស្ដ ឬរបបផ្ដាច់ការ ឬមនោគមន៍វិជ្ជាកុម្មុយនីស្ដជាដើម>?

**ឆ៖** <បាទ ខ្ញុំសរសេរមួយចំនួនតូច។> ជាបន្តបន្ទាប់<ក្រោយពី>សៀវភៅនិយាយអំពីកម្ពុជាប្រជាធិបតេយ្យនេះ ត្រូវបានបោះចេញពុម្ពផ្សាយ <>ខ្ញុំ<បានបោះពុម្ព>សៀវភៅ<មួយ>របស់ ហ្វ្រង់

ស្វ៊រ ប៊ីហ្ស <ឈ្មោះថា “ឡេ ព័តត្រេ” សៀវភៅ>នេះ<>ខ្ញុំ<ចូលចិត្តខ្លាំងណាស់>។ <ខ្ញុំបានត្រួតពិនិត្យសៀវភៅនេះ ហើយ ហ្វ្រង់ស្វ័រ ប៊ីហ្ស ដឹងគុណខ្ញុំ ព្រោះគាត់គិតថា អ្វីដែលខ្ញុំបាននិយាយគឺមានសារៈសំខាន់។ នៅពេលដែល> ហ្វីលីព ស្សូត <>ចេញសៀវភៅនិយាយអំពី “សុបិនអាក្រក់របស់<ប៉ុល ពត>”នេះ ខ្ញុំក៏បាន<ផលិតការវាយតម្លៃមួយ។ ខ្ញុំមិនដឹងថា ខ្ញុំ-->

**ស៖** ខ្ញុំខ្លាចតែស្តាប់គ្នាមិនយល់ទេត្រង់កន្លែងនេះ ពាក្យថា *រៀ វីវ្យូ* គឺខ្ញុំសំដៅទៅលើការជួយពិនិត្យផ្ទៀតផ្ទាត់<អត្ថបទ សម្រាប់បោះពុម្ពនៅក្នុងទស្សនាវដ្តីសិក្សាជាន់ខ្ពស់> និយាយអំពីរបប<កុម្មុយនីស្ត ឬរបបផ្តាច់ការ។ តើលោកមានបានបោះពុម្ពមួយណាទេ?>

**ឆ៖** បាទ ប៉ុន្តែសំខាន់បំផុតនោះគឺពិនិត្យជាភាសាបារាំង។ ខ្ញុំក៏បានចេញអត្ថបទមួយចំនួនទៀតផងដែរ <ក្នុងនោះយ៉ាងហោចណាស់មានបីអត្ថបទ>ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី<សិក្សាជាន់ខ្ពស់>ស្តីអំពីរបបកុម្មុយនីស្ត។ <ទី១>គឺ *“ខ្មែររូស ហ្គូឡាក់”* ដែលបោះពុម្ពផ្សាយជាភាសាបារាំង គឺថាមិនមានជាភាសាអង់គ្លេសទេ ហើយខ្ញុំបានបោះពុម្ពផ្សាយផងដែរ<អំពីការវាយតម្លៃលើសវនាការ ឌុច ដែលមានជាង៥០>ទំព័រ ហើយនៅពេលដែលសៀវភៅមួយហៅថា “<សៀវភៅខ្មៅនៃរបបកុម្មុនីស្ត>” <ត្រូវបានបោះពុម្ពដោយ ស្តេផាន ខតទ័រ> នោះគឺថាមានភាពចម្រូងចម្រាសគ្នាមែនទែន<នៅប្រទេសបារាំង>។ អ៊ីចឹងខ្ញុំបានបោះពុម្ពផ្សាយទស្សនៈយល់ឃើញរបស់ខ្ញុំ និយាយអំពី “សៀវភៅខ្មៅនៃរបបកុម្មុយនីស្ត” <ហើយរបាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយផងដែរនៅក្នុង> “របបកុម្មុយនីស្ត”<>។ ហើយអត្ថបទមួយរបស់ខ្ញុំ <ត្រូវបាន>បោះពុម្ពផ្សាយ<នៅក្នុងទស្សនាវដ្តី *“អ៊ីនធឺណេសិនណល យូរ៉ូភាន រីវ្យូ”* ដែលជាអត្ថបទសិក្សាមួយសម្រាប់>សិក្ខាសាលា<>ដែលខ្ញុំបានចូលរួម<នៅទីក្រុងលីដ>នៅដើមឆ្នាំ២០០០ ហើយប្រធានបទសិក្ខាសាលានោះ គឺនិយាយអំពី<អំពើ>ប្រល័យពូជសាសន៍ ដែលសៀវភៅនោះ គឺថាសរសេរជាភាសាអង់គ្លេស។ ជាការពិតហើយ គឺថាខ្ញុំនឹងមានការបោះពុម្ពផ្សាយបន្ថែមទៀត។

[០៩:៤០:៤៣]

**ស៖** តើមានហេតុផលណាជាក់លាក់ដែលថាការបោះពុម្ពផ្សាយទាំងអស់នេះ<មួយចំនួន> ខ្ញុំរកអត់<>ឃើញ<>នៅក្នុង *ស៊ីវី* ប្រវត្តិរូបរបស់លោក<ដែលធ្វើនៅខែមិថុនា ឆ្នាំ២០១៦នេះ?>

**ឆ៖** កាលណាយើងសរសេរប្រវត្តិរូប គឺយើងនិយាយអំពីជំនាញវិជ្ជាជីវៈរបស់យើង ហើយនិងស្នាដៃបោះពុម្ពផ្សាយ<ឬស្នាដៃបោះពុម្ពចម្បងៗ>។ ខ្ញុំមិនមានជំហរអីដែលត្រូវអាចជម្រាបទៅលោក

អំពីឈ្មោះទីកន្លែង ឬក៏ឈ្មោះអត្ថបទទាំងអស់ ដែលខ្ញុំបានបោះពុម្ពផ្សាយទាំងអស់បានទេ។ ខ្ញុំដឹងថាអ្នកនិពន្ធដូចជា ដេវីដ ឆេនដ៍ល័រ គឺថាបានបោះពុម្ពផ្សាយ<អត្ថបទ និងសៀវភៅច្រើន>ជាង<ខ្ញុំ>១០<ដង> ប៉ុន្តែជាមធ្យម -- <ខ្ញុំជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ម្នាក់។> សម្រាប់អ្នកសិក្សាស្រាវជ្រាវម្នាក់ៗគឺថា ខ្ញុំ<គិតថា>យ៉ាងហោចណាស់<ខ្ញុំ>បានបោះពុម្ពផ្សាយក្នុងកម្រិតមធ្យមដែរ។

**ស៖** <យើងនឹងត្រឡប់មកនិយាយពីចំណុចនេះវិញនៅពេលយើងធ្វើសេចក្តីសន្និដ្ឋាន។> ឥឡូវខ្ញុំសួរអំពីជំនាញចម្បងៗរបស់លោក ដូចដែលលោកបានបញ្ជាក់មកហើយ គឺថានៅម៉ោង ១១:១៥ នាទីពេលព្រឹក គឺថ្ងៃដំបូងនៃសវនាការ គឺថា លោកថា “លោកគ្រាន់តែជាអ្នកប្រវត្តិវិទ្យាសាមញ្ញម្នាក់តែប៉ុណ្ណោះ”។ នៅពេលដែលលោកអញ្ជើញមកប្រទេសកម្ពុជានៅឆ្នាំ១៩៨២ ទៅដល់៨៤ លោកបានសម្ភាសប្រជាជនជាច្រើនទាក់ទងទៅនឹងកិច្ចការរបស់លោក។ តើនៅពេលនោះ លោកគឺជាអ្នកប្រវត្តិសាស្ត្រ ឬក៏លោកគ្រាន់តែជាគ្រូបង្រៀនភាសាអង់គ្លេស ជំនាញខាងផ្នែកភាសាអង់គ្លេសតែប៉ុណ្ណោះទេ?

[០៩:៤៣:០៨]

**ឆ៖** ជាការពិតហើយ ខ្ញុំបង្រៀនភាសាអង់គ្លេស។ <ប៉ុន្តែ>នៅនាយកដ្ឋានអក្សរសាស្ត្រ<អង់គ្លេស>ពេលនោះ <គេ>មិនមែនបង្រៀនតែភាសាអង់គ្លេសទេ <គេ>បង្រៀនឲ្យចេះបកប្រែ<បង្រៀន>ភាសាវិទ្យា បង្រៀនអក្សរសាស្ត្រ ក៏ដូចជាបង្រៀនអំពីប្រវត្តិសាស្ត្រផងដែរ។ <ដូច្នេះ> ហើយនៅ<ពេលដែលខ្ញុំនៅ>ក្នុងនាយកដ្ឋានអក្សរសាស្ត្រ<អង់គ្លេស>នៅទីក្រុងលីយ៉ុង ជំនាញរបស់ខ្ញុំនោះគឺប្រវត្តិវិទ្យានេះឯង។ នៅពេលដែលខ្ញុំមកប្រទេសកម្ពុជា លោកហាក់បីដូចជាច្រឡំឆ្នាំបន្តិច មិនមែន៨២-៨៤ ទេ ជាឆ្នាំសិក្សារបស់ខ្ញុំហ្នឹង គឺឆ្នាំ៨៣-៨៤។ នៅពេលនោះ គឺ៨៣ ខ្ញុំបានបោះពុម្ពផ្សាយប្រវត្តិរូបរបស់ មឿង សុន <ជាមួយរោង>ពុម្ព<ដ៏ល្បីល្បាញឈ្មោះ ហ្វាយ៉ាត។ ខ្ញុំគិតថា ជាការបោះពុម្ព>សៀវភៅ<ដ៏ល្អ> ដោយមានទាំងកំណត់ចំណារ កំណត់អំពីផែនទី <និង>ភស្តុតាង<ច្បាស់លាស់ត្រូវបានគេរៀបចំឡើង។>ហើយសៀវភៅនេះ<បង្ហាញថា>គឺថាខ្ញុំចាប់ផ្តើមពីការសិក្សារបៀបអង់គ្លេសមករបៀបជាកម្ពុជាវិញម្តង។ ចៅហ្វាយរបស់ខ្ញុំនោះ គឺរដ្ឋមន្ត្រីក្រសួងអប់រំ <>នៅប្រទេសបារាំងនេះ<បានផ្តល់ការអនុគ្រោះយ៉ាងខ្លាំងដល់ខ្ញុំនៅប្រទេសបារាំង គឺការឈប់សម្រាកមួយឆ្នាំ។ ការឈប់សម្រាកមួយឆ្នាំនៅ>អង់គ្លេស<គឺជារឿងធម្មតា ប៉ុន្តែនៅសកលវិទ្យាល័យនានានៅប្រទេសបារាំងមិនមានការអនុញ្ញាត>បែបនេះទេ។ <ប៉ុន្តែដោយសារគេចាត់ទុកថា>អ្វីដែលខ្ញុំធ្វើកន្លងមកនោះ គឺថាគ្រប់គ្រាន់ហើយសម្រាប់រដ្ឋាភិបាលបារាំងបន្តឲ្យប្រាក់បៀវត្សរ៍ដល់ខ្ញុំឲ្យបានពេញលេញ <>ដោយខ្ញុំមិន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចាំបាច់មានកាតព្វកិច្ចបង្រៀននៅទីក្រុងលីយ៉ុង<>។ អ៊ីចឹងឯងបានជាខ្ញុំមកប្រទេសកម្ពុជានេះ ចំណាយពេលជាង១៤ខែ ពីខែកក្កដា ៩៣ ដល់ខែកញ្ញា ៩៤ គឺជាពេលវេលាមួយ<ដែលប្រហែលជាខ្ញុំមិនគួរធ្វើបាននោះទេ>។ ខ្ញុំបានបង្រៀនមួយវគ្គនៅនាយកដ្ឋានអប់រំ <ជំនួសឲ្យការយកចិត្តទុកដាក់ទៅលើបញ្ហា>ពីរ គឺការបន្តការសិក្សាស្រាវជ្រាវតាមមូលដ្ឋានរបស់ខ្ញុំ និងទី២ ការបន្តការប្រមូលសុភាសិតទាំងអស់ដូចដែលខ្ញុំបានសរសេរអ៊ីចឹង ពេលនោះគឺថាខ្ញុំសកម្មមែនទែន។ ខ្ញុំគិតថាការផ្លាស់ប្តូរប្រធានបទរបស់ខ្ញុំ គឺវាជារឿងមួយចម្លែកបន្តិច <នៅក្នុងពិភព>និយាយជាភាសាបារាំង ក៏ប៉ុន្តែជា<ការ>សាមញ្ញណាស់<សម្រាប់ពិភពនិយាយ>ភាសាអង់គ្លេស។ មិនមែនដោយសារតែយើងមានជំនាញតែផ្នែកណាមួយ មុខវិជ្ជាណាមួយ ហើយគឺថាយើង<>នៅក្នុងជំនាញ<៤០>ឆ្នាំនេះ <ដូច>ខ្ញុំ<នៅក្នុងជំនាញដល់ទៅ៥០>ឆ្នាំឯណោះ គឺថាមិនមែនថាមានជំនាញប៉ុណ្ណោះហើយ មិនអាចទៅរកជំនាញមួយទៀតបានទេ។ អ៊ីចឹង<ខ្ញុំ>នៅក្នុង<ជំនាញ>ផ្នែក<ភាសាអង់គ្លេសរយៈពេល>២៥ឆ្នាំ ហើយ<ជាអ្នកជំនាញអំពីបញ្ហា>ប្រទេសកម្ពុជានេះ<រយៈ>ពេល២៥ឆ្នាំ<>។ ខ្ញុំថាគ្មានអ្វីខុសជាមួយនឹងការសិក្សាស្រាវជ្រាវរបស់ខ្ញុំទេ។ ហើយខ្ញុំយល់ឃើញថាវាមានសារៈសំខាន់មែនទែន គឺថាខ្ញុំអាចធ្វើទាំងផ្នែកជំនាញនេះផង។ គឺជំនាញរបស់ខ្ញុំពីរ គឺភាសាអង់គ្លេសផង និងប្រវត្តិវិទ្យាផង។

[០៩:៤៧:០២]

**ស៖** លោកអ្នកជំនាញ លោកអាចសូមឆ្លើយឲ្យខ្លីបន្តិចមក ដោយសារតែខ្ញុំមិនមានពេលវេលាច្រើនទេសម្រាប់ថ្ងៃនេះ ក៏ប៉ុន្តែជាសង្ខេបមកតើលោកយល់ស្របជាមួយខ្ញុំទេ នៅពេលលោកធ្វើសិក្សាស្រាវជ្រាវនៅក្នុងឆ្នាំ៩៣ លោកមិនមែនជាអ្នកសិក្សាស្រាវជ្រាវជំនាញជាអ្នកប្រវត្តិសាស្ត្រដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវទេ? <លោកមិនមែនជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ខាងប្រវត្តិសាស្ត្រទេ> មែនទេ?

**ឆ៖** ខ្ញុំសូមឆ្លើយទាំងពីរ ទាំងបាទ ទាំងមិនមែន។ បាទ ព្រោះថាខ្ញុំមិនមានសញ្ញាបត្រ ឬក៏មិនមានឯកសារអ្វីមួយដែលខ្ញុំបង្កើតក្នុងនាមជាអ្នកប្រវត្តិវិទូទេ ប៉ុន្តែខ្ញុំធ្លាប់រៀនប្រវត្តិសាស្ត្រនៅបឋម ហើយបន្តទៀតនៅ<ឆ្នាំសិក្សាទី១នៅ>សកលវិទ្យាល័យ ហើយខ្ញុំសិក្សាយ៉ាងច្រើន<អំពីប្រវត្តិសាស្ត្រ ដែលជាមុខវិជ្ជា>សិក្សាទី២ <ហើយនៅពេលដែលខ្ញុំបានបង្រៀន> គឺនៅក្នុងឆ្នាំ៦៧ <នៅ>លីយ៉ុង ខ្ញុំមិនបាន<បង្រៀន>អ្វីក្រៅពីប្រវត្តិសាស្ត្រអង់គ្លេសនៅក្នុងសតវត្សរ៍១៩ និង ២០ នោះឡើយ។

**ស៖** នៅក្នុងសក្ខីកម្មកាលពីសប្តាហ៍មុនរបស់លោក <> នៅថ្ងៃទី០១ <ម៉ោង១៥:២៧ នាទី>

គឺលោកនិយាយថាលោកធ្វើការស្រាវជ្រាវ<មិនជាលក្ខណៈផ្លូវការទេ។> ហើយនៅថ្ងៃដដែលម៉ោង ១១:០៤ លោកបាននិយាយថា លោកសរសេរពាក្យស្លោក ដើម្បីគ្រាន់តែកំសាន្ត។ ហើយនៅពេលដែលគេសួរលោក គឺពេលចៅក្រម ឡាវែន៍ សួរ គឺលោកឆ្លើយថាលោកមិនជាអ្នកអាជីពប៉ុន្មាននោះទេ។ ហើយលោកក៏មិនបានថតសំឡេងនៃការសម្ភាសណាមួយនោះឡើយ លោកនិយាយភាសាខ្មែរបានតិចតួច។ កាលៈទេសៈទាំងអស់នេះ តើវាជាកត្តាមួយ ថាតើវាជាកត្តាមួយ ដើម្បីឱ្យអ្នកដទៃធ្វើការវាយតម្លៃថាលោកគួរទទួលបានសញ្ញាបត្រដុកទ័រ ឬក៏នោះទេ?

[០៩:៤៩:២០]

**ឆ៖** មិនមែនទាល់តែសោះ នៅពេលដែលខ្ញុំការពារបណ្ឌិតរបស់ខ្ញុំក្នុងឆ្នាំ២០០០ <>មាន<សាធារណជនចូលរួម>យ៉ាងច្រើន។ ហើយអ្នកខ្លះនិយាយថា គឺជាការការពារបណ្ឌិត<ដ៏>គួរឱ្យចាប់អារម្មណ៍បំផុតដែលគេធ្លាប់ចូលរួមស្ដាប់។

**សៈ** ប៉ុន្តែប្រាកដណាស់ថា អ្នកសិក្សាត្រូវតែត្រួតពិនិត្យឡើងវិញ អំពីការស្រាវជ្រាវដែលលោកបានធ្វើកន្លងមក។ ហើយថាតើពួកគាត់ហ្នឹងអាចកំណត់យ៉ាងដូចម្ដេច ដែលៗថាលោកបានជួបនិយាយជាមួយ<មនុស្សទាំងអស់នោះ ហើយលោកយល់ពីពួកគេបានច្បាស់លាស់> តើអ្នកបកប្រែឱ្យលោកហ្នឹង គេបកប្រែបានល្អដែរឬទេ? លោកធ្វើយ៉ាងម៉េច បានដឹងអំពីចំណុចទាំងអស់នេះ?

**ឆ៖**<ពួកគេ>ចាំបាច់ត្រូវតែ<មានអ្នកត្រួតពិនិត្យបែបនោះហើយ> ព្រោះថាមានអ្នកត្រួតពិនិត្យចំនួនបួន<នាក់។ ម្នាក់ក្នុងចំណោមនោះ> គឺ<ជនជាតិខ្មែរ>។ គាត់ជាអ្នកពិនិត្យ មើលការបកប្រែ គឺការបកប្រែពាក្យស្លោកពីខ្មែរទៅបារាំង។ ហើយប្រសិនបើពួកគាត់មិនពេញចិត្តជាមួយការបកប្រែទេ គឺពួកគាត់នឹង<កែខ្ញុំឱ្យបានល្អបំផុត ដែលគេហៅ>ថាពេលនុ៎ង គឺ *ហ្វេលីស៊ីតាស្យុង ដុយ ហ្សូរី*។ <> ប្រសិនបើពួកគាត់មិនពេញចិត្តទេ ពួកហ្នឹង ពួកគាត់មិនឱ្យសញ្ញាប័ត្រ ឬក៏មិនឱ្យឋានៈជាបណ្ឌិតមកខ្ញុំនោះឡើយ។

**សៈ** តើលោកអាចប្រាប់បានទេថា តើលោកបានផ្ដល់នូវកំណត់ត្រារបស់លោកដែរឬទេទៅៗពួកគាត់? ថាតើពួកគាត់អាចអានកំណត់ត្រារបស់លោក អាចពិនិត្យមើលទៅលើកំណត់ត្រារបស់លោកហើយបញ្ជាក់ថា នេះគឺជាអ្វីដែលលោកបាននិយាយ ឬក៏បានជួបសម្ភាសជាមួយប្រជាជនដែរឬទេ?

**ឆ៖** សុំទោសលោកមេធាវី ខ្ញុំគិតថា លោកកំពុងតែធ្វើឱ្យតុលាការនេះ ធ្វើឱ្យសាធារណជនដែលស្ដាប់ខ្ញុំ ក៏ដូចជាអង្គជំនុំជម្រះ គាត់ចំណាយពេលអត់ប្រយោជន៍ស្ដាប់សំណួរទាំងអស់នេះ។ លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និយាយកន្លងមកថា លោកមានពេលវេលាតិចតួចទេ ដូច្នេះសូមលោក<សួរ>សំណួរដែលពាក់ព័ន្ធមកតែម្តងទៅ។

**ស៖** ខ្ញុំគិតថាវាពាក់ព័ន្ធហើយ។ ខ្ញុំ<នឹង>ពន្យល់<ថាហេតុអីបានជាវាពាក់ព័ន្ធ។ យើងត្រូវរកឲ្យឃើញ>ថា តើលោកមានជំនាញ<ឬក៏អត់ទេ>។ ឥឡូវនេះខ្ញុំសួរសំណួរចុងក្រោយទៅលើប្រធានបទនេះ។ <តើ>លោកបានប្រាប់ទៅដល់គណៈមេប្រយោគទាំងប្រាំនុ៎ងថា ការស្រាវជ្រាវរបស់លោក គឺមិនជាមានលក្ខណៈអាជីពខ្លាំងនោះទេ លោកគ្រាន់តែសរសេរពាក្យស្លោក ដោយដើម្បីកំសាន្តតែប៉ុណ្ណោះ <ហើយមិនមែនជាលក្ខណៈផ្លូវការផង តើលោកបានប្រាប់អ៊ីចឹងទេ?> តើគណៈមេប្រយោគហ្នឹង គាត់ដឹងអំពីអ្វីដែលលោកនិយាយហ្នឹងដែរឬទេ?

**ឆ៖** សំណួរមិនពាក់ព័ន្ធ ដូច្នេះខ្ញុំសូមបដិសេធមិនឆ្លើយ។

[០៩:៥២:៣៨]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមស្នើដោយគោរពថា សំណួរនេះ គឺវាមានភាពពាក់ព័ន្ធ។ ហេតុដូច្នេះ ខ្ញុំសូមឲ្យលោកៗ ឡូកា គាត់ឆ្លើយ ដើម្បីឲ្យយើងវាយតម្លៃ ថាតើគាត់ទទួលសញ្ញាបត្របណ្ឌិតហ្នឹង ដោយមានភាពជំនាញពាក់ព័ន្ធដែរឬក៏យ៉ាងណា ដើម្បីឲ្យយើងខ្ញុំអាចធ្វើការសម្រេចអំពីជំនាញរបស់គាត់។

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញ សូមលោកឆ្លើយតបនឹងសំណួរ!

**លោក ហង់រី ឡូកា៖**

**ឆ៖** ប្រសិនបើការប្រមូលពាក្យស្លោករបស់ខ្ញុំ វាៗឆ្កួត វាគ្មានលក្ខណៈសិក្សា ឬក៏វាគ្មានប្រយោជន៍អីនោះ <ហេតុអីបានជា *ស៊ីលវ៉ែម ប៊ុក*> នៅឆៀងម៉ៃ <នៅប៉ុន្មានឆ្នាំក្រោយមក បាន>ស្នើសុំឲ្យខ្ញុំបោះពុម្ព<ជាលើក>ទី២ <នូវឯកសារដែល>ត្រូវបានគេកែប្រែ <ធ្វើឲ្យធំជាងមុន> ហើយបានចំណាយថវិកាផ្ទាល់ខ្លួនដើម្បីបោះពុម្ពសៀវភៅនុ៎ង <>ហើយ<លក់ដាច់>យ៉ាងច្រើន ហើយខ្ញុំដឹងថាសៀវភៅនោះ នៅបន្តលក់នោះ ថាតើគេបន្តលក់នៅ*ម៉ូញូមិនប៊ុក*ហ្នឹង ដោយរបៀបណា ប្រសិនបើអត់ប្រយោជន៍បែបនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ឡូកា ខ្ញុំសូមបន្តទៅមុខទៀត។ តើលោកមានព្យាយាមស្វែងរកគាំទ្រ <>ការ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

សម្ភាសរបស់លោក ដែលលោកបានធ្វើឡើងជាមួយនឹងកម្មាភិបាល ក៏ដូចឯកសារសម័យខ្មែរក្រហម ដែរឬទេ? គឺខ្ញុំចង់សួរថា នៅពេលដែលលោកសរសេរសៀវភៅអំពីពាក្យស្លោកនោះ តើលោកមានបាន សិក្សាអំពីទស្សនាវដ្ដីទង់បដិវត្តន៍<> ឬមួយក៏មានសិក្សាអំពីសារទូរលេខ កំណត់ត្រាកិច្ចប្រជុំ ឬក៏ឯក សារប្រវត្តិសាស្ត្រតាំងពីសម័យនោះដែរឬទេ? តើលោកមានបានធ្វើទេ?

[០៩:៥៥:០០]

**លោក ហង់រី ឡូកា៖**

**ឆ៖** ខ្ញុំបានធ្វើ ប៉ុន្តែប្រភពព័ត៌មានចម្បងរបស់ខ្ញុំ ដូចដែលលោកឃើញនៅក្នុងកំណត់ត្រារបស់ ខ្ញុំហើយ គឺនៅក្នុងសៀវភៅក្រហម <--> សៀវភៅតូចក្រហមរបស់ ប៉ុល ពត <ដែលបោះពុម្ពជា ភាសាអង់គ្លេស គឺជាសេវាកម្មផ្សាយព័ត៌មានបរទេស> គឺខ្ញុំត្រូវទទួលបានការណែនាំដោយអាកាឌីមិច ខាងការពារជាតិអូស្ត្រាលី នៅកង់បឺរ៉ា គាត់ជាអ្នកណែនាំខ្ញុំឲ្យស្គាល់។ ដូច្នេះ ប្រភពព័ត៌មានចម្បងរបស់ ខ្ញុំ គឺពួកខ្មែរក្រហមផ្ទាល់តែម្ដង ហើយខ្ញុំបានដកស្រង់ចេញពី<>វិទ្យុខ្មែរក្រហម ដែលកត់ត្រាដោយខ្មែរ ក្រហមផ្ទាល់តែម្ដង ហើយមាន<របាយការណ៍អំពី>ការប្រជុំ ការធ្វើទស្សនកិច្ច<ទៅបរទេស អំពីការ សម្រេចបានរបស់របបនោះ> សុន្ទរកថា<ផ្លូវការ ដែលខ្ញុំបានដកស្រង់មកពី> ប៉ុល ពត, ខៀវ សំផន, នួន ជា <ហើយនិងផ្សេងៗទៀត។> ទាំងអស់ហ្នឹង -- ទាំងអស់នេះ គឺសុទ្ធតែជាប្រភពព័ត៌មានដែលខ្ញុំ ពឹងផ្អែកទៅលើ<ពាក្យស្លោកនោះ>។

**ស៖** សំណួរខ្ញុំសួរអ៊ីចេះវិញ តើ<ត្រឹមត្រូវទេ>នៅពេលដែលខ្ញុំពិនិត្យមើលទៅលើជើងទំព័រនៅ ក្នុងឯកសាររបស់លោកអំពីសៀវភៅពាក្យស្លោករបស់លោក គឺលោកមិនបានយោងទៅលើទស្សនាវដ្ដី ទង់បដិវត្ត ឬក៏កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ កំណត់ត្រាកិច្ចប្រជុំមេបញ្ជាការ<កងពល>ជាមួយនឹង សុន សេន ឬក៏សារទូរលេខអីទេ។ តើអ៊ីចឹងមែនទេ អត់មានអីអ៊ីចឹងមែនទេ?

[០៩:៥៦:៤៩]

**ឆ៖** ប្រហែលហើយ ព្រោះថា ការស្រាវជ្រាវរបស់ខ្ញុំ គឺតាមរយៈការចុះផ្ទាល់ ចុះទៅដល់ទី កន្លែង ទៅជួបជាមួយប្រជាជនដែលនៅ រស់នៅសហករណ៍សល់ពីរបបខ្មែរក្រហមនោះ។ ដូច្នេះ គឺថា ពេលខ្លះ គឺយើងទៅស្ដាប់ផ្ទាល់អំពីប្រជាជន ហើយម្យ៉ាងទៀត ព្យាយាមយល់ ថាតើពួកគាត់យល់ដឹង បែបណាអំពីរបបនោះ? តើពួកគាត់រស់នៅរបៀបណានៅក្នុងរបបនេះ? ថាតើការឃោសនារបស់របប នុ៎ងមានន័យយ៉ាងម៉េចចំពោះពួកគាត់? ដូច្នេះ អ្វីដែលខ្ញុំចង់បញ្ជាក់ គឺថាប្រភពព័ត៌មានរបស់ខ្ញុំ គឺមិនមែន

ប្រភពព័ត៌មានផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែខ្ញុំសួរទៅលើប្រជាជនដែលរស់នៅក្នុងរបប នោះ។

**សៈ** ខ្ញុំមិនចង់បញ្ជាក់ថា អ្វីដែលលោកកត់ត្រាទុំងវាខុសឆ្គង ឬក៏ខុសពីប្រវត្តិសាស្ត្រអីនោះទេ។ គ្រាន់តែខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាលោកមិនស្វែងរកការគាំទ្រអំពីឯកសារដែលសំខាន់បំផុត ដែលយើង ហៅថា អាចហៅថា ជាឯកសារបោះពុម្ពផ្សាយសំខាន់បំផុត ដូចជា ទស្សនាវដ្តីទង់បដិវត្តជាដើម។ ឧទាហរណ៍ ខ្ញុំលើកឧទាហរណ៍មួយ ដើម្បីឲ្យលោកយល់ច្បាស់អំពីអ្វីដែលខ្ញុំចង់និយាយ។ លោក និយាយអំពីពាក្យស្លោកមួយដែលថា “ទុកមិនចំណេញ ដកចេញក៏មិនខាត”។ គឺថាពាក្យស្លោកនេះ គ្មាន ទេ នៅក្នុងទស្សនាវដ្តីទង់បដិវត្ត ក៏ដូចឯកសារនានាសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំចង់ដឹង ថាហេតុអ្វីក៏លោកមិនព្យាយាមស្វែងរកការគាំទ្រពីឯកសារទាំងអស់នោះ គឺថាក្នុងនាមជាអ្នកស្រាវជ្រាវ លោក គួរតែបង្ហាញពីទិដ្ឋភាពទាំងស្រុងនៃមនោគមន៍វិជ្ជាខ្មែរក្រហម?

[០៩:៥៨:៥៣]

**ផៈ** ខ្ញុំព្យាយាមស្វែងរកការគាំទ្រដែរ ប៉ុន្តែមិនមែនការគាំទ្រចេញពីមេដឹកនាំកំពូលនោះទេ។ ខ្ញុំ មើលទៅលើផ្នែក ទៅលើមូលដ្ឋានតែម្តង ហើយម្យ៉ាងទៀត ខ្ញុំគិតថា នៅក្នុងអត្ថបទជាច្រើនរបស់ កម្ពុជាប្រជាធិបតេយ្យ គឺថាពាក្យស្លោកនេះ ត្រូវបានគេដកស្រង់យ៉ាងញឹកញាប់ ហើយច្រើនទៀតផង។ ហើយយើងអាចរកឃើញជាច្រើន ហើយប្រភពព័ត៌មានសំខាន់របស់ខ្ញុំមួយដែលខ្ញុំគិតថា អ្នកស្រាវជ្រាវ ដទៃទៀតមិនបានប្រើប្រាស់ឲ្យបានគ្រប់គ្រាន់នោះ គឺសក្ខីកម្មរបស់មនុស្ស។ ដូចដែលខ្ញុំបានបញ្ជាក់រួច ហើយកាលពីសប្តាហ៍មុននៅក្នុងតុលាការនេះ ថាខ្ញុំបានអាននូវចម្លើយរបស់ប្រជាជនជាច្រើន ដែលបាន បោះពុម្ព ហើយ<ឯកសារចុងក្រោយមួយអាចត្រូវបានគេនាំយកមកទីនេះ គឺវាត្រូវ>បានផ្សព្វផ្សាយនៅ ក្នុងប្រទេសបារាំង<កាលពីឆ្នាំមុន ហើយ>ខ្ញុំ<បាន>អាន<នៅរដូវក្តៅនេះ>។ ហើយក្នុងចំណោម ចម្លើយទាំងអស់នោះ យើងរកឃើញនូវពាក្យស្លោកទាំងនេះ គឺថាយើងឃើញប្រភេទពាក្យស្លោកទាំង អស់នេះ ហើយចំពោះខ្ញុំប៉ុណ្ណេះ គឺគ្រប់គ្រាន់ណាស់ទៅហើយ។

**សៈ** បើតាមដែលខ្ញុំដឹង ពាក្យស្លោកពាក្យមួយនេះ ត្រូវបានប្រើប្រាស់ជាញឹកញាប់ ដោយពាក្យ ស្លោកចិនដែលគេប្រើប្រាស់ប្រចាំថ្ងៃនោះ។ ឥឡូវនេះ ខ្ញុំសួរបន្តទៅទៀត ដោយដកស្រង់នូវអ្វីដែលលោក និយាយកាលពីថ្ងៃទី២ កាលពីថ្ងៃសុក្រ គឺម៉ោង១០:៥៨ នៅក្នុងតុលាការនេះ គឺមានពាក្យស្លោកមួយ លោកនិយាយថា “ប្រសិនបើពាក្យស្លោកនេះ <ជាការពិតមែន សំណួរ>គឺថាតើវាបង្កើតឡើងដោយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បដិវត្តន៍ ឬក៏វាគឺជាការស្រមើលស្រមៃរបស់បុគ្គលមួយចំនួនតូច"។ <ដូច្នេះ ក្រោយពីបានស្តាប់>សម្តីដែលលោកនិយាយ ខ្ញុំចង់សួរលោកថា ហេតុអ្វីបានជាលោកមិនព្យាយាម<>ស្វែងរកការគាំទ្រនៅក្នុងឯកសារផ្លូវការ?

**ឆ៖** ឥឡូវនេះ ខ្ញុំសូមប្រគល់សំណួរនេះ ទៅលោកវិញ។ លោកសំណាងហើយ ដែលលោកបានមកការពារក្តី បុគ្គលម្នាក់ដែលមានឋានៈ តួនាទីខ្ពង់ខ្ពស់បំផុត អស្ចារ្យបំផុត<នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ> គឺ នួន ជា ហើយពាក្យមួយចំនួនដែលខ្ញុំបាននិយាយ ដែលថា ខ្ញុំបានប្រើប្រាស់ពាក្យស្លោកហ្នឹង គឺពាក្យស្លោកមួយចំនួនជាពាក្យស្លោកបាលីសំស្រ្កឹត ហើយមានតែមនុស្សដែលមានចំណេះដឹងខ្ពង់ខ្ពស់នោះទេ ដែលបង្កើតបាន។ ដូច្នេះ ហេតុអ្វីក៏លោកមិនងាកទៅសួរកូនក្តីលោកវិញទៅ។ ថាតើគាត់ ឬក៏មនុស្សដែលនៅជុំវិញគាត់នោះ<ដូចជា ទីវ អុល ឬ>អ្នកណាក៏ដោយ ប្រហែលជា ខៀវ សំផន ផងក៏មិនដឹង ថាតើពួកគាត់បានបង្កើតពាក្យស្លោកហ្នឹង<ទេ?> ខ្ញុំមិនដឹងទេ។ ខ្ញុំដឹងថា មនុស្សពីរនាក់ដែល<គេកំពុង>ជំនុំជម្រះនេះ គឺ ខៀវ សំផន ហើយ នួន ជា គាត់ដឹងច្បាស់ ច្បាស់ខ្លាំងណាស់ ប៉ុន្តែលោកប្រាប់ពួកគាត់ឲ្យរក្សាសិទ្ធិនៅស្ងៀមមិនបញ្ចេញមតិយោបល់ទៅវិញ។ ដូច្នេះ ដោយសារតែលោកធ្វើអ៊ីចឹង យើងមិនអាចបន្តទៅមុខទៀតទេ។ ក្នុងនាមជាអ្នកប្រវត្តិវិទូ គឺហាក់វាដូចជាងងឹតឈឹងតែម្តង ហើយយើងគ្រាន់តែអាចធ្វើសម្មតិកម្មមួយ ដើម្បីបង្ហាញថា អ្វីត្រូវ អ្វីខុស គឺមានតែពួកគាត់ទេដែលដឹងច្បាស់។

[១០:០២:៣៥]

**ស៖** ខ្ញុំគិតថានេះជាសំណួរដ៏សាមញ្ញ។ ឥឡូវនេះ ខ្ញុំបន្តទៅមុខទៀតចុះ លោក ឡូកា។ មុនពេលដែលខ្ញុំនិយាយអំពីប្រភពជាបុគ្គលរបស់លោក <ថាតើអ្នកទាំងនោះភាគច្រើនជាជនរងគ្រោះ ឬក៏>ជាកម្មាភិបាល<ខ្លះដែរ>។ ឥឡូវនេះ ខ្ញុំសួរលោកអំពីចំណុចអ៊ីចេះវិញ។ តើលោក<យល់ពីពាក្យថា "ការលម្អៀងក្នុងការគាំទ្រ" មានន័យថាម៉េចទេ?>

**ឆ៖** លោកប្រធាន ស្នើសុំឲ្យមេធាវីសួរសំណួរឡើងវិញ។

**ប្រធានអង្គជំនុំ៖**

សួរសំណួរឡើងវិញ បកប្រែ បកប្រែអត់ទាន់ទេ សំណួររបស់លោកចុងក្រោយអម្បាញ់មិញ លោកមេធាវី រ៉ិចទ័រ កូប៉េ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំគិតថាវាសំណួរពិបាក ឬក៏ពាក្យពិបាកមួយ គឺថា “ការលម្អៀង<>ក្នុងការគាំទ្រ”។ ខ្ញុំសូមពន្យល់អំពីពាក្យនេះបន្តិចទៅចុះ។ ខ្ញុំចង់និយាយអំពីទំនោរក្នុងការបកស្រាយព័ត៌មាន<>ដែល<>វាស្របជាមួយនឹងទ្រឹស្តីដែលមានស្រាប់ <>ជឿជាក់ <និងការជឿជាក់។ ម្យ៉ាងទៀត យើងចម្រាញ់> ព័ត៌មាន<ណា>ដែលផ្ទុយទៅនឹងទស្សនៈដែលមានស្រាប់។ <ដោយសង្ខេប> នេះគឺភាពលម្អៀង<ក្នុងការ>គាំទ្រ<ព័ត៌មាន>។ <ហើយ>ខ្ញុំ<សួរសំណួរនេះទៅលោក ព្រោះ>នៅថ្ងៃទី១<ដែលលោកផ្តល់សក្ខីកម្ម> នៅម៉ោង១១:០០ លោកបានឆ្លើយទៅសំណួរ “ហេតុអ្វីបានជាលោកធ្វើកាស្រាវជ្រាវនេះ?” លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ “ដើម្បីយល់ថា ហេតុអ្វីបានជាមានរបបសាហាវយង់ឃ្នងបែបនេះ”។ និយាយម្យ៉ាងទៀត គឺថាដើម្បីឲ្យច្បាស់ទៅលើសំណួររបស់ខ្ញុំ។ ឥឡូវនេះ ប្រហែលជាយើងយល់ហើយ ថាតើភាពលម្អៀង<ក្នុងការ>គាំទ្រនោះ<មានន័យថាម៉េច។> ថាតើលោកមានភាពលម្អៀងដែរឬទេ នៅពេលដែលលោកចាប់ផ្តើមធ្វើការស្រាវជ្រាវនោះ?

[១០:០៤:៤១]

**ឆ៖** ខ្ញុំមិនដឹងថា តើលោកមកពីផ្នែកណាក្នុងប្រទេសហូឡង់នោះទេ។ ប៉ុន្តែនៅក្នុងប្រទេសបារាំង គឺថាគេបង្រៀនតាំងពីក្មេងមក ថាឲ្យប្រើប្រាស់នូវការគិត វិនិច្ឆ័យ ហើយការដាក់នូវសំណួរអំពីអ្វីៗដែលគេប្រាប់តាមសៀវភៅ <ហើយជាពិសេសអ្នកនយោបាយ។ យើងមិនដែលបញ្ឈប់ការរិះគន់ទេ> យើងរិះគន់ម្តងហើយម្តងទៀតៗ<>។ <ដូច្នេះហើយ នៅពេលដែលខ្ញុំឮថា ឧទាហរណ៍>ថានៅក្នុងរបបខ្មែរក្រហម ខ្មែរក្រហមបំផ្លាញ<អ្វីៗ>ទាំងអស់ គ្មាននៅសល់អ្វីនោះទេ។ <កាលពីថ្ងៃសៅរ៍សប្តាហ៍មុន បុរសជនជាតិបារាំងម្នាក់បាន>សួរ<ខ្ញុំ>ថា “តើការបំផ្លាញនៅទីក្រុងភ្នំពេញមានកម្រិតបែបណា?” ខ្ញុំឆ្លើយថា “តិចតួចទេ សឹងតែគ្មានការបំផ្លាញអ្វីទាំងអស់នៅក្នុងទីក្រុងភ្នំពេញក្នុងរបបកម្ពុជាប្រជាធិតេយ្យ” ហើយគាត់បានឆ្លើយថា គាត់ៗភ្ញាក់ផ្អើល ព្រោះថាការគិតជាទូទៅ គឺថាខ្មែរក្រហមបំផ្លាញសឹងតែទាំងអស់។ ហើយខ្ញុំសូមទោស <នេះគឺជាការបណ្តុះបណ្តាលរបស់ខ្ញុំ។> ខ្ញុំតែងតែឆ្ងល់ មុនពេលដែលមានការកំណត់អំពីអង្គហេតុណាមួយ<>យើងត្រូវការនូវភស្តុតាងឲ្យច្បាស់លាស់មួយ ហោចណាស់ក៏ដកស្រង់ប្រភពឲ្យបានបី<ភាគ>បួន។ នៅពេលដែលខ្ញុំនិយាយអំពីភ្នំពេញ គឺថាខ្ញុំថាពិតហើយ ខ្មែរក្រហមបំផ្លាញតែវិហារគ្រិស្ត ហើយនិងអគារផ្ទះ<>ល្វែង<>មួយចំនួន <បច្ចុប្បន្នយើងឃើញមានអគារខ្ពស់ៗ> ដែលគេកម្ទេចតែប៉ុណ្ណោះ ហើយនិងកម្ទេច<>ធនាគារជាតិ។ យើងមិន

ដឹងថាតើការកម្ទេចអគារធនាគារជាតិហ្នឹង ដោយសារហេតុផលអ្វីនោះទេ។ <ប៉ុន្តែគឺគេកម្ទេចតែប៉ុណ្ណឹងឯង។> ប៉ុនវត្តទាំងអស់នៅទីក្រុងភ្នំពេញ គឺនៅស្អាត អត់មានការខ្ទេចទេ។ វត្តនៅសៀមរាបក៏ដូចគ្នា ហើយខ្មែរក្រហមកម្ទេចវត្តតិចតួចទេ។ <ប៉ុន្តែវាត្រូវបានគេនិយាយរំឭកម្ដងហើយម្ដងទៀត ហើយរបប>សាធារណរដ្ឋ<ប្រជាមានិត>កម្ពុជា <ក៏បានរំឭកថា ព្រះសង្ឃរាប់ពាន់អង្គត្រូវបានគេធ្វើគុត។> អត់ទេ <ព្រះសង្ឃ>បន្តិចបន្តិចទេ<ដែលត្រូវបានគេធ្វើគុត> គឺគ្រាន់តែផ្សឹកលោក ប៉ុន្តែអត់មានសម្លាប់ ឬក៏ធ្វើគុតលោកច្រើននោះទេ។

[១០:០៦:៥៧]

អ៊ីចឹងមានន័យថាប្រទេសកម្ពុជាមិនបានឆ្លងកាត់បដិវត្តន៍វប្បធម៌នោះទេ <អត់មានឧស្សាហកម្មនោះទេ>? អត់ទេ ខ្ញុំឆ្លើយថាអត់ទេ។ ខ្មែរក្រហម កែសម្រួលទាំងអស់ ហើយបង្កើត<>ថ្មីទាំងអស់។ គឺថាមានការប្រែប្រួលទាំងអស់ គឺថាមានរោងចក្រកៅស៊ូនៅតាខ្មៅដំណើរការពេញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយពេលវៀតណាមចូលមកកាន់កាប់ គឺគេបិទរោងចក្រកៅស៊ូនេះ។ ដូច្នេះប្រាកដណាស់ <ខ្ញុំគិត>ថា ខ្មែរក្រហមបានប្រព្រឹត្តបទល្មើសជាច្រើន ហើយខ្ញុំខឹងយ៉ាង<ខ្លាំង>នៅពេលដែលខ្ញុំឮថា ពួកគេត្រូវបានចោទប្រកាន់ថាមានការប្រព្រឹត្តល្មើស ដែលគេមិនបានធ្វើឡើង។

**ស៖** ខ្ញុំគិតថាលោកបានឆ្លើយជាទូទៅហើយ ប៉ុន្តែតើលោកអាចពន្យល់បានទេ ប្រាប់អង្គជំនុំជម្រះទាក់ទងទៅនឹងការស៊ើបអង្កេត នៅក្នុងការសរសេរអត្ថបទរបស់លោក ដែលថាលោកព្យាយាមលុបបំបាត់នូវការលម្អៀង ដើម្បីគាំទ្រដល់ខ្លួនលោកនោះ។ <តើលោកបានធ្វើអ្វីខ្លះ ដើម្បីឱ្យប្រាកដ>ថា <>ភស្តុតាង ឬក៏ដូចជាព័ត៌មានដែលផ្ដល់ដល់លោកហ្នឹង គឺវា<មានភាពចាំបាច់>គាំទ្រ<ដល់លោក> គឺថាលោកមិនមែនធ្វើឡើងដើម្បីគ្រាន់តែគាំទ្រទៅដល់ការយល់ឃើញរបស់លោកនោះ<>?

[១០:០៨:២២]

**ឆ៖** ខ្ញុំផ្ដល់ឧទាហរណ៍មួយទៀត គឺការរំលោភ។ ខ្ញុំគិតថាតុលាការនេះបានចាត់ទុកការរំលោភផ្លូវភេទគឺជាឧក្រិដ្ឋកម្មមួយដែលតុលាការត្រូវជំនុំជម្រះ។ ខ្ញុំគិតថាវាចម្លែកបន្តិច ព្រោះថាក្នុងវិធានទី៦នៃក្រមសីលធម៌<របស់បក្ស> គឺថា<បានហាមឃាត់យ៉ាងដាច់ខាត>មិន<>ឱ្យប៉ះពាល់ស្ត្រីនោះទេ។ ខ្ញុំគិតថាការរំលោភបំពាន រំលោភផ្លូវភេទ ត្រូវបានគេគ្រប់គ្រងតឹងរ៉ឹងនៅក្នុងរបបនោះ ក៏ដូចជានៅក្នុងរបបនានានៅក្នុងប្រទេសកម្ពុជារហូតមកដល់បច្ចុប្បន្ននេះ ក៏គេគ្រប់គ្រងឱ្យបានតឹងរ៉ឹងដែរ ប៉ុន្តែនៅពេលដែលខ្ញុំពិនិត្យមើលទៅលើកំណត់ត្រាស្រាវជ្រាវរបស់ខ្ញុំ គឺខ្ញុំឃើញថានៅតំបន់ជាច្រើន គឺថាប្រហែលជា

១០ភាគរយនៃជនរងគ្រោះនៅក្នុងពន្ធនាគារ គឺ១០ភាគរយជាស្ត្រី និង៩០ភាគរយជាបុរស គឺថាខ្ញុំរកឃើញថា ស្ត្រីមុនពេលគេសម្លាប់ហ្នឹងនៅខាង បូព៌ា នៅក្រឡាញ់ នៅបាត់ដំបង ពួកគាត់គឺស្ត្រីទាំងអស់ហ្នឹង មុនពេលដែលគេសម្លាប់ គឺត្រូវបានគេរំលោភផ្លូវភេទ គឺគេរំលោភ<បូក>។ ដូច្នេះភាពលម្អៀងរបស់ខ្ញុំ គឺខ្ញុំមានភាពលម្អៀងមែនថា ការរំលោភផ្លូវភេទ គឺជារឿង ជាករណីលើកលែងមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រហែលជាខ្ញុំខុស ប៉ុន្តែវាគឺជាការពិតដែលកើតឡើងជាទូទៅ។ ដូច្នេះ<វាផ្ទុយនឹងអ្វីដែល>ខ្ញុំ<បាននិយាយពីខាងដើម>ថា ឧក្រិដ្ឋកម្មដែលមិន<>បានធ្វើឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ គឺជាឧក្រិដ្ឋកម្មដែលធ្វើឡើងជាញឹកញាប់។ ខ្ញុំសង្ឃឹមថា ខ្ញុំមិនមាននូវគំនិតដែលជុះជាប់នៅក្នុងខ្លួនខ្ញុំតាំងពីយូរណាស់មកហើយនោះទេ <ហើយខ្ញុំត្រៀមខ្លួនផ្លាស់ប្ដូរការសន្និដ្ឋានរបស់ខ្ញុំ បើ>មានភស្តុតាងថ្មីបង្ហាញ។ ហើយ<ក្នុងករណីនោះ>ភស្តុតាង<ថ្មីបាន>បង្ហាញនៅក្នុងឆ្នាំ២០១០ នៅពេលដែលខ្ញុំធ្វើការស្រាវជ្រាវជាមួយ <លុច> ប៉ែនែស នៅបាត់ដំបងទៅលើពន្ធនាគារមួយ។ គឺ<អ្នកទោស>ស្ត្រី<នៅពន្ធនាគារនេះ>ត្រូវបានគេរំលោភផ្លូវភេទជាប្រព័ន្ធតែម្តង<មុននឹងគេសម្លាប់>។ <ដូច្នេះ>ហើយ<មេដឹកនាំសម្រេចថា ពេជ្ឈឃាតមិនត្រូវឲ្យមានជាបុរសទៀតទេ គឺឲ្យមានជា>ស្ត្រី<វិញ ដូច្នេះគេ>ស្នើឲ្យ<ប្រធាន>កងចល័តសម្លាប់អ្នកទោស<ស្ត្រី>។

[១០:១១:០០]

**សៈ** សំណួរចុងក្រោយរបស់ខ្ញុំ ប្រហែលជាសំណួរចុងក្រោយទី១ ឬក៏ទី២របស់ខ្ញុំនេះ សម្រាប់ពេលនេះ គឺខ្ញុំចង់សួរថា តើលោកមានពិធីសាស្ត្រស្រាវជ្រាវរបស់លោកដែរឬទេ គឺថាដើម្បីព្យាយាម<> ជៀសឲ្យផុតពីភាពលម្អៀងនេះ? ដូច្នេះហើយខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់បន្តិច គឺខ្ញុំលើកឯកសារ E3/2071, អង់គ្លេសមានលេខ 00087312, ខ្មែរមានលេខ 00233398 និងបារាំងមានលេខ 00282785។ គឺអំពីគុកនៅត្រាំកង់ ដែលលោកនិយាយអំពីមនុស្សម្នាក់ឈ្មោះ អ៊ុក កីឡា បានរៀបរាប់អំពីរឿងរាវ<ដ៏>អាក្រក់អំពីការរំលោភផ្លូវភេទ គឺដូចដែលលោកបានបញ្ជាក់អំមិញអីចឹង។ ហើយលោកបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ការរៀបរាប់របស់ អ៊ុក កីឡា បង្ហាញថាវាមាន<ភាពស្រពិចស្រពិល គួរឲ្យខ្លាច ហើយប្រហែលជាភាគច្រើនជាការស្រមើស្រមៃ ឬ>ព័ត៌មានចចាមអារ៉ាមជាច្រើន ដែលប្រមូលបានក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ុក កីឡា <គឺជាអ្នក>គាំទ្រ<ដ៏ខ្លាំងក្លា និងជាអ្នកទទួលបានប្រយោជន៍ពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយគាត់ចង់ទាក់ទាញចំណាប់អារម្មណ៍>អ្នកស្រាវជ្រាវ<ដែលគ្មានបទពិសោធន៍>។”

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្ញុំគិតថានេះគ្រាន់តែជាឧទាហរណ៍មួយ ដែលជាយន្តការ ដើម្បីការពារកុំឲ្យមានភាពលម្អៀង។ ដូច្នេះខ្ញុំចង់ដឹងថា ហេតុអ្វីបានជាក្នុងករណីហ្នឹង លោកសរសេរអំពីការការពារកុំឲ្យមានលម្អៀងបែបនេះទៅវិញ?

**ឆៈ** <>សូមលោកបញ្ជាក់កាលបរិច្ឆេទបានទេ តើនៅក្នុងឆ្នាំណា ៨០, ៨១ ឬក៏ប៉ុន្មានដែរ?

[១០:១៣:០៤]

**ាសៈ** នៅថ្ងៃ១១ កក្កដា ៨១។

**ឆៈ** នេះគឺជាឆ្នាំទី១ ដែលខ្ញុំចាប់ផ្តើមដំណើរស្រាវជ្រាវរបស់ខ្ញុំ។ ភាគច្រើនខ្ញុំ<ធ្វើការងារ>ជានវិទូ ប៉ុន្តែខ្ញុំមិនមែនជាអ្នកនរវិទូឲ្យពិតប្រាកដនោះទេ។ ខ្ញុំធ្វើការសិក្សាស្រាវជ្រាវ នៅពេលដែលខ្ញុំចាប់ផ្តើមដំណើរការរបស់ខ្ញុំ ហើយខ្ញុំគិតថាមុនកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅខែតុលានោះ គឺថាខ្ញុំចាប់ផ្តើមមុន។ ហើយនៅពេលហ្នឹង គឺប្រទេសកម្ពុជាស្ថិតក្រោមការគ្រប់គ្រងរបស់បក្សប្រជាជនកម្ពុជា។ ហើយខ្ញុំមានសេរីភាពក្នុងការផ្លាស់ទីលំនៅតិចតួចនៅឡើយទេ។ ហើយពេលខ្លះខ្ញុំត្រូវប្រឈមជាមួយ<>សាក្សី ដែលពួកគាត់ទទួលរងនូវការត្រួតត្រាយ៉ាងយូរតាំងពី ៧៩ ដល់ ៨១ គឺទទួលរងការគ្រប់គ្រងដោយរដ្ឋាភិបាលគាំទ្រដោយវៀតណាម។ ហើយខ្ញុំចាំគឺនៅក្នុងស្រុកស្វាយរៀង គឺខ្ញុំជួបនារីម្នាក់ <ហើយខ្ញុំបានបញ្ជាក់នៅក្នុងសៀវភៅរបស់ខ្ញុំ គាត់>និយាយអំពីការឈឺចាប់របស់គាត់ក្នុងរបបខ្មែរក្រហម។ ហើយខ្ញុំប្រាកដណាស់ថាគាត់កែព័ត៌មានរបស់គាត់នោះ <>គឺគាត់មិនបញ្ជាក់ឲ្យបានច្បាស់អំពីព័ត៌មាន <ដូច្នេះហើយ ខ្ញុំបានបញ្ឈប់ការសម្ភាសភ្លាមៗតែម្តង>។ <សហសេវិករបស់>ខ្ញុំ<> ឈ្មោះ <អ៊ីវ> ចាន់ <ដូច>ដែល<ខ្ញុំបានបញ្ជាក់រួចមកហើយ គាត់បានប្រាប់ខ្ញុំថា នៅ>ក្នុងសវនាការ<លើកទី១>ប្រឆាំងបន ប៉ុល ពត, អៀង សារី <មានសាក្សីម្នាក់ ជាស្ត្រី>បានពន្យល់ប្រាប់អំពីការឈឺចាប់<>របស់ប្តីរបស់គាត់។ ហើយ <អ៊ីវ> ចាន់ <បានប្រាប់ខ្ញុំថា>នារីម្នាក់ហ្នឹង គឺគាត់អត់ដែលធ្លាប់រៀបការនោះទេ <ឬនិយាយម្យ៉ាងទៀតថា សក្ខីកម្មរបស់គាត់គឺជាការប្រឌិត>។ ដូច្នេះ ខ្ញុំសង្ស័យមែនទែន ហើយខ្ញុំមានការប្រុងប្រយ័ត្ន ព្រោះថា<នៅ>ពេល<នោះ> យើងចាំបាច់ត្រូវចូលទៅរាយ-ការណ៍នៅនាយកដ្ឋាន<>ព័ត៌មាន <និង>វប្បធម៌<ជាមុនសិន នៅពេលដែលយើងទៅដល់ស្រុកណាមួយ> ហើយយើងត្រូវជួបពួកគាត់ ដើម្បីពួកគាត់អាចបង្ហាញសាក្សីឲ្យយើងទៅជួបសម្ភាស។ ហើយសាក្សីមួយចំនួន<-- ខ្ញុំមិនប្រាកដថា ខ្ញុំបានស្តាប់នោះទេ។> សាក្សីខ្លះ ជាសាក្សីត្រឹមត្រូវ គឺជាសាក្សីដែលមិនទទួលបានការបង្រៀនដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានោះទេ ប៉ុន្តែមានសាក្សីខ្លះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៀត ខ្ញុំសង្ស័យអំពីចម្លើយរបស់គាត់ <ហើយខ្ញុំបានសម្តែងឲ្យឃើញនូវការសង្ស័យរបស់ខ្ញុំ។ ហើយជាលំដាប់បន្តច្រើនឆ្នាំមកទៀត ខ្ញុំអាចធ្វើដំណើរដោយសេរីជាងមុន>។ ហេតុដូច្នេះហើយ ខ្ញុំមិនពឹងផ្អែកច្រើនទៅលើអាជ្ញាធរក្នុងស្រុកនោះឡើយ។

**ស៖** សំណួរចុងក្រោយសម្រាប់ពេលនេះ មុនពេលឈប់សម្រាកលោកប្រធាន។ ខ្ញុំស្តាប់ឮអ្វីដែលលោកនិយាយ ប៉ុន្តែខ្ញុំចង់ដឹងថា តើយើងធ្វើយ៉ាងម៉េច ដើម្បីអាចត្រួតពិនិត្យទៅលើភាពត្រឹមត្រូវឬក៏តម្លៃនៃភស្តុតាងរបស់ឯកសារលោកនោះ? តើយើងធ្វើយ៉ាងម៉េចទើបអាចត្រួតពិនិត្យបានទៅលើចំណុចនេះ?

**ឆ៖** ងាយមែនទែន។ មេធាវី ក៏ដូចជាប្រវត្តិវិទូ អាចធ្វើការប្រៀបធៀបជាមួយប្រភពផ្សេងទៀត គឺប៉ុណ្ណឹងឯង គ្មានអីលំបាកសោះ។

[១០:១៦:៤៦]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះ ប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់ និងសែសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីជំនាញរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់ និងសែសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៧ នាទី ដល់ម៉ោង ១០:៤១ នាទី)*

[១០:៤១:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និង ផ្តល់វេទិកាជូនទីសហមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

01344483



**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ឡូកា នៅថ្ងៃទី២ នៃការផ្តល់សក្ខីកម្មរបស់លោកនៅម៉ោង ០៩:០៧ លោកឆ្លើយថា <សាក្សីដែល>លោកបាននិយាយ<ជាមួយ គឺជា> "<>ជនរងគ្រោះ<ដំបូង និងសំខាន់>"។ តើលោកអាចផ្តល់ចំនួនត្រួសៗបានទេថា ជនរងគ្រោះ -- សម្ភាសជាមួយជនរងគ្រោះនុ៎ង គឺប៉ុន្មានប្រហែលជាប៉ុន្មានភាគរយ? ហើយក្នុងចំណោមនេះ តើលោកមានសម្ភាសកម្មាភិបាលខ្មែរក្រហមនុ៎ងប្រហែលជាប៉ុន្មាននាក់?

[១០:៤២:២៩]

**លោក ហង់រី ឡូកា៖**

**ឆ៖** ខ្ញុំសូមទោសលោកមេធាវី ខ្ញុំមិនអាចឆ្លើយសំណួរលោកបានឱ្យបានច្បាស់លាស់បានទេ។ ដោយសារតែខ្ញុំពេលនោះ គឺថាសម្ភាសតែ<>ផ្នែកដ៏ខ្មៅងងឹត<នៃរបបកម្ពុជាប្រជាធិបតេយ្យ> គឺនិយាយអំពីគុក <អំពីកន្លែងឃុំឃាំង។ ហើយពិតប្រាកដណាស់ គឺខ្ញុំពិតជាបានជួបសន្ទនាជាមួយជនរងគ្រោះ ហើយខ្ញុំក៏>មានសំណាងល្អបំផុតហើយ ដែលបានជួបសម្ភាសជាមួយនឹងអតីតកម្មាភិបាលខ្មែរក្រហមផងដែរ។ ប៉ុន្តែលោកត្រូវ<ដឹងថា បន្ទាត់ព្រំដែន>រវាងជនរងគ្រោះ ហើយនិងជនដៃដល់នៅក្នុងរបបខ្មែរក្រហម<គឺតូចចង្អៀតខ្លាំងណាស់។> ដូចខ្ញុំបានឆ្លើយហើយ ថាជនដៃដល់ខ្លួនឯងហ្នឹង ក៏ជាជនរងគ្រោះនៃរបបនោះដែរ ជាញឹកញាប់នោះ។ <ហើយវាមិនងាយស្រួលទេ> ក្នុងចំណោមកម្មាភិបាល ឬក៏កងទ័ព ឬក៏ជនស៊ីវិល <>គឺថាយើងមានជនរងគ្រោះច្រើនមែនទែន។ បើសិនជា <ពួកគេ>ទាំងអស់នេះមិនមែនជាជនរងគ្រោះដោយផ្ទាល់ ក៏គេមានសាច់ញាតិជាជនរងគ្រោះផងដែរ។ <ដូច្នេះហើយដំបូងគេបង្អស់ ភាគច្រើននៃ>អ្នកដែលខ្ញុំសម្ភាសនោះ គឺថាជាជនរងគ្រោះហើយ ក៏ប៉ុន្តែអ្នកណាក៏ដោយគ្រប់ៗគ្នាទាំងអស់ក្នុងរបបនោះ គឺជាជនរងគ្រោះហើយ។ ហើយខ្ញុំស្គាល់អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនដែល <ជីវិតរបស់ពួកគេ>គឺថាត្រូវបានគេកម្ទេចទាំងស្រុង<តែម្តង ដោយសារតែបទពិសោធន៍នៅក្នុងរបបនោះ>។

**ស៖** ខ្ញុំព្យាយាមសាកសួរតាមរបៀបផ្សេង។ ខ្ញុំបានប៉ាន់ប្រមាណចំនួនប្រជាជនដែលលោកបានសម្ភាសនោះទៅ គឺមានចំនួនប្រហែលជា ៣៦៦នាក់ ដែល<យើង>បានកំណត់អត្តសញ្ញាណ<នៅក្នុង

ការបោះពុម្ពរបស់លោក>។ តើក្នុងចំណោម ៣៦៦នាក់នេះ មានប៉ុន្មានជាកម្មាភិបាលខ្មែរក្រហម <ប៉ុន្មាននាក់?> មួយ, ប្រាំ, ១០នាក់ ឬក៏យ៉ាងណា? <តើមាន>កម្មាភិបាលខ្មែរក្រហម<ប៉ុន្មាននាក់ដែលមានការ>យល់<ដឹង>អំពីដំណើរការខាងក្នុងនៃបណ្ដាគុកទាំងអស់នោះ?

[១០:៤៤:៥៦]

**ឆ៖** ដំបូងខ្ញុំសូមថ្លែងអំណរគុណលោកសិន លោកមេធាវី ពីព្រោះថា ខ្ញុំមិនដែលបានរាប់ចំនួនទេ។ <ដូច្នេះខ្ញុំគិតថា តួលេខ>លោករាប់ទៅឃើញ៣៦៦នាក់<>នោះ<គឺមានប្រយោជន៍>។ ពេលខ្ញុំធ្វើការស្រាវជ្រាវជាមួយលោក ប៉ែនែស <នៅឆ្នាំ២០១០> ខ្ញុំ<មានសាក្សីមួយចំនួនថែមទៀត ដែលខ្ញុំមិនបានផ្ដល់ឲ្យតុលាការ។> ជាការពិតហើយដែលថា ខ្ញុំពេញចិត្តក្នុងការស្វែងរកជនដៃដល់ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ក៏ប៉ុន្តែជាអកុសល គឺថា មានឱកាសតិចតួចមែនទែនដែលជនដៃដល់នេះហ៊ានមកឆ្លើយ។ ចាប់តាំងពីពេលដែលខ្ញុំបោះពុម្ពផ្សាយសុភាសិតទាំងអស់នេះរួចមក។ <ខ្ញុំគិតថា ខ្ញុំក៏ដូចជា> ហ្វីលីព ស្បូត <ដែល>ជាអ្នកសិក្សាស្រាវជ្រាវម្នាក់ដែលបានគិតថា ជនដៃដល់ក៏ជាមនុស្សហើយជនដៃដល់ក៏គេមាន គេហៅថាទាំងផ្នែកភ្លឺ ផ្នែក<ល្អរបស់ពួកគេដែរ ហើយខ្ញុំតែងតែចាត់ទុកពួកគេថា>ជាមនុស្សដែរ។ <ហើយចាប់តាំងពីពេលនោះមក ខ្ញុំបានសម្ភាសពួកគេមួយចំនួនដែរ។ ពេលខ្លះ> គេបានផ្ដល់ឈ្មោះអតីតកម្មាភិបាលក្រហមមកឲ្យខ្ញុំដែរ។ បុគ្គលទាំងនោះគឺថា មិនចង់និយាយជាមួយខ្ញុំទេ គេចខ្លួនទៅណាបាត់អស់ទៅ។ ខ្ញុំតាមការពិតទៅមានបំណងចង់សម្ភាសអតីតកម្មាភិបាលខ្មែរក្រហមឲ្យបានច្រើនណាស់ <ប៉ុន្តែវាពិបាកខ្លាំងណាស់>។

**ស៖** មុននឹងខ្ញុំចូលនិយាយទៅដល់កម្មាភិបាលទាំងនោះ សំណួរខ្ញុំសួរថាតើ លោកធ្វើម៉េចធានាឲ្យបានដឹងច្បាស់ថា អ្នកដែលឆ្លើយជាមួយលោកគឺជាជនរងគ្រោះ ហើយជាតំណាងឲ្យចំនួនប្រជាជនដែលបានរស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យនោះទៅបាន?

**ឆ៖** មិនជាចាំបាច់ អ្នកនោះ គឺថាជាអ្នកតំណាងឲ្យប្រជាជនដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។ គោលបំណងខ្ញុំសម្ភាសអំពីគុក<ខ្មែរក្រហម>។ អ៊ីចឹងខ្ញុំចង់ជួបសាក្សី<បីប្រភេទ ទី១គឺជនរងគ្រោះ គឺអ្នកដែលខ្លួនគេផ្ទាល់នោះធ្លាប់>ជាអ្នកទោស ប៉ុន្តែ<ដូចលោកដឹងហើយ គឺមានជនរងគ្រោះប្រភេទ>នេះតិចណាស់ ដោយសារភាគច្រើនត្រូវគេសម្លាប់ចោលបាត់អស់ទៅហើយ។ <ទី២គឺ>អ្នកដែល<បានរស់>នៅ<ជុំវិញ>គុក ឬក៏ជិតគុក គេបានប្រាប់ខ្ញុំអំពីរបៀបគេទទួលអ្នកទោសចូលទៅក្នុងគុក និងគេបញ្ចេញមកខាងក្រៅគុក <ប្រាប់អំពីអគារ និងការបង្កើតវាឡើងជាដើម។ ហើយទី៣

គឺ>ជាយោធា ឬក៏ជាកម្មាភិបាលខ្មែរក្រហម<ខ្លួនឯងតែម្តង>។ ដូច្នេះ ខ្ញុំយល់ឃើញថា វាមិនចាំបាច់ថា ប្រជាជននេះ ត្រូវតែជាតំណាងឲ្យប្រជាជនទាំងមូល ដែលរស់នៅក្នុងរបបនោះទេ។

**សៈ** ខ្ញុំសូមសួរតាមក្រោយ អ្វីដែលលោកបានឆ្លើយ។ តើលោកធ្វើដូចម្តេច បានជាលោកដឹងថា អ្នកទោសភាគច្រើនបំផុតនោះ គឺត្រូវបានសម្លាប់ចោលបាត់អស់ទៅហើយ? លោកមានទិន្នន័យណាជាក់លាក់ដែរទេ ដែលលោកយកមកអះអាងបែបនេះ ឬក៏មានប្រជាជនណាម្នាក់ប្រាប់លោកអំពីរឿងនេះនៅពេលដែលលោកសម្ភាសពួកគាត់?

[១០:៤៨:៣០]

**ឆះ** <>បើនិយាយអំពីការរាប់អំពីចំនួននេះ <ខ្ញុំសូម>និយាយអំពី<>ការ<>វិនិច្ឆ័យអំពីភាពគួរឲ្យជឿទុកចិត្តបានទៅលើអ្នកដែលខ្ញុំត្រូវសម្ភាសនោះ <ដែល>ខ្ញុំយល់ឃើញថា<នេះជាមូលដ្ឋានមួយនៃការសម្ភាសប្រជាជន។> លោក<សួរសំណួរដែលលោកមានចម្លើយរួចហើយ លោក>ដឹងចម្លើយហើយ គឺ<សួរដើម្បី>ចង់<ដឹងថា>ប្រជាជនប្រាប់<>ការពិតទេ។ <ខ្ញុំតែងតែធ្វើដូច្នេះ។> បើនិយាយអំពីចំនួនវិញ ខ្ញុំមិនយល់ស្របជាមួយនឹងការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមាននិន្នាការគឺថាបំប៉ោងតួលេខ ចំនួនជនរងគ្រោះ ពីព្រោះប្រភពចម្បងរបស់គេ គឺអាជ្ញាធរសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលតោងតែចង់បំប៉ោងតួលេខចំនួនជនរងគ្រោះ<ថា មួយភាគបី ឬក៏ថា មានជនរងគ្រោះបីលាននាក់ ជាជាងនិយាយថា មានប្រហែលពីរលាននាក់>។ <ដោយសារតែច្រើន>ឆ្នាំ<កន្លងផុតទៅ> គឺថា <ប្រជាជនកាន់តែចង់ធ្វើឲ្យបទពិសោធក្នុងរបបនោះកាន់តែធ្ងន់ធ្ងរឡើង> ហើយ<ដោយចេតនា ឬអចេតនា គេចង់ធ្វើឲ្យព្រឹត្តិការណ៍នោះកាន់តែរន្ធត់ ហើយធ្វើឲ្យ>ចំនួន<ជនរងគ្រោះ>កាន់តែច្រើនឡើង។ <នេះជាបញ្ហាមួយទៀត។> ដូច្នេះ <វិធីសាស្ត្ររបស់>ខ្ញុំ<ក្នុង>ការ<>ប៉ាន់ប្រមាណចំនួននេះ គឺទី១ និយាយអំពីអំឡុងពេលនៃអត្ថិភាពរបស់គុកទាំងនោះ <ថាតើវាត្រូវបានបង្កើតឡើង>តាំងពីមុន៧៥ <ឬក៏>ក្រោយ៧៥ ថាតើគុកនីមួយៗ វាមានអត្ថិភាព៦ខែ ១ឆ្នាំ ២ឆ្នាំ ៣ឆ្នាំ ឬក៏យ៉ាងណា ក៏ដូចជាគុកក្រាំងតាចាន់ជាដើម។ នេះ ដំបូងគឺត្រូវនិយាយអំពីអំឡុងពេលដែលគុកនោះមានអត្ថិភាពនោះ។ ហើយទី២ និយាយអំពីចំនួននៃការចាប់ខ្លួន <ចំនួនមនុស្សដែលគេនាំទៅគុកនោះ បើគេមិននាំទៅជារៀងរាល់ថ្ងៃទេ យ៉ាងហោចណាស់ក៏រៀងរាល់>សប្តាហ៍ ឬក៏ប្រចាំខែ។ ខ្ញុំបានទទួលព័ត៌មាននេះពីអ្នកដែលរស់នៅជិតៗគុក <ដែលមានគំនិតប្រភេទនេះ>។ <ដូច្នេះហើយ ខ្ញុំអាចគណនា>ចំនួនអ្នកទោសចូល<>ប្រចាំសប្តាហ៍ ឬក៏ប្រចាំខែ <ជាមួយនឹងរយៈពេលនៃការបង្កើតគុកនោះ ដូច្នេះហើយវា>ផ្តល់តួ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

លេខជាការប៉ាន់ប្រមាណ<ពីចំនួន>អ្នកទោសដែលត្រូវគេ<ទៅ>គុកទាំងនោះ។ <ហើយចំពោះចំនួនមនុស្សដែលគេបានសម្លាប់នៅទីនោះ> ខ្ញុំព្យាយាមធ្វើការប៉ាន់ប្រមាណតួលេខ<អ្នកដែល>ត្រូវបានគេដោះលែងឲ្យរួចខ្លួន ឬក៏រត់គេចចេញពីគុក <ឬក៏ត្រូវបានរំដោះ>។ <ហើយជាការពិតណាស់ ចំនួននេះខ្ញុំអាចដឹងបាន> ដោយសារសាក្សីដែលខ្ញុំសម្ភាស ដូចជា មឿង សុន នេះ គឺត្រូវបានគេដោះលែង ហើយអ្នកទោសខ្លះទៀត គឺថារត់គេចខ្លួនចេញពីគុកទាំងនោះ ដោយខ្លួនឯង។

[១០:៥១:២៩]

អ៊ីចឹង<ខ្ញុំគិតថាមានភាពខុសគ្នាខ្លាំងណាស់រវាង>អ្នកដែលគេនាំចូលទៅក្នុងគុកនីមួយៗ ហើយ<>ចំនួនដែលគេដោះលែង ឬក៏រត់គេចខ្លួន។ <ហើយបើលោកដើរមើលជុំវិញប្រទេសកម្ពុជា អ្នកដែលបានឆ្លងកាត់គុកទាំងអស់នោះគឺខុសគ្នាខ្លាំងណាស់។ និយាយម្យ៉ាងទៀតថាអ្នករស់>រានមានជីវិត<មានតិចតួចណាស់ ហើយភាគច្រើនបំផុតគឺស្លាប់នៅក្នុងគុកទាំងអស់នោះ>។

**ស៖** ដូចដែលខ្ញុំបានយកមកសួរនៅមុនពេលឈប់សម្រាក។ យើងខ្ញុំចង់ព្យាយាមស្វែងយល់ឲ្យបានច្បាស់ និងផ្ទៀងផ្ទាត់នូវអ្វីដែលលោកបានឆ្លើយ។ អ៊ីចឹងសំណួរខ្ញុំងាយទេ សំណួរខ្ញុំសួរថា តើលោកបានប្រភពមកពីណា ដែលលោកថាអ្នកទោសភាគច្រើនហ្នឹង ត្រូវបានគេសម្លាប់ចោលអស់ហើយ? តាមដែលខ្ញុំឮ ឬក៏ដូចជាតាមរយៈភស្តុតាងមួយចំនួន គឺថាយើងបានរកឃើញថា លោកគឺថាបានចុះទៅមើលគុកតិចជាងមួយភាគ<បួន>នៅតាមបណ្តាស្រុកនានា ហើយមិនមានបណ្ណសារតម្កល់ឯកសារ<>ទុកទេ <ក្រៅពី>គុកក្រាំងតាចាន់ <និងស-២១។> តើលោកធ្វើការសន្និដ្ឋានដ៏វែងឆ្ងាយបែបនេះបានដោយរបៀបណា លោកមានប្រភពអីយកមកសំអាង?

**ឆ៖** លោកមានតួលេខពីចំនួនមនុស្សដែលខ្ញុំសម្ភាស<៣៦៦នាក់>។ ឥឡូវ លោកបានតួលេខថ្មីមកទៀតហើយ។ លោកថា ខ្ញុំបានចូលទៅ -- គឺថាខ្ញុំបានស្រាវជ្រាវតែគុក បានតែមួយភាគ<បួន>នៃបណ្តាគុកតាមស្រុកហ្នឹង។ <បើសិនជាបុគ្គលម្នាក់បានទៅមើលគុកដល់ទៅមួយភាគបួន គឺមានន័យថាច្រើនណាស់ហើយ ហើយវាជាគំរូសំខាន់សម្រាប់គុកទាំងអស់នោះ។> ខ្ញុំយល់ថា ខ្ញុំបានពិនិត្យ<គុក>ទាំងនោះច្រើន<ជាងនោះ ប៉ុន្តែវាត្រូវការពិនិត្យមើលសិន>។

**ស៖** <លោកថាតិចជាងមួយភាគបួន> អ៊ីចឹង តាមការឯកសារ <E3/2811> គឺថាលោក<និយាយថា> បានទៅស្រាវជ្រាវគុកនោះ តែមួយភាគ<បួន>ទេ មែនទេ?

[១០:៥៣:៤៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំអត់ដែលបានរាប់ទេលោកមេធាវី។ <ខ្ញុំគិតថា នោះប្រហែលជា>តាមការប៉ាន់ប្រមាណ <ប៉ុណ្ណោះ។ ខ្ញុំបានពិនិត្យមើលឯកសារនោះប៉ុន្មានសប្តាហ៍កន្លងមកនេះ ឃើញថាខ្ញុំបាន>ទៅកាន់តំបន់ទាំងអស់នៅភូមិភាគបូព៌ា ហើយ<សម្រាប់ខ្ញុំ វាហាក់ដូចជាថា ខ្ញុំពិតជាបាន>ការសិក្សាស្រាវជ្រាវ<> គ្របដណ្តប់ទៅដល់គុកដទៃទៀត<>ជាច្រើនផងដែរ។ ប៉ុន្តែនេះ មិនមែនជាបញ្ហាទេ បញ្ហាចម្បងនោះគឺថា លោកថាគុកចំនួន៥០ គឺថា ឬក៏លើស៥០បន្តិចបន្តួច ស៊ើបអង្កេតទៅ គឺថាវាមានភាពស៊ីចង្វាក់គ្នា។ បើយើងនិយាយអំពីអក្សរសាស្ត្រ<ទាក់ទងនឹង>កម្ពុជាប្រជាធិបតេយ្យទាំងមូលនោះ តាមសំណេររបស់គេនិយាយថា ប្រជាជនជាច្រើននេះ គឺថា<ត្រូវ>បាន<គេ>សម្លាប់ចោល <ឬក៏ស្លាប់>នៅក្នុងរបបនោះ។

ចំណោទបញ្ហាចម្បង ថាតើអ្នក<ខ្លះពិតជា>ត្រូវបានសម្លាប់<> ឬក៏<ពួកគេបានឆ្លងកាត់គុកទាំងនោះ>។ នេះការមន្ទិលសង្ស័យ គឺនៅត្រង់នេះឯង <ទោះបីជាយើងអាចប្រាប់>តួលេខ<ត្រឹមត្រូវក៏ដោយ។ តើធ្វើម៉េចលោកដឹងថា>អ្នកស្លាប់<ទាំង>អស់នោះ<មាន>២លាននាក់<>? <តើចំនួនអ្នកស្លាប់ដោយសារជំងឺ និងការអត់ឃ្លាន<មានប៉ុន្មានភាគរយ?> ប៉ុន្មាននាក់ត្រូវបានសម្លាប់ចោលដោយមិនមានការជំនុំជម្រះអីត្រឹមត្រូវ? <តើមានប៉ុន្មាននាក់ស្លាប់នៅក្នុងគុក? យើងគ្រាន់តែអាចធ្វើការប៉ាន់ស្មានតែប៉ុណ្ណោះ>។ <នៅពេលដែល ម៉ារេក ស្លីវិនស្គី បានមក ខ្ញុំគិតថា> ខ្ញុំមិនមែនជាអ្នកប្រជាសាស្ត្រ<ទេ។> ប៉ុន្តែគាត់បានផ្តល់តួលេខដោយរួមទាំង<មធ្យោបាយ>សម្លាប់<មនុស្សទៀតផង>។ ប៉ុន្តែខ្ញុំក៏ឆ្ងល់ដែរថា តើគាត់ស្វែងរកតួលេខបានដោយរបៀបណា ដោយសារការសម្លាប់គឺជារឿងមួយសម្ងាត់ណាស់ គេសម្លាប់តែនៅក្នុងពេលយប់ សម្លាប់នៅយប់ងងឹត សម្លាប់នៅក្នុងព្រៃ ឬក៏យ៉ាងហោចណាស់ក៏ទៅសម្លាប់កន្លែងណាដែលមិនមានមនុស្សរស់នៅដែរ។

**ស៖** លោកប្រធាន ពាក្យដែលខ្ញុំថាតិចជាងមួយភាគ<បួន>គឺ <E3/2811>, <ERN ជាភាសាអង់គ្លេសគឺ 00394583> ខ្មែរ 00822562, បារាំង 00796261។ លោក ឡូកា នៅម៉ោង <១១:៣៥> ថ្ងៃទី១ លោកថាប្រភពរបស់លោក សុំដកស្រង់៖ “គឺព័ត៌មាននេះបានពីការសម្ភាសរបស់ខ្ញុំផ្ទាល់” បញ្ចប់ការដកស្រង់។ ហើយលោកក៏បានឆ្លើយផងដែរ នៅម៉ោង<១៣:៥៨> នៅថ្ងៃទី១ នៃផ្តល់សក្ខីកម្ម សុំដកស្រង់៖ “ខ្ញុំមិនបានចូលទៅពិនិត្យបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា <ឬស-២១>ទេ ពាក់ព័ន្ធទៅនឹងការចងក្រងសុភាសិតទាំងអស់នេះ។” ហើយលោកក៏ត្រូវបានគេសួរសំណួរមួយចំនួនរួចមកហើយអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឆ្លើយទៅនឹងសំណួររបស់ខ្ញុំ លោកថាមជ្ឈ-

មណ្ឌលឯកសារកម្ពុជាហ្នឹងគឺបំប៉ោងតួលេខហ្នឹងផងដែរ។ តើវាត្រឹមត្រូវដែរទេ បើខ្ញុំនិយាយថា រវាងលោក ហើយនិងមជ្ឈមណ្ឌលឯកសារកម្ពុជានេះ គឺថាលោកអត់មានទំនាក់ទំនងល្អជាមួយនឹងគ្នាទេ។ បើខ្ញុំនិយាយអ៊ីចឹង លោកយល់យ៉ាងម៉េចដែរ?

[១០:៥៧:៤០]

**ឆៈ** ពាក់ព័ន្ធនឹងការប្រមូលចងក្រងសុភាសិតរបស់ខ្ញុំនេះគឺថា ខ្ញុំដំបូងគឺខ្ញុំចង់ប្រមូលសុភាសិតហ្នឹង ដោយ -- ដែលគេប្រើប្រាស់រាត់រាយនៅតាមសហករណ៍នានា។ មិនមែនសុភាសិតដែលលោកអាចរកបាន ស្ដាប់ឮនៅតាមវិទ្យុទេ ពីព្រោះគេដឹងហើយ ប៊ី.ប៊ី.ស៊ី, អេហ្វ.ប៊ី.អាយ.អេហ្វ <មិន> បានកត់ត្រាសុភាសិតទាំងអស់នេះ<ទេ> ក្រៅពីសុភាសិត<តិចតួច>ដែល<>គេ<>ផ្សាយ<សម្រាប់សាធារណជន។ ដូច្នេះហើយ យើងមិនឃើញមានសុភាសិតនៅក្នុង អេហ្វ.ប៊ី.អាយ.អេហ្វ ទេ>។ ខ្ញុំមិនបានពិនិត្យមើលទៅតាមសំណេររបស់ខ្មែរក្រហមនោះទេ ដូចជាទស្សនាវដ្ដីទង់បដិវត្តន៍ ឬក៏ទស្សនាវដ្ដីយុវជនបដិវត្តន៍។ ខ្ញុំមិនបានមើលបណ្ណសារ ឬក៏ឯកសារពីស-២១។ ខ្ញុំក៏មិនបានចូលទៅមើលឯកសារនៅបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ អ្វីដែលខ្ញុំចង់ប្រមូលផ្ដាច់មុខតែម្ដងនោះគឺសុភាសិតដែលប្រជាជន ជាពិសេសប្រជាជនដែលពេញវ័យនោះ ដែលគាត់នៅមានការចងចាំនៅពេលនោះ ឬក៏យុវជន យុវនារីដែលមានវ័យក្មេងនៅជំនាន់កម្ពុជាប្រជាធិបតេយ្យ ហើយ១០, ១៥ឆ្នាំក្រោយមក ចង់ដឹងថាតើពួកគាត់ចាំអ្វីខ្លះពីសុភាសិតទាំងអស់នោះ? <ដូច្នេះ គឺនៅថ្នាក់មូលដ្ឋាន>។ <នេះ>ហើយ<ជាមូលហេតុ ដូចដែលខ្ញុំនិយាយនៅក្នុងតុលាការនេះអ៊ីចឹងថា> ខ្ញុំ<>មិនបានរាប់បញ្ចូលសុភាសិតដែល<មាននៅ>តាម<ជញ្ជាំង>ស-២១<ទេ>។ <សម្រាប់ខ្ញុំសុភាសិតទាំងនោះដូចជាមិនពិតទេ ហើយម្យ៉ាងទៀត ក៏មិនមាននៅទីនោះដែរ។ ដូច្នេះ>សុភាសិត<>ដែលខ្ញុំប្រមូលបាន<មានតែ>នៅថ្នាក់មូលដ្ឋាន<ប៉ុណ្ណោះ>។

**សៈ** អ្វីដែលលោកឆ្លើយនៅម៉ោង ១១:២៥ នៅថ្ងៃដំបូងពាក់ព័ន្ធទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាបដិសេធមិនទទួលយកសេវាការងាររបស់លោកទេ<ដោយសារលោកជាជនជាតិបារាំង>។ ហើយក្រោយមកលោកនិយាយ<ថា>មជ្ឈមណ្ឌលឯកសារកម្ពុជាគឺថាមិនបានបើកចំហការងាររបស់ខ្លួនទៅដល់សាធារណជននោះទេ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ហេតុអ្វីបានជាលោកគិតថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនពេញ<ចិត្ត>ធ្វើការជាមួយលោក? ហេតុអីបានជាសញ្ជាតិរបស់លោក វាក្លាយទៅជាការរាំងស្ទះមួយឧបសគ្គមួយ ដែលមិន

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

អាចឲ្យលោកធ្វើការជាមួយមជ្ឈមណ្ឌលឯកសារ កម្ពុជាបាន?

**ឆ៖** <ខ្ញុំគិតថា>មជ្ឈមណ្ឌលឯកសារកម្ពុជាគាត់មិន<ចាប់អារម្មណ៍>ភាសាបារាំងទេ។ <តាមដែលខ្ញុំដឹង ពួកគេគ្មានធនធានជាភាសាបារាំងទេ> ហើយមេរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះ ក៏មិនចេះនិយាយភាសាបារាំងទៀត ចេះតែនិយាយភាសាអង់គ្លេស។

[១១:០០:៣៥]

**ស៖** ហើយចុះលោកនិយាយថា មជ្ឈមណ្ឌលឯកសារកម្ពុជានេះ គឺថាមិនបើកចំហការងាររបស់ខ្លួនទៅដល់សាធារណជនទេ។ តើលោកនិយាយហ្នឹង លោកសំអាងលើអ្វី?

**ឆ៖** ខ្ញុំមិនមកធ្វើការវិនិច្ឆ័យអំពីមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ខ្ញុំមកទីនេះ គឺមកផ្ដល់សក្ខីកម្មពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ <និងមេដឹកនាំនៃរបបនោះ>។

**ស៖** ខ្ញុំបន្តទៅមុនទៅទៀតចុះលោក ហង់រី ឡូកា។ លោកក៏បានប្រសាសន៍ហើយ អត្ថបទដែលលោកបោះពុម្ពផ្សាយជាមួយនឹងកាសែតភ្នំពេញប៉ុស្តិ៍ ហើយនៅទីនេះលោកឆ្លើយថា លោកពិចារណាទៅលើសៀវភៅរបស់ ហ្វីលីព ស្សូត។ សូមដកស្រង់ លោកថាជាសៀវភៅមួយដែលសរសេរបានល្អបំផុតអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ <លោកនិយាយដូច្នេះនៅម៉ោង ១១:១៩ និង>នៅម៉ោង ១១:៣២ ថ្ងៃដំបូងនៃការផ្ដល់សក្ខីកម្មនេះ គឺលោកបានឆ្លើយថា “កិច្ចសម្ភាសន៍របស់ ហ្វីលីព ស្សូត នេះ គឺបានសម្ភាសបញ្ញវន្ត កម្មាភិបាលខ្មែរក្រហម និង<សមាជិកបក្សកុម្មុយនីស្តថ្នាក់ខ្ពស់ ច្រើនជាង>អ្នកដទៃទៀត<>” បញ្ចប់ការដកស្រង់។ តើលោកអាចពន្យល់លម្អិត<>បន្តិចបានទេ?

**ឆ៖** ខ្ញុំមានការកោតសរសើរយ៉ាងខ្លាំងចំពោះ ហ្វីលីព ស្សូត។ គាត់មិនមែនជាអ្នកសិក្សាស្រាវជ្រាវទេ ប៉ុន្តែតាមការងារ គាត់គឺជាតំណាងរបស់ ប៊ី.ប៊ី.ស៊ី ហើយគាត់មានការងារនៅប៉ារីសផងដែរ។ ហេតុដូច្នេះហើយ ទើបគាត់អាចសរសេរប្រវត្តិយ៉ាងល្អរបស់អតីតប្រធានាធិបតី ប្រ្ញង់ស្វ័រ មីតតេរ៉ង់ ហើយនៅពេលក្រោយមកទៀត គាត់ផ្ទេរទៅទីក្រុងប៉េកាំង ហើយធ្វើជាអ្នកតំណាង ប៊ី.ប៊ី.ស៊ី នៅប៉េកាំង <ដែលធ្វើឲ្យ>គាត់<អាច>សរសេរប្រវត្តិរូប<>របស់ ម៉ៅ សេទុង <បានយ៉ាងល្អ>។ <ហើយគឺនៅទី>នេះហើយ <ដែល>គាត់ចាប់ផ្ដើមចាប់អារម្មណ៍ពីខ្មែរក្រហម ព្រោះថានៅពេលដែល ប៉ុល ពត ទៅ<ទស្សនកិច្ចនៅ> ប៉េកាំង គឺថាគាត់<>នៅ<ទី>នោះដែរ ហើយគាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារតែប្រទេសដ៏តូចមួយនេះ គឺធ្វើការតាម ដើរតាមមាគ៌ារបស់ ម៉ៅ ហើយគាត់ក៏មានការចាប់អារម្មណ៍។ ហើយ<នេះជាអ្វីដែលខ្ញុំគិតថា នៅដើមឆ្នាំ២០០០ នៅពេលដែល>គាត់បានចូលនិវត្តន៍ពី

ប៊ី.ប៊ី.ស៊ី គាត់<មានពេលវេលាច្រើន ហើយគាត់>ក៏មកប្រទេសនេះ ហើយ<យើង>បានជួប<គ្នា>។ គាត់បានផ្លាស់ប្ដូរការងារពីអ្នកជំនាញ<បារាំង និងអ្នកជំនាញ>ចិន មកជាអ្នកជំនាញកម្ពុជាប្រជាធិបតេយ្យ<យ៉ាងលឿន។> គាត់ជាមនុស្សដែលគេថារៀនឆាប់ចេះ ហើយគាត់<មានវិធីសាស្ត្រ>ដ៏ល្អ ហើយគាត់ជាអ្នកបកប្រែល្អ ហើយគាត់សរសេរបានយ៉ាងល្អ។ គាត់ទៅអមលាំង គឺថាទៅកន្លែងដែលខ្ញុំមិនដែលទៅសោះតែម្ដង។ អមលាំងនេះ ហើយគាត់បានរកឃើញអំពីព័ត៌មានមួយចំនួន<អំពី ម-១៣> ដែលខ្ញុំមិនដែលរកឃើញបាន គឺថាគាត់សកម្មជាងខ្ញុំខ្លាំងណាស់ ទោះបីថាគាត់មកក្រោយ គាត់ជាអ្នកសិក្សាពីខ្មែរក្រោយគេ ប៉ុន្តែគាត់ យើងអាចប្រើពាក្យខ្មែរក្រហមថា គឺគាត់មហាលោតផ្លោះ មហាអស្ចារ្យតែម្ដង។ គាត់ៗអាចធៀបស្មើជាមួយ ដេវីដ ឆេនដ៍ល័រ។

[១១:០៥:១២]

ហើយក្រៅពីនេះទៀត គាត់ទទួលបានព័ត៌មាន ដែលទទួលបានពីពាក្យប្រជាជន<ដែលពាក់ព័ន្ធនឹងរបបនោះ>តែម្ដង <ហើយនិងទទួលបានព័ត៌មានពី>មេដឹកនាំជាន់ខ្ពស់។ ខ្ញុំគិតថាអ៊ីចេះ គឺគាត់បានប្រមូលព័ត៌មានតាំងពី ជួន ប្រសិទ្ធិ ទៀត។ សូម្បីតែតុលាការខ្មែរក្រហមយើងនេះ ក៏មិនបានសម្ភាសជួន ប្រសិទ្ធិ ដែរ ប៉ុន្តែគាត់ទទួលបានព័ត៌មានពី ជួន ប្រសិទ្ធិ។ គឺថាគាត់ជាមនុស្សដែលថាលេចធ្លោជាងគេ។ គឺថា ហ្វីលីព ស្សូត គាត់ជាមនុស្សដែលល្អ ដែលគាត់ផ្ដល់នូវការសម្ភាសជាមួយ ខៀវ សំផន ដែលជាព័ត៌មានដ៏ល្អ គាត់ប្រគល់ឲ្យខ្ញុំផងដែរ។ <ហើយខ្ញុំបានសិក្សាច្រើនពីការសម្ភាសនោះ។> ហើយតាមរយៈការសម្ភាសនេះ<> ទើបខ្ញុំដឹងថាគាត់ជាអ្នកស្រាវជ្រាវល្អ គឺពូកែជាងខ្ញុំខ្លាំង <ព្រោះគាត់បានថតសំឡេង និងបានធ្វើវិភាគព័ត៌មានទាំងអស់>។ ហើយក៏ជាអ្នកដែលធ្វើការងារបានប្រសើរ មានប្រសិទ្ធភាព ជាអ្នកស្រាវជ្រាវខ្ពស់ ហើយប្រកប ហើយជាអ្នកនិពន្ធល្អមែនទែន។

**ស៖** ប្រហែលជាត្រឹមត្រូវមែន ប៉ុន្តែអ្វីដែលខ្ញុំចង់សួរលោក គឺថា ហ្វីលីព ស្សូត បានសម្ភាសជាមួយកម្មាភិបាលខ្មែរក្រហមច្រើន<ជាងអ្នកដទៃទៀត>។ តើផ្អែកទៅលើមូលដ្ឋានអ្វី ដែលថា<>អ្នកដែល<គាត់>បានសម្ភាស <អ្នកដទៃទៀតមិនបានសម្ភាសនោះ>?

**ឆ៖** ខ្ញុំលើកឧទាហរណ៍មួយសាមញ្ញទៅចុះ ខ្ញុំមកសិក្សាអំពីប្រទេសខ្មែរ <ខ្ញុំគិតថា>សន្និសីទ<ទី>មួយ<ដែលខ្ញុំបានចូលរួមគឺ>នៅក្នុងទីក្រុង<ប៉ារីស>--

**ស៖** ខ្ញុំសូមកាត់លោកទៅចុះ លោកឆ្លើយសំណួរតែម្ដងថា តើៗ ហ្វីលីព ស្សូត សម្ភាសអ្នកណាដែលអ្នកដទៃទៀតអត់ដែលបានសម្ភាសនោះ? សូមលោកឆ្លើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:០៦:១៥]

**ឆ៖** មនុស្សដទៃទៀត ដែលខ្ញុំនឹកឃើញនោះ គឺ ដេវីដ ឆេនដ៍ល័រ។ ដេវីដ ឆេនដ៍ល័រ គាត់សរ-សេរប្រវត្តិរូបរបស់ ប៉ុល ពត ដែរ។ នៅពេលដែលខ្ញុំនៅក្នុងសិក្ខាសាលានៅប៉ារីស<នៅទសវត្សរ៍៩០> ហ្នឹង គឺខ្ញុំទៅទីនោះ ហើយជួបជាមួយ ឆេនដ៍ល័រ ហើយគាត់<បានដឹកនាំ>សិក្ខាសាលានៅទីក្រុងប៉ារីស។ <ហើយខ្ញុំបានចូលរួមសិក្ខាសាលារបស់គាត់មួយចំនួន ដើម្បីពង្រីកចំណេះដឹង ឬក៏ថា>ជាអ្នកទើបតែចាប់ផ្ដើមសិក្សាអំពីប្រទេសខ្មែរ ហើយ<នៅពេលនោះ>គាត់បានបង្ហាញអំពីការសរសេរប្រវត្តិរូបរបស់ ប៉ុល ពត។ ខ្ញុំសួរគាត់ថា៖ “លោកធ្លាប់សម្ភាសន៍ ប៉ុល ពត ទេ?” ដល់ ដេវីដ ឆេនដ៍ល័រ មើលមុខមកខ្ញុំហើយភ្ញាក់ផ្អើល ហើយក៏សួរថា៖ “ហ៊ឺ ! សម្ភាស ប៉ុល ពត អេ្ហស? មិនដែលទេ។” <មិនដែលគិតដល់ ព្រោះជនជាតិអាមេរិកាំងមានទំនោរគិតថា ពិភពលោកនេះត្រូវបានបែងចែកផ្នែកល្អ និងផ្នែកអាក្រក់> ដូច្នេះ<> គាត់<>សម្ភាសតែអ្នកដែលល្អ មិន<>សម្ភាសអ្នកដែល<មិន>ល្អនោះឡើយ។ <ប៉ុន្តែនៅពេលជាមួយគ្នានោះ នេត ថាយ័រ ដូចដែលយើងស្គាល់ហើយ គាត់ជាអ្នកកាសែតអាមេរិកាំងបានសម្ភាសជាមួយ ប៉ុល ពត>។ ដូច្នេះ ខ្ញុំចំពោះខ្ញុំៗគិតថា ដើម្បីសរសេរអំពីប្រវត្តិរូប ប៉ុល ពត យើងគួរតែបានសម្ភាស ប៉ុល ពត។ ប៉ុន្តែ ដេវីដ ឆេនដ៍ល័រ គាត់មានលក្ខណៈផ្សេងមួយទៀត គាត់<បានសម្ភាសអ្នកមានអំណាចខ្មែរជាច្រើននៅក្រៅប្រទេស គាត់បាន>ពិនិត្យមើលទៅលើប្រវត្តិ មើលបណ្ណសារទៅមើលអ្វីៗទាំងអស់ <ប៉ុន្តែមិនសម្ភាស -->។

**ស៖** លោក ហង់រី ឡូកា សូមលោកឆ្លើយ?

**ឆ៖** ខ្ញុំឆ្លើយហើយតើ។

**ស៖** លោកបាននិយាយថា ហ្វីលីព ស្សូត បានសម្ភាសមនុស្សដទៃទៀតដែលអ្នកដទៃអត់ដែលបានសម្ភាស។ គ្រាន់តែប្រាប់ឈ្មោះមកចប់ហើយលោក?

**ឆ៖** បាទ មិនអីទេ។ មាន ភី ភួន, សួង ស៊ីគឿន, ខៀវ សំផន។ ប្រហែលជាមិនបានសម្ភាសនួន ជា ទេ ពីព្រោះ នួន ជា មិនដែលផ្ដល់ពេលឲ្យនរណានោះទេ។ ហើយខ្ញុំបញ្ជាក់រួចហើយគឺ ជួនប្រសិទ្ធិ, ជួន ម៉ុម។ ប៉ុន្តែ ជួន ម៉ុម ត្រូវ ដេវីដ ឆេនដ៍ល័រ សម្ភាសដែរ។ ដូច្នេះ បើខ្ញុំមិនប្រាកដទេអាចៗឡុង វីសាឡូ ហើយនិងមនុស្សដទៃទៀតជាច្រើនដែលពាក់ព័ន្ធដោយផ្ទាល់ ឬក៏ដោយប្រយោលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែល ដេវីដ ឆេនដ៍ល័រ អត់បានសម្ភាសទេ។ ដូច្នេះ ខ្ញុំគិតថាសៀវភៅរបស់គាត់គឺ គួរឲ្យចង់អានមានព័ត៌មានជាច្រើន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** លោកយល់ស្រប<ជាមួយខ្ញុំ>ថា <លោកខ្លួនឯងនេះ>បានសម្ភាស ភី ភួន, ខៀវ សំផន <ដែល>តុលាការខ្មែរក្រហមយើងនេះ ក៏បានសម្ភាស ភី ភួន<> ដែរ។ ដូច្នេះ ខ្ញុំចង់សួរថា ចុះតើ <ហេតុអ្វីបានជាមិនមាន>កំណត់ត្រារបស់លោក<ថាលោកបាន>សម្ភាសជាមួយនឹង ខៀវ សំផន?

**ផះ** សំណួរនេះ គឺសំណួរដដែលៗច្រំដែលខ្ញុំឆ្លើយរួចទៅហើយ។

**សៈ** តើលោកមានកំណត់ត្រាការសម្ភាសរបស់លោកជាមួយ អៀង សារី ទេ?

[១១:០៩:១០]

**ផះ** មាន។ ខ្ញុំមាន ប៉ុន្តែការសម្ភាស អៀង សារី គឺខ្លីទេ ខ្ញុំធ្វើនៅប៉ៃលិន។ នៅពេលហ្នឹងមានមនុស្សជាច្រើននៅជុំវិញហ្នឹង។ <ហើយ>គាត់ផ្តល់<ពេលវេលាឲ្យខ្ញុំប្រហែលកន្លះម៉ោង>។ ហើយ <>គាត់ថាគាត់រវល់<ខ្លាំងណាស់> ហើយគាត់ក៏ចាកចេញទៅបាត់ទៅ។ ដូច្នេះ <ពេលនោះយើងទើបតែ>ចាប់ផ្តើម<និយាយ>អំពីប្រវត្តិកុមាររបស់គាត់ ហើយ<គាត់>រៀបរាប់ថាគាត់បានផ្លាស់ប្តូរកាលបរិច្ឆេទកំណើតរបស់គាត់ ធ្វើឲ្យគាត់ហ្នឹងកែអាយុក្មេងជាងអាយុពិតរបស់គាត់ បួនប្រាំឆ្នាំ <ដើម្បីឲ្យគាត់បានចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិ>។

**សៈ** <បើ>វា<>មិនមែនជាការសម្ភាសឲ្យហ្មត់ចត់<រយៈពេល>៣០នាទី<ទេ> ហេតុអីក៏លោក<>ដាក់នៅក្នុងឯកសារ<ការពារនិក្ខេបបទ>របស់លោក<>?

**ផះ** លោកនិយាយថា ជាការសម្ភាសដែលមិនហ្មត់ចត់ ប៉ុន្តែ <អៀង សារី គិតថា>វាជាការសម្ភាសហ្មត់ចត់។ <ប៉ុន្តែ>វាខ្លី<ពេក។> នៅពេលនោះ <>គ្មានអ្នកណា<>មានឱកាសបានសម្ភាស អៀង សារី ទេ ព្រោះ អៀង សារី ក៏មិនសូវចង់ផ្តល់ការសម្ភាស។

**សៈ** ប៉ុន្តែ ស្ទីវ ហេដឌ័រ គាត់សម្ភាស អៀង សារី បានច្រើនណាស់។ ហើយលោក ខ្លួនលោកផ្ទាល់ នៅថ្ងៃទី០២ លោកបានបញ្ជាក់ថា លោកគ្មានពេលដើម្បីនិយាយអំពីកម្ពុជាប្រជាធិបតេយ្យជាមួយ អៀង សារី។ តើអីចឹងមែនទេ?

**ផះ** បាទ ខ្ញុំនិយាយអីចឹងមែន។ ដោយសារតែគាត់ចាកចេញទៅបាត់ទៅ គាត់គេចទៅបាត់ទៅ <ហើយគាត់>និយាយ<មកខ្ញុំថា "ខ្ញុំផ្តល់ឲ្យអ្នកឯងជាច្រើននាទីហើយ>គឺគ្រប់គ្រាន់<ហើយ។>" យើងមិនមានពេលវេលាលម្អិតទៅលើចំណុច <--> ព្រោះថាអតីតខ្មែរក្រហម ភាគច្រើន គាត់ចូលចិត្តនិយាយអំពីប្រវត្តិពីកុមារ ពីការអប់រំ <ពីការរស់>នៅបារាំង នៅ<វិទ្យាល័យ>ស៊ីសុវត្ថិ ប៉ុន្តែនៅពេលដែលយើងនិយាយអំពីសង្គ្រាមស៊ីវិល អំពីរបបខ្មែរក្រហម គឺពិបាកក្នុងការសម្ភាស។ ប៉ុន្តែស្ទូម្បី ជួន

ម៉ុម ក៏អ៊ីចឹងដែរ។

[១១:១១:១៦]

**ស៖** លោកបាននិយាយថា លោកបានសម្ភាស ភី ភួន នៅថ្ងៃទី១ ម៉ោង<១១:១៧ នាទី> គឺលោកបាននិយាយថា ភី ភួន ជាប្រភពព័ត៌មានដ៏សំខាន់ចំពោះលោក។ តើលោកអាចប្រាប់បានទេថាតើ ភី ភួន ប្រាប់អ្វីខ្លះដល់លោក ច្រើនជាងអ្វីដែលគាត់បានមកផ្ដល់សក្ខីកម្មនៅទីនេះ? ដូច្នេះខ្ញុំចង់សួរថា តើមានអ្វីដែលថ្មី ដែល ភី ភួន ប្រាប់លោកទាំងមិនបានប្រាប់អង្គជំនុំជម្រះនេះ?

**ឆ៖** លោក<នឹង>ដឹង<រឿងនោះ វាមិនវែងទេ> ព្រោះថានៅពេលនោះ គឺថាខ្ញុំបានកត់ត្រាសំឡេង ខ្ញុំបានថតសំឡេង ហើយបានកត់ត្រាជាអក្សរ <ដែលគ្រប់គ្រាន់សម្រាប់បោះពុម្ព>សៀវភៅ<>។ គាត់បានបញ្ជាក់ទៅលើអ្វីដែលគាត់បាននិយាយនៅតុលាការនេះ<>។ ខ្ញុំគិតថា គាត់មកផ្ដល់សក្ខីកម្មបីបួនថ្ងៃ គឺច្រើន<>។ គាត់<ជាអតីត>ខ្មែរក្រហម<អ្នកកាន់លទ្ធិកុម្មុយនីស្ដម្នាក់។ គាត់ជា>កងទ័ព<ធ្វើការខាងផ្នែកសន្តិសុខ> ហើយគាត់និយាយត្រង់។ ហើយខ្ញុំគិតថា តុលាការពេញចិត្តជាមួយនឹងសក្ខីកម្មរបស់គាត់។

ប្រាកដណាស់ថា គាត់បាននិយាយជាមួយខ្ញុំច្រើនអំពីកុមារភាពរបស់គាត់ ថាតើគាត់ចូលបដិវត្តន៍ដោយរបៀបណា តើចលនាបដិវត្តន៍ចាប់ផ្ដើមដោយរបៀបណា។ ហើយយើងបានពិភាក្សាលម្អិត។ <គាត់ថា នៅពេលនោះ> អៀង សារី <បានទៅ>ដល់<មុន គឺ>មុន<ពេល> សាឡុត ស <ហៅថា ពត បានទៅដល់>។ ហើយគាត់ពន្យល់ខ្ញុំ<នូវអ្វីដែលគាត់ហៅថា ជាការប្រកួតប្រជែងយ៉ាងយូរ នៅ>ឆ្នាំ<១៩>៧០ នៅពេល ប៉ុល ពត និងក្រុមរបស់ពួកគាត់ហ្នឹង បានគេចខ្លួនរាប់ខែ ពីខេត្តរតនគិរី ទៅស្ទឹងជីនិត។ ហើយគាត់បានផ្ដល់ព័ត៌មានលម្អិតអំពីសង្គ្រាមស៊ីវិល <ការចូលទៅ>ទីក្រុងភ្នំពេញ <>ការកាន់កាប់ក្រុងភ្នំពេញ ហើយ<តួនាទីរបស់>គាត់បាន<ប្ដូរទៅគ្រប់គ្រង>ខាងសន្តិសុខនៅក្រសួង<>ការបរទេស។ ហើយ<គាត់>ក៏បាន<ប្រាប់ខ្ញុំលម្អិតដែរ អំពីពេលដែលគាត់បានអមដំណើរការពារ>សម្ដេច សីហនុ <ពេលសម្ដេច>ធ្វើដំណើរទៅកំពង់សោមជាដើម។ គាត់បានឃើញអំពីការកសាង<ផ្លូវរថភ្លើងថ្មី ហើយនិងអ្វីៗជាច្រើន>ទៅទៀត។

**ស៖** <ប៉ុន្តែ>សំណួរខ្ញុំចង់សួរថាតើ<>គាត់ប្រាប់លោក<អ្វីខ្លះដែលគាត់>មិនបានប្រាប់តុលាការនេះ?

**ឆ៖** ក្នុងអង្គជំនុំជម្រះនេះ គាត់ចំណាយពេល៣ថ្ងៃ ដើម្បីផ្ដល់សក្ខីកម្ម។ <ខ្ញុំមិនដឹងមិនដឹង

ច្បាស់ទេ។> ខ្ញុំ<មិន>ចាំ<ទេ>។ <លោកអាច>ប្រាប់ខ្ញុំ<បាន។> ប៉ុន្តែគាត់ចំណាយពេលរាប់ខែច្រើនខែជាមួយខ្ញុំ ផ្តល់ចម្លើយមកខ្ញុំ មុនពេលដែលគាត់មកផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះនេះ។ ខ្ញុំសម្គាសគាត់យ៉ាងច្រើន<នៅពេលកន្លងទៅ ប៉ុន្តែ>គាត់<ទើបតែបាន>ស្លាប់ទៅ គឺស្លាប់នៅឆ្នាំមុនហ្នឹង <> ខ្ញុំបានទៅ<>ភូមិកំណើតរបស់គាត់<ជាមួយគាត់ គឺ>ទៅព្រះវិហារ។ ហើយវាជារឿងគួរឲ្យភ្ញាក់ផ្អើលណាស់ដែលគាត់ស្លាប់ភ្លាមៗបែបនេះ។ <ប៉ុន្តែ>ក្នុងរយៈពេល១៨ខែចុងក្រោយ<ខ្ញុំបានធ្វើការជាមួយគាត់>។

[១១:១៤:៤១]

**ស៖** ឥឡូវនេះខ្ញុំសូមនិយាយអំពី ហ្វីលីព ស្បូត វិញ ក៏ដូចជានិយាយអំពីប្រធានបទមន្ទីរសន្តិសុខជាទូទៅ ជារួម។ លោកជាអ្នកដែល<>ពេញចិត្តយ៉ាងខ្លាំងជាមួយនឹង<ការងាររបស់> ហ្វីលីព ស្បូត។ <>ថាតើលោក<យល់ស្របជាមួយគាត់ទេ>ថាស-២១អាចធៀបទៅនឹងគុករបស់បារាំងនៅអាល់ហ្សេរី <នៅទសវត្សរ៍៥0>?

**ឆ៖** បាទ នេះ គឺជាការប្រៀបធៀបដ៏<ជាក់លាក់មួយ> ដែលខ្ញុំបាន<ដាក់សញ្ញាសួរនៅក្នុងឯកសាររបស់ខ្ញុំ> ប៉ុន្តែខ្ញុំអត់យកឯកសារនោះមកទេ។ <ទី១> ខ្ញុំមិន<>ដឹង<អ្វីច្រើន>ទេ <ពីព្រោះនៅពេល>សង្គ្រាមនៅអាល់ហ្សេរី<>នោះ ខ្ញុំនៅក្មេងនៅឡើយ។ ខ្ញុំនៅរៀននៅមធ្យមសិក្សានៅឡើយ។ <ហើយ>ខ្ញុំមិន<មែនជាអ្នកជំនាញ>អំពីអំឡុងនៅក្នុងអាល់ហ្សេរីនោះទេ។ <ទី២ ខ្ញុំមិន>ជឿជាក់<ដាច់ខាត>ថា ការប្រៀបធៀបហ្នឹង <>មានភាពពាក់ព័ន្ធគ្នា។

**ស៖** ប៉ុន្តែប្រាកដណាស់ថា លោកបានធ្វើការលើកនូវទឡ្ហីករណ៍យ៉ាងច្រើនអំពីលក្ខណៈនៃមន្ទីរសន្តិសុខ ក៏ដូចជាប្រព័ន្ធមន្ទីរសន្តិសុខកម្ពុជាប្រជាធិបតេយ្យ ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកធ្វើយ៉ាងណាដើម្បីអាចប្រៀបធៀបប្រព័ន្ធសន្តិសុខនៅកម្ពុជាប្រជាធិបតេយ្យ<ជាមួយប្រទេសផ្សេងៗទៀត ឬក៏ជាមួយ>ប្រទេសកម្ពុជា<ខ្លួនឯងហ្នឹង?> តើលោកមានបានដឹងថា មានគុកប៉ុន្មានទេ? តើមាននៅកន្លែងណាដែរទេ ហើយថាតើគុកនៅមុនឆ្នាំ៧៥ មានប៉ុន្មាន? នៅកន្លែងណាខ្លះ? តើលោកដឹងអំពីចំណុចនេះទាំងអស់នេះទេ?

[១១:១៦:៤៣]

**ឆ៖** បាទ ប្រាកដណាស់។ នេះ គឺជាប្រធានបទនៃការសិក្សាស្រាវជ្រាវ<របស់>លោក <លុច> ប៉ៃនែស។ <>ការសិក្សា<នេះបានដឹងដល់កូនសិស្សគាត់នៅ>សាកលវិទ្យាល័យមួយនៅបារាំង

01344495



ហើយគាត់ចាប់ផ្ដើមពីសម័យអាណានិគមបន្តមក។ <នៅពេលនេះ ការសិក្សានេះមានភាពល្អីល្បាញណាស់ គឺ>បារាំង <បាន>បង្កើតប្រព័ន្ធយុត្តិធម៌<> បង្កើតគុក គឺថាបានន័យថា <>ខេត្តមួយមានគុកមួយ។ <សូមអរគុណដល់>ការងាររបស់លោក <លុច> ប៉ៃនែស <ដែល>គាត់បានសិក្សាអំពីប្រភពដើមនៃខ្នោះ គឺសិក្សាអំពីខ្នោះឈើ។ ខ្ញុំភ្លេចពាក្យជាភាសាអង់គ្លេសហើយ ប៉ុន្តែខ្នោះឈើ ហើយខ្នោះឈើហ្នឹង គឺមាន<នៅកម្ពុជា>តាំងពីមុនសម័យអាណានិគមមកម៉្លេះ។ ភាសាអង់គ្លេសគេថា *"វូតដេន <សេក>ខល"* អរគុណ។ គឺថា ខ្នោះឈើហ្នឹង មានតាំងពីមុនរបបខ្មែរក្រហមមកតទៅទៀត។ <> ខ្ញុំគិតថា ការ<ដាក់ច្រវាក់បានកើតមាន>នៅក្នុងរបបសម័យអាណានិគម <ប៉ុន្តែអ្នកទោសត្រូវបានគេដាក់ច្រវាក់តែនៅ>ពេលយប់ <ហើយនៅពេលថ្ងៃ អ្នកទោសទាំងនោះត្រូវបានគេបញ្ចេញឲ្យទៅធ្វើការងារធ្ងន់ធ្ងរ ដូច្នេះហើយអ្នកទោសទាំងនោះមិនត្រូវបានគេដាក់ឲ្យជាប់ច្រវាក់ជារៀងរហូតនោះទេ>។ នៅពេលដែលបារាំងគ្រប់គ្រង<>ពន្ធនាគារ <លុច ប៉ៃនែស ប្រាប់ខ្ញុំថា>ហើយនៅសម័យនោះ គឺគុកនៅក្នុងប្រទេសកម្ពុជា គឺថាអ្នកជាប់ទោសត្រូវបានគេដាក់ខ្នោះឃ្នាងទាំងអស់ សូម្បីតែនៅសម័យអាណានិគមបារាំងក៏ដោយ។ នៅពេលដែលបារាំងគ្រប់គ្រងដែលយើងហៅថា ដាក់អាណាព្យាបាលលើកម្ពុជានុំង គឺថាមាន<រដ្ឋបាលពីរ គឺរដ្ឋបាលគ្រប់គ្រងដោយបារាំង និងរដ្ឋបាលគ្រប់គ្រងដោយកម្ពុជា។ ដូច្នេះ វាមិនអាចទៅរួចទេថា នៅក្នុងគុករបស់ខ្មែរ មាន>ដាក់ខ្នោះអ្នកទោស ហើយនិងការធ្វើទារុណកម្មផងដែរ។ ខ្ញុំគិតថា តាមរយៈវៀតមិញ គឺខ្មែរក្រហមបានសិក្សាពីវៀតមិញ អំពីការដាក់ខ្នោះ អំពីការសួរចម្លើយជនរងគ្រោះ។ <>យើងឃើញមានការផ្ដល់សក្ខីកម្មជាច្រើន<របស់ទាហានជនជាតិបារាំង ក្រោយពីការបរាជ័យរបស់កងទ័ព>បារាំង<នៅឆ្នាំ១៩៥៤។>

[១១:១៩:១៨]

**សៈ** សូមទោសលោក ឡូកា ខ្ញុំត្រូវតែកាត់លោក ដោយសារខ្ញុំមានពេលវេលាកំណត់។ អ្វីដែលខ្ញុំចង់សួរលោក គឺចង់សួរលោកអំពីរយៈកាលមុនកម្ពុជាប្រជាធិបតេយ្យ គឺក្នុងរបបសាធារណរដ្ឋ។ នៅពេលដែលលោកឆ្លើយសំណួរសហមេធាវីនាំមុខ លោកបាននិយាយអំពីស្ថានភាពរស់នៅ នៅតាមគុក នៅតាមខេត្ត ហើយខ្ញុំបានកត់ត្រាដែរ លោកនិយាយថា វាគគ្រិចគ្មានអនាម័យ គ្មានខ្មើយ គ្មានភួយ គ្មានការព្យាបាលជំងឺ មានសត្វល្អិតច្រើន។ ដូច្នេះ ខ្ញុំចង់សួរលោកថា ប្រសិនបើធ្វើការប្រៀបធៀបស្ថានភាពឃុំឃាំងនៅរបបសាធារណរដ្ឋខ្មែរ និងខ្មែរក្រហមយ៉ាងម៉េចដែរ តើលោកមានបានសិក្សាស្រាវជ្រាវលើចំណុចនេះទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងឌូបកប្រែ និងឌូបកប្រែបន្ត។*

**ឆ៖** ចំពោះប្រធានបទនេះ គឺជាការគួរឲ្យសោកស្តាយ ដោយសារ<អង្គជំនុំជម្រះនេះ>មិនបាន<សួរចម្លើយ ឬក៏>សម្ភាស<ឌុច>ឲ្យបានច្រើន<> អំពីបទពិសោធន៍របស់គាត់នៅ<ក្នុងគុក>ក្នុងរបបសង្គមរាស្ត្រនិយម។ <ខ្ញុំគិតថា គាត់ត្រូវបានគេចាប់ដាក់គុកជិតពីរឆ្នាំ គឺ>នៅព្រៃស<>។ ហើយ<គាត់ត្រូវបានគេដោះលែងនៅដើម>របបសាធារណរដ្ឋខ្មែរ<>។ <ដូច្នេះ>ខ្ញុំគិតថា ឌុច គាត់ដឹងអំពីរបបសង្គមរាស្ត្រនិយម ក៏ដូចជានៅក្នុងរបប លន់ នល់ដែរ។ ខ្ញុំបានស្តាប់នូវសក្ខីកម្មរបស់ ឌុច សឹងតែទាំងអស់ហើយ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំមិនប្រាកដថាតើគេបាន<សួរ>គាត់អំពីបញ្ហាទាំងអស់នេះ ឬក៏អត់នោះទេ។

**ស៖** អ្វីដែលខ្ញុំចង់សួរ គឺថាតើលោកមានបានធ្វើការស្រាវជ្រាវអំពីស្ថានភាពគុក នៅតាមខេត្តមុនឆ្នាំ៧៥ដែរឬទេ ដើម្បីឲ្យលោកអាចធ្វើការប្រៀបធៀបបាន។ គឺខ្ញុំចង់សួរថា តើកម្មាភិបាលខ្មែរក្រហមគ្រាន់តែបន្តការគ្រប់គ្រងដែលគេធ្វើជាទូទៅនៅមុនឆ្នាំ៧៥មក ឬមួយក៏យ៉ាងណា?

**ឆ៖** លោកអាចទទួលបានព័ត៌មានទាំងអស់នេះ ពី ខៀវ សំផន។ ខ្ញុំដឹងថា ខៀវ សំផន ជាប់គុក ហើយហោចណាស់ក៏១ខែដែរ។ ដូច្នេះហើយគាត់អាចឆ្លើយបានល្អជាង។ ខ្ញុំចង់បញ្ជាក់ថា ខ្ញុំមិនបានធ្វើការស្រាវជ្រាវណាមួយអំពីគុក<មុនរបប>ខ្មែរក្រហមនោះទេ ប៉ុន្តែ <លុច ប៉ែនែស> ដែលជាជនជាតិបារាំង គាត់បានធ្វើការស្រាវជ្រាវ។ ដូច្នេះ ខ្ញុំមិនធ្វើការប្រៀបធៀប<ជាមួយនឹងគុកមុនសម័យខ្មែរក្រហម>នោះទេ។ គ្រាន់តែខ្ញុំប្រៀបធៀបគុក នៅក្នុងសហភាពសូវៀត និង គុកហ្គូឡាស ក៏ដូចជាគុកនៅប្រទេសចិន។ ខ្ញុំគិតថា ស្ថានភាពទូទៅរបស់គុកនៅតាមប្រទេសទាំងអស់នេះ គឺប្រហាក់ប្រហែលគ្នា។ គឺថាជារឿងគួរឲ្យសោកស្តាយយ៉ាងខ្លាំង។ ដូចគ្នានៅវៀតណាម គឺវៀតណាម គឺមានជនរងគ្រោះជាច្រើនដែលគេដាក់នៅក្នុងគុកងងឹត ហើយខ្ញុំមិនដឹងថា ខ្មែរក្រហមធ្វើឬក៏អត់។

[១១:២២:៤២]

**ស៖** ខ្ញុំមិនចាប់អារម្មណ៍អំពីចំណុចនេះទេ។ អ្វីដែលខ្ញុំចង់សួរ គឺថាមុនឆ្នាំ៧៥ អត់មានស្រាវជ្រាវទេ ចុះក្រោយ៧៩ ក៏អត់ដែរ អ៊ីចឹងមែនទេ?

**ឆ៖** ក្រោយឆ្នាំ៧៩ មិនមែនជាកម្មវត្ថុនៃជំនុំជម្រះនេះទេ។

**ស៖** ខ្ញុំមិនចាប់អារម្មណ៍លើចំណុចនេះ ប៉ុន្តែចង់ដឹងថា តើលោកមានបានធ្វើការប្រៀបធៀបគុកនៅតាមខេត្ត ក្រោយឆ្នាំ៧៩ និងមុនឆ្នាំ៧៥ ដែរឬទេ? ដើម្បីឲ្យលោកអាចធ្វើការប្រៀបធៀបបាន?

**ឆ៖** ការប្រៀបធៀប<បែបនេះ> មិនមែនជាផ្នែកនៃការស្រាវជ្រាវរបស់ខ្ញុំទេ ប៉ុន្តែជាការ

ស្រាវជ្រាវរបស់ លោក <លុច ប៉ែនែស>។ <ចំពោះ>ក្រោយ ៧៩ ក៏ខ្ញុំមិនបានស្រាវជ្រាវដែរ ហើយវាមិនមែនជាកម្មវត្ថុនៃ តុលាការនេះដែរ មិនមែនជាកម្មវត្ថុនៃការស្រាវជ្រាវរបស់ខ្ញុំ។

**ស៖** ឥឡូវនេះ សូមលោកបញ្ជាក់ឲ្យបានច្បាស់បន្តិចទាក់ទងទៅនឹងការស្រាវជ្រាវរបស់លោកនៅក្រាំងតាចាន់។ ប្រសិនបើខ្ញុំខុសសូមលោកប្រាប់ខ្ញុំ។ ខ្ញុំបានអានទៅលើការសង្ខេបរបស់លោក គឺ <E3/8299>, ភាសាអង់គ្លេសមានលេខ 00217717, ខ្មែរមានលេខ 00739069, បារាំងមានលេខ 00743775។ គឺថា លោកថាបានសម្ភាសមនុស្សបីនាក់ទាក់ទងទៅនឹងក្រាំងតាចាន់។ មនុស្សទី១ ឈ្មោះ ហ៊ូ <កិល>, ទី២ <កែវ ម៉ៅ> ម្នាក់ទៀតឈ្មោះ <សូត្រ សាំង>។ ខ្ញុំគិតថា អង្គជំនុំជម្រះក៏ដូចជាភាគីនានាដឹងអំពីមនុស្សពីរនាក់ក្រោយហ្នឹង ប៉ុន្តែ ហ៊ូ <កិល> ប្រហែលជាយើងមិនដែលស្គាល់ពីមុន។ ដូច្នេះ ខ្ញុំចង់សួរថា តើ ហ៊ូ <កិល> ហ្នឹងគឺជាអ្នកណាលោកចាំទេ?

[១១:២៥:០០]

**ឆ៖** ខ្ញុំមិនអាចចាំបានទេ នូវកំណត់ត្រារាប់រយ រាប់ពាន់ទំព័ររបស់ខ្ញុំ <ដែលខ្ញុំបានផ្តល់ឲ្យអង្គជំនុំជម្រះនោះ>។ ឯកសារអំពីក្រាំងតាចាន់ ខ្ញុំមាននៅទីនេះ <ខ្ញុំអាចយកវាចេញមកបាន>។

**ស៖** ឥឡូវ ខ្ញុំជួយលោក គឺថាលោក -- គឺថាគាត់ជាមេភូមិ ជាកម្មាភិបាលជាន់ទាប គឺភូមិហ្នឹងមានចម្ងាយប្រហែល២គីឡូម៉ែត្រពីក្រាំងតាចាន់ ថាតើត្រឹមត្រូវដែលថា ហ៊ូ <កិល> គឺជាមេភូមិដែលនៅចម្ងាយប្រហែលជា២គីឡូម៉ែត្រ ពីក្រាំងតាចាន់នោះ?

**ឆ៖** បាទ ប្រហែលហើយ។ <ម៉េចបានជា>ខ្ញុំ<>និយាយ<ដូច្នោះ តើ>ខ្ញុំបានសរសេរ<អ្វី>មួយ<>ដែល<>មិន<ពិតឬ?> ដូច្នេះ ខ្ញុំចង់បញ្ជាក់ថា តុលាការរកឃើញសាក្សីច្រើន ច្រើនជាងខ្ញុំទៀត ដោយសារតុលាការមាននូវសម្ភារៈ ធនធាន ហិរញ្ញវត្ថុ និងពេលវេលាច្រើនជាងខ្ញុំ។ ដូច្នេះ ប្រាកដណាស់ថា អង្គជំនុំជម្រះរកឃើញបានច្រើនពីក្រាំងតាចាន់លើសខ្ញុំទៅទៀត។

**ស៖** តើលោកគិតថា មនុស្សភាគច្រើនដែលលោកជួបសម្ភាសហ្នឹង គឺមិនបាននិយាយអំពីក្រាំងតាចាន់នោះទេ គឺនិយាយអំពីមន្ទីរសន្តិសុខផ្សេងៗនៅក្នុងតំបន់ដែលមន្ទីរសន្តិសុខនោះស្ថិតក្រៅវិសាលភាពតុលាការនេះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយ ប៉ុន្តែខ្ញុំ<រីករាយ កាលពី>សប្តាហ៍<មុនខ្ញុំដឹងថា គុកចំនួនបួន>ត្រូវបានតុលាការនេះ រើសយកមក<ជំនុំជម្រះ។ ខ្ញុំបានស៊ើបអង្កេតទៅលើគុកទាំងអស់នោះ ហើយបានដឹងរឿងខ្លះៗដែរ>។ ដូច្នេះ <ក្រៅពីគុកដែលត្រូវបាន>អង្គជំនុំជម្រះ<ជ្រើសរើសនេះ ខ្ញុំបានដឹងព័ត៌មានមួយ

ចំនួន១០០ភាគរយពីគុក>ទាំងអស់នេះ។

**ស៖** តើលោកយល់ស្របទេ ដែលថាមានតែ ហ៊ូ <កិល> ហ្នឹង <>ជាភស្តុតាង<មានសក្តានុពល> ដែល<>លោកបានផ្តល់ដល់អង្គជំនុំជម្រះ<និងភាគី> ចំណែកភស្តុតាងផ្សេងៗដទៃទៀត អំពីក្រាំងតាចាន់ គឺអង្គជំនុំជម្រះមានរួចទៅហើយ។ តើអ៊ីចឹងមែនទេ?

[១១:២៧:១៧]

**ឆ៖** បាទ ពិតហើយ។ ការស្រាវជ្រាវដើមរបស់ខ្ញុំ គឺមាននៅក្នុងបណ្ណសាររួចទៅហើយ ប៉ុន្តែប្រសិនបើយើងមើលទៅលើលំដាប់លំដោយការស៊ើបអង្កេតរបស់ខ្ញុំ គឺខ្ញុំធ្វើឡើងតាំងពីមុនតុលាការនេះមកម្ល៉េះ។

**ស៖** លោកនិយាយអំពីបណ្ណសារ ប៉ុន្តែតើលោក<ដឹងថា>មានឯកសារអ្វីទាក់ទងនឹងក្រាំងតាចាន់ ដែលលោកមាន ប៉ុន្តែអង្គជំនុំជម្រះអត់មានទេ?

**ឆ៖** ឯកសារក្រាំងតាចាន់ <ដែលលោកស្រី ហ្គីសសេ>បានប្រគល់<ឱ្យខ្ញុំ>កាលពីថ្ងៃសុក្រ <> ខ្ញុំមិនបានពិនិត្យមើលថាតើខ្ញុំមានដូចគ្នានៅផ្ទះ ឬក៏អត់ទេ ព្រោះថានៅផ្ទះខ្ញុំ ខ្ញុំមានឯកសារថតចម្លងជាច្រើន <ខ្ញុំមិនទាន់បានពិនិត្យមើល>។ ហើយខ្ញុំមិនប្រាកដថា ការប្រមូលចងក្រងរបស់ខ្ញុំជាការប្រមូលចងក្រងពេញលេញ ឬក៏អត់នោះទេ។ ហើយតុលាការនេះ ក៏មិនប្រាកដដែរថា ឯកសារច្បាប់ដើមនៅឯណា <មិនដឹងថា>នៅឌី.ស៊ី.ខេម នៅស-២១ ឬក៏នៅកន្លែងណានោះ<ទេ>។ ដូច្នេះ អ្វីដែលខ្ញុំចង់បញ្ជាក់ គឺថាទីកន្លែងរបស់ឯកសារច្បាប់ដើម ហាក់ដូចជា<មានបញ្ហា>។

[១១:២៨:៤០]

**ស៖** នៅក្នុងឯកសារ E3/8299 ដែលនិយាយអំពីក្រាំងតាចាន់ហ្នឹង គឺលោកក៏បានបង្ហាញផងដែរ អំពីព័ត៌មានរបស់មនុស្សម្នាក់ឈ្មោះថា ប៉ែន សុវណ្ណ។ តើលោកមានបានធ្លាប់សម្ភាស ប៉ែន សុវណ្ណ ដែរឬទេ? ប្រសិនបើលោកធ្លាប់សម្ភាសគាត់ តើលោកមកំណត់ត្រាអំពីកិច្ចសម្ភាសន៍នោះទេ?

**ឆ៖** បាទ ខ្ញុំបានសម្ភាស ប៉ែន សុវណ្ណ ក្រោយពេលដែលគាត់ត្រឡប់មកប្រទេសកម្ពុជា <--> ភ្លាមៗ ក្រោយពេលគាត់ត្រឡប់មក។ <ដូចខ្ញុំបាននិយាយនៅក្នុងឯកសារខ្ញុំហើយ ទោះបីជាគាត់មកពីភូមិមួយជិតភូមិតាម៉ុក និងជិតក្រាំងតាចាន់ ប៉ុន្តែគាត់ជ្រើសរើសមក>រស់នៅក្នុងទីរួមខេត្តតាកែវ ហើយខ្ញុំសម្ភាសគាត់នៅក្នុងទីរួមខេត្តតាកែវ។ ខ្ញុំមិនប្រាកដថាខ្ញុំសម្ភាសជាភាសាបារាំង ឬអត់ទេ ប៉ុន្តែខ្ញុំពិតជាមានកំណត់ត្រាអំពីកាសម្ភាសនេះ។ ហើយការសម្ភាសនេះ វាជារឿងគួរឱ្យចាប់អារម្មណ៍យ៉ាងខ្លាំង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយខ្ញុំរីករាយដែលខ្ញុំបានសម្ភាសគាត់។

**ស៖** តើលោកអាចផ្តល់ដល់អង្គជំនុំជម្រះនិងភាគីបានទេ អំពីកំណត់ត្រានៃការសម្ភាសរបស់លោកជាមួយ ប៉ែន សុវណ្ណ នេះ?

**ឆ៖** ខ្ញុំពិនិត្យមើលលើឯកសារ<>របស់ខ្ញុំ ទាក់ទងនឹងក្រាំងតាចាន់ <ដែលខ្ញុំបានត្រៀមសម្រាប់សិក្ខាសាលាមួយរៀបចំដោយ> ដេវីដ ឆេនដ៍ល័រ <នៅក្នុងឱកាសគាត់ចូលនិវត្ត>នៅ<ខែធ្នូ ឆ្នាំ>៩៦។ <ខ្ញុំគិតថា ខ្ញុំបានសង្ខេបរួច>ហើយនៅក្នុងឯកសារនេះ គឺជាឯកសារដ៏សំខាន់មួយ ដែល ប៉ែន សុវណ្ណ គាត់ផ្តល់ឱ្យខ្ញុំ <ប៉ុន្តែ>ខ្ញុំអាចពិនិត្យមើល<កំណត់ហេតុរបស់ខ្ញុំ>ឡើងវិញថា តើខ្ញុំ<មានភ្លេច>ចំណុចសំខាន់<ណាទេ>។

**ស៖** លោកប្រធាន ខ្ញុំមើលទៅឃើញថា ដល់ម៉ោងឈប់សម្រាកហើយ។ ដូចខ្ញុំសូមអនុញ្ញាតដើម្បីឈប់សម្រាក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការវិញ នៅវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឱ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣១ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការកិច្ចនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅមេធាវី រ៉ិកទ័រ កូប៉េ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

**សួរដោយលោក រ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។ ជម្រាបសួរលោក ហង់រី ឡូកា។ ខ្ញុំនៅសល់ពេល៣០នាទីទៀត។ ដូច្នេះ ខ្ញុំត្រូវ<រំលង>ប្រធាន<បទ> ខ្លះចោល។ <ខ្ញុំនៅសល់ប្រធានបទពីរទៀត ដែលខ្ញុំចង់សួរលោក។> អ៊ីចឹងខ្ញុំនឹងសួរលោកប្រធានបទមួយ គឺប្រធានបទទាក់ទងទៅនឹងអ្វីដែលលោកបានឆ្លើយនៅថ្ងៃទី១ នៃការចូលមកផ្តល់សក្ខីកម្មនេះគឺ <នៅម៉ោង១៣:៣៨នាទី> ខ្ញុំសូមដកស្រង់៖ "ខ្ញុំបានចូលសិក្សាអំពីប្រវត្តិរបស់កម្ពុជាប្រជាធិបតេយ្យ <តាមរយៈប្រវត្តិ>សង្គ្រាមត្រជាក់ <ដូច្នេះខ្ញុំបានអានអ្វីៗទាំងអស់ដែល>ខ្ញុំ<អាច>អាន<បានទាក់ទងទៅនឹង>ប្រទេសកុម្មុយនីស្ត<ទាំងអស់នេះ> ជាពិសេសគឺប្រទេសចិន" ហើយបន្ទាប់មកទៀត លោកឆ្លើយថាកម្ពុជាប្រជាធិបតេយ្យ គឺយកគំរូពីប្រទេសចិន។<> តើចំណុចនេះ<មានន័យ>ថា លោកអាច <ចាត់ទុកខ្លួនលោក>ថា <តើលោកមានតួនាទីក្នុងការចោទប្រកាន់ថា>ការសម្លាប់រង្គាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសការសម្លាប់រង្គាល<ហ្នឹង>ប្រព្រឹត្តឡើងដោយ<ពួកបស្ចិមប្រទេសឬ>បណ្តារដ្ឋដែលគាំទ្រ ដោយបស្ចិមប្រទេស<នៅ>ពេលសង្គ្រាមត្រជាក់នោះដែរទេ?

[១៣:៣៣:៤២]

**លោក ហង់រី ឡូកា៖**

**ឆ៖** សូមអរគុណចំពោះសំណួរនេះ។ ខ្ញុំគិតថាយើងនឹងទៅនិយាយអំពីប្រទេសចិន អំពីម៉ៅសេងទុង។ <ប៉ុន្តែប្រាកដណាស់>យើង<កំពុងតែ>និយាយអំពីការសម្លាប់រង្គាលនៅក្នុងឆ្នាំ៧៥ ដល់ ៧៩ ដែល<បានប្រព្រឹត្ត>នៅបស្ចិមប្រទេសដោយពួកបស្ចិមប្រទេស<>។ ពាក់ព័ន្ធប្រធានបទនេះខ្ញុំអត់មានព័ត៌មានអាចឆ្លើយបានទេ ពីព្រោះខ្ញុំអត់បានសិក្សារៀនសូត្រអំពីរឿងនេះទេ។

**ស៖** ខ្ញុំ<ចង់សួរលោកឲ្យច្បាស់ ពី>ពាក្យ<ដែល>លោក<ថា សិក្សាពី>កម្ពុជាប្រជាធិបតេយ្យ<តាមរយៈប្រវត្តិសង្គ្រាមត្រជាក់> ដែលក្នុងឃ្លានេះអាចមានន័យថា លោកក៏មានការយល់ដឹងអំពីការសម្លាប់រង្គាល ដែលប្រព្រឹត្តឡើងដោយពួកបស្ចិមប្រទេស ឬក៏ប្រទេសដែលគាំទ្រដោយពួកបស្ចិមប្រទេស ឬក៏ក្នុងក្របខ័ណ្ឌនៃ<សង្គ្រាមត្រជាក់>។ លោកចង់និយាយថាយ៉ាងដូច្នេះឬ?

**ឆ៖** អត់ទេ ខ្ញុំមិនចង់មានន័យយ៉ាងដូច្នេះទេ។ ខ្ញុំឥឡូវនេះ មិនដឹងថាលោកកំពុងនិយាយពីអ្វីផង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំសូមសួរលោកឲ្យច្បាស់ៗតែម្តងដើម្បីចង់ឲ្យដឹងថាតើខ្ញុំកំពុងមានបំណងចង់ៗទៅណា។ ខ្ញុំចង់និយាយការសម្លាប់រង្គាលដែលមានការពាក់ព័ន្ធយ៉ាងខ្លាំងទៅដល់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសគោលការណ៍រក្សាការសម្ងាត់នេះតែម្តង <ដែលលោកក៏បាននិយាយអំពីរឿងនេះដែរ។ មាន>ការសម្លាប់រង្គាលនៅក្នុងឆ្នាំ១៩៦៥<នៅ>ឥណ្ឌូនេស៊ី។ លោកមានដឹងរឿងការសម្លាប់រង្គាលនៅប្រទេសឥណ្ឌូនេស៊ីនេះទេ?

[១៣:៣៥:៤០]

**ឆ៖** ខ្ញុំមិនដែលបានសិក្សាបញ្ហាជាក់លាក់នេះទេ ខ្ញុំដឹង<រឿងនេះ>ពីប្រភពបន្ទាប់បន្សំទេ ដែលថាជាការពិតនោះគឺ ខ្មែរក្រហមបានដឹងច្បាស់ហើយអំពីការសម្លាប់រង្គាល ដែលប្រព្រឹត្តឡើងនៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលប៉ះពាល់ទៅដល់ជនរងគ្រោះរាប់រយពាន់នាក់ ជាពិសេសនៅក្នុងសហគមន៍ជនជាតិចិនរស់នៅក្នុងប្រទេសឥណ្ឌូនេស៊ីដែលត្រូវបានគេចោទប្រកាន់ថាជាសមាជិករបស់បក្សកុម្មុយនីស្តផងដែរ។ <>ខ្ញុំ<គ្រាន់តែ>បានអាន<រឿងដែរ ដូចលោក និងដូចមនុស្សគ្រប់ៗគ្នា>ដែរ។ ហើយជាពិសេស<ខ្ញុំគិតថា> នួន ជា នេះតែម្តងបានដឹងថា បក្សកុម្មុយនីស្ត<>អាចនឹងត្រូវគេបំផ្លាញចោលប្រសិនណាបើមេដឹកនាំត្រូវបានគេបំផ្លិចបំផ្លាញ ឬក៏សម្លាប់។ យ៉ាងដូច្នេះឯង ទើប<គាត់ចង់>ការពារថ្នាក់ដឹកនាំ ប៉ុន្តែ<ចំណុចនោះស្ទើរតែគ្មាន>ពាក់ព័ន្ធ<អ្វីសោះ>ទៅនឹងបស្ចិមប្រទេស។ <ខ្ញុំគិតថា រឿងនេះគឺ>ពាក់ព័ន្ធទៅនឹង<សង្គ្រាមត្រជាក់> ប្រទេសដែលមិនចូលបក្សសម្ព័ន្ធ ពាក់ព័ន្ធទៅនឹងសន្និសីទនៅទីក្រុងបានឌុងនៅក្នុងឆ្នាំ១៩៥៥ និង<១០>ឆ្នាំមុននោះ។ <ដូច្នេះ>ហើយ<មិនមែន>ជា<>ការសម្លាប់រង្គាលដែលប្រព្រឹត្តឡើងនៅបស្ចិមប្រទេស<ទេ>។

**ស៖** អ៊ីចឹងខ្លួនលោកផ្ទាល់ លោកមិនមានជំហរធ្វើការប្រៀបធៀបពាក់ព័ន្ធទៅទំហំនៃការសម្លាប់ជាដើម។ល។ បានទេឬ រវាងការសម្លាប់រង្គាលនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងឥណ្ឌូនេស៊ី លោកមិនអាចប្រៀបធៀបបានទេឬ?

**ឆ៖** ខ្ញុំមិនអាចប្រៀបធៀបបានទេ ពីព្រោះខ្ញុំមិនបានសិក្សាលម្អិតអំពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសឥណ្ឌូនេស៊ីនៅឆ្នាំ១៩៦៥នោះទេ។

**ស៖** ខ្ញុំសូមចូលទៅប្រធានបទចុងក្រោយមួយរបស់ខ្ញុំ។ នៅក្នុងសៀវភៅរបស់លោកនិយាយអំពីសុភាសិត<របស់អង្គការ> គឺឯកសារ <E3/2812>, ERN អង់គ្លេស <00394647>, ខ្មែរ 00810744, បារាំង 00394994។ លោកបានឆ្លើយថា ពាក្យស្លោក សូមដកស្រង់ "<ពាក្យស្លោកទាំង

អស់នេះសម្ដែងឲ្យឃើញច្បាស់នូវ>គោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជា"។ តើឃ្លានេះអាចពន្យល់ជូនអង្គជំនុំជម្រះឲ្យលម្អិតបន្តិចបានទេ?

**ឆ៖** សុភាសិតនោះ គឺពាក់ព័ន្ធទៅនឹងសេចក្ដីសង្ខេបអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលខ្ញុំចាត់ទុកថាវាជាការ -- ខ្ញុំៗបានចាត់ចំណាត់ថ្នាក់ទៅក្នុងជំពូក<ផ្សេងៗ។ ជំពូក>ទី១ គឺពាក់ព័ន្ធទៅនឹងពាក្យស្លោកក្នុងការលើកសរសើរបក្ស។ ខ្ញុំចាំដែរសម្ដេច សីហនុ <នៅក្នុង>សៀវភៅស្ដីអំពីការចងចាំរបស់លោកគឺៗថា <លោកបាន>ស្ដាប់វិទ្យុ <លោកថាខ្មែរក្រហម>តែងតែ<កើតសរសើរ>ខ្លួនឯង <គេ>ថា <គេបាន>បង្កើតមធ្យោបាយមួយដឹកនាំប្រទេសដែលពិភពលោកទាំងមូលនឹងដើរតាមកម្ពុជាប្រជាធិបតេយ្យ។ កម្ពុជា គឺជួរមុខពាក់ព័ន្ធទៅនឹងការតស៊ូបដិវត្តន៍ដើម្បីឲ្យមានការរីកចម្រើនជឿនលឿននេះ នេះទី១។ ទី២ ពាក្យស្លោកដែលយកចេញមកពីសៀវភៅក្រហមរបស់ ម៉ៅ ដែលខ្ញុំបានជម្រាបថា <បាឋកថាសាធារណៈដំបូងរបស់ខ្ញុំ គឺ>ខ្ញុំ<ធ្វើទៅលើប្រធានបទ>ពាក្យស្លោកខ្មែរក្រហម <និងកូនសៀវភៅក្រហម>របស់ ម៉ៅ។ <>ក្នុងពេលនោះ ខ្ញុំយល់ឃើញថា សៀវភៅក្រហមរបស់ -- កូនសៀវភៅក្រហមរបស់ ម៉ៅ <ដែលបោះពុម្ពនៅចុងទសវត្សរ៍៦០ បានជ្រាបចូលទៅក្នុងមនុស្សលើ>ពិភពលោករាប់លាននាក់ មិនមែនតែត្រូវបានយកមកប្រើប្រាស់ដោយតែខ្មែរក្រហម <នោះទេ>។ គឺថា វាពាក់ព័ន្ធទៅនឹងបញ្ហាចិត្តសាស្ត្រមួយដ៏ជ្រាលជ្រៅ។ ពាក្យស្លោកមួយទៀត គឺអង្គការ គឺថាតើ<>ប្រទេស<ហ្នឹងត្រូវបានចាត់ចែង>ដោយរបៀបណា។ អង្គការគឺជាប្រភពនៃអំណាចទាំងអស់។ ដូច្នេះខ្ញុំប្រមូលពាក្យស្លោកទាំងអស់ហ្នឹង ពាក់ព័ន្ធនឹងការយល់ឃើញ ថាតើអង្គការឆ្លាតប៉ុនណា ហើយថាតើគេដឹកនាំប្រទេសជាតិនៅក្នុងប្រទេសកម្ពុជាដោយរបៀបណា។ និងបន្ទាប់មកទៀត <គឺការ>តាមប្រមាញ់ខ្មាំង។ <ចំណុចនេះអាចឲ្យខ្ញុំយល់ថា តើគេបែងចែកខ្មាំង>ដោយរបៀបណា ហើយខ្មាំងត្រូវបានគេចាត់ចំណាត់ថ្នាក់ដោយរបៀបណា ហើយមានអ្វីកើតឡើងទៅ<លើ>អ្នកដែលគេចាត់ទុកថាខ្មាំង។ ហើយបើគេចាប់មក តើគេធ្វើទារុណកម្មដោយរបៀបណា។

[១៣:៤១:២៧]

**ស៖** សុំទោស ដែលខ្ញុំកាត់រំខានលោក។ សំណួររបស់ខ្ញុំ គឺចង់ឲ្យលោកបញ្ជាក់តាមដែលអាចធ្វើទៅបាន។ លោកបានបញ្ជាក់អះអាងថា <>ពាក្យស្លោក<នោះបង្ហាញឲ្យឃើញច្បាស់អំពី>គោល-នយោបាយ<កម្ពុជាប្រជាធិបតេយ្យ ដោយមិនបានសិក្សាទូលំទូលាយទៅលើអត្ថបទនៅក្នុង>ទស្សនា-វដ្ដីបដិវត្ត ក៏ដូចជាទស្សនាវដ្ដីយុវជនយុវនារីផងដែរ។ តើត្រឹមត្រូវដែរទេ?

**ឆ៖** <តើហេតុអីបានជា>ឯកសារទង់បដិវត្ត និងទង់យុវជន-យុវនារី គឺជាប្រភពចម្បង ស្តីអំពីគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ? ខ្ញុំបានសិក្សា និងអានរបាយការណ៍<យ៉ាងច្រើនអំពី>វិទ្យុខ្មែរក្រហម នេះប្រភពមួយ។ ហើយការសិក្សាស្រាវជ្រាវក្នុងវិស័យណាក៏ដោយ គឺយើង<ប្រើការ>សិក្សាស្រាវជ្រាវ<របស់អ្នកផ្សេងទៀតផងដែរ។ ដូច្នេះហើយយើងប្រើប្រភពបន្ទាប់បន្សំ ឬប្រភពទី២> ហើយតាមរយៈភាពឆ្លាតវាងវៃ គឺថាយើង<>វិភាគទៅលើប្រភព<ប្រហាក់ប្រហែលខុសៗគ្នា ឬក៏យើង>រកប្រភពថ្មីមួយទៀត។ អ៊ីចឹង<ខ្ញុំគ្រាន់តែធ្វើឡើង>តាមរយៈអ្នកនិពន្ធមុនៗនេះ ដូចជា ដេវីដឆេនឌ័ល័រ និយាយអំពី "សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជាជាដើម"។

**ស៖** ខ្ញុំសូមបញ្ជាក់ចំណុចខ្ញុំ ដោយលើកយកឧទាហរណ៍ជាក់ស្តែងមួយមក។ គឺៗថា យើងបានលើកយកមកនិយាយហើយ អំពីពាក្យស្លោកពីប្រទេសចិនមួយ និយាយអំពី "ទុកមិនចំណេញ ដកចេញមិនខាត"នេះ។ ឥឡូវយើងនិយាយពាក់ព័ន្ធទៅនឹងកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធទៅនឹងប្រជាជនថ្មី ឬក៏ប្រជាជន១៧មេសា ជាពិសេស នៅជំពូក៥នៃសៀវភៅរបស់លោក ដែលលោកនិយាយពី<ពាក្យស្លោករបស់>ប្រជាជនថ្មី ឬក៏ប្រជាជន១៧មេសា ដែលអង់គ្លេស គឺ <209>, ទំព័របារាំង <170> គឺ <សៀវភៅរបស់លោក> <E3/2812> ដែលសុភាសិតនេះ គឺ 209 លេខរៀង209 ថា "ប្រជាជន១៧មេសា គឺថាជាជនបញ្ញើក្អែក។ គំនិតដែលនិយាយថា ជនបញ្ញើក្អែកនេះ គឺនិយាយពាក្យពេចន៍ដែលចម្លងពី ម៉ៅ ឬ ស្តាលីន ដែលពាក់ព័ន្ធទៅនឹងក្រុមអ្នកនយោបាយដែលត្រូវតាមដានយ៉ាងជិតដិត និងត្រូវកម្ចាត់ចោល។ ឥឡូវ សូមចាប់ផ្តើមជាមួយនឹងពាក្យ "ប្រជាជន១៧មេសា"។ ពាក្យនេះ មិនមានសរសេរនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ឬក៏នៅក្នុងទស្សនាវដ្តីយុវជន-យុវនារីបដិវត្ត ឬក៏នៅក្នុងសារព័ត៌មាន *ហ្វីប៊ីស* ទេ។ ដោយសារតែក្នុងឯកសារទាំងអស់នេះ និយាយតែប្រជាជនថ្មីទេ អត់និយាយប្រជាជន១៧មេសាទេ។ លោកបានប្រភពពាក្យថា "ប្រជាជន១៧មេសា" នេះមកពីណាដែរ?

[១៣:៤៤:៥៦]

**ឆ៖** អ្នក១៧មេសា ឬក៏ -- គឺជាពាក្យមួយដែលគេប្រើជាទូទៅក្នុងការកំណត់ឈ្មោះប្រជាជនថ្មីនេះឯង។ ពាក្យ "១៧មេសា" ប្រជាជនគេនិយាយនៅទូទាំងប្រទេសហើយ ហើយការសិក្សាស្រាវជ្រាវរបស់ខ្ញុំ គឺសំអាងទៅលើអ្វីដែលប្រជាជនធ្លាប់និយាយ កំពុងនិយាយ តើប្រជាជនយល់យ៉ាងដូចម្តេចអំពីរបបនោះ? ហើយ<វាមិន>យោងទៅលើសៀវភៅរបស់អ្នកសិក្សាស្រាវជ្រាវ<នោះទេ។ វាផ្អែកទៅលើ>ការសិក្សាស្រាវជ្រាវនៅថ្នាក់មូលដ្ឋាន ក៏ដូចជាការសិក្សាស្រាវជ្រាវអំពីមនុស្សសាស្ត្រនេះផងដែរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សូមកាត់រំខាន។ អ៊ីចឹងពាក្យ “១៧មេសា” នេះមិនអាចរកឃើញនៅក្នុងឯកសារបោះពុម្ពជាអក្សរណាមួយទេឬ?

**ឆ៖** បាទ មិនមែន -- នេះមិនមែនជាជម្រើសរបស់ខ្ញុំដែលត្រូវរកពាក្យនេះ ពីឯកសារទាំងនេះទេគឺនិយាយប្រភពរបស់ខ្ញុំ គឺចង់ដកស្រង់ចេញពីការចងចាំនៅក្នុងខួរក្បាលរបស់ប្រជាជនផ្ទាល់តែម្តង។

<**ស៖** មីក្រូហ្វូនមិនទាន់បើកទេ ប៉ុន្តែខ្ញុំឮលោកនិយាយថា “ខ្ញុំមិនខ្វល់ទេ” តើត្រឹមត្រូវទេ?>

<**ឆ៖** ត្រឹមត្រូវហើយ។>

**ស៖** ឥឡូវខ្ញុំចូលទៅដល់ខ្លឹមសារនៃពាក្យស្លោក ដែលថា អ្នក១៧មេសា គឺជាជនបញ្ញើក្អែក <ឬប្រជាជនថ្មី>។ លោកបានឆ្លើយថា លោកសិក្សាអំពីមនោគមន៍វិជ្ជាម៉ៅយ៉ាងច្បាស់លាស់។ តើពិតដែរទេ ដែលថាបក្សកុម្មុយនីស្តកម្ពុជា បានប្រើពាក្យប្រជាជន<>ថ្មី <ដែលបញ្ជាក់>ថា ពាក្យ “ប្រជាជនថ្មី” នេះ គឺថាមិនចាត់ទុកអ្នកទាំងអស់នេះជាខ្មាំងទេ ដោយសារពាក្យចិន -- ចម្លងយកមកពីពាក្យចិនប្រើ ពាក្យ “ប្រជាជន” នេះដែរ ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំដូចជាយល់សំណួរលោកមិនបានច្បាស់លាស់ទេ។ អ្វីដែលខ្ញុំដឹងនោះ គឺថាគោលនយោ--នៅក្នុងគោលនយោបាយ<>កម្ពុជា<ប្រជាធិបតេយ្យ>ហ្នឹង គឺថាភាគច្រើន គឺខ្ចី ឬក៏ថាចម្លងចេញមកពីចិនទេ ដូចជាពាក្យ “មហាលោតផ្លោះ មហាអស្ចារ្យ” <និងបដិវត្តន៍វប្បធម៌>នេះជាដើម <ប៉ុន្តែគេបានបន្ថែមគំនិតផ្ទាល់ខ្លួនគេដែរ>។ ហើយគំនិតយោបល់នៃការបែងចែក<ប្រទេស>ទៅជាពីរវណ្ណៈ<ត្រកូល។ ពួកគេបានលុបបំបាត់>វណ្ណៈ<សង្គមជាច្រើនចោល ប៉ុន្តែក៏បានបង្កើតវណ្ណៈត្រកូលវិញ។ ភាពខុសគ្នារវាងវណ្ណៈត្រកូល និងវណ្ណៈសង្គម គឺថាមានសង្គមចល័ត។ តាមរយៈការរស់នៅ ឬការឆ្លងកាត់ជំនាន់មួយទៅជំនាន់មួយ វណ្ណៈសង្គមគេអាចផ្លាស់ប្តូរបាន ប៉ុន្តែវណ្ណៈត្រកូល គំនិតនេះគឺចេញមកពី>ឥណ្ឌា<ដូចដែលយើងដឹងហើយ។> បើសិនណាយើងកើតមកក្នុងវណ្ណៈ<ត្រកូល>ណាមួយ<ជាក់លាក់> ដូរវណ្ណៈហ្នឹងអត់បានទេ។ អ៊ីចឹង របបខ្មែរក្រហមបើថាអ្នកឯងជាប្រជាជនថ្មី ឬក៏អ្នក១៧មេសា គឺថាត្រូវតែៗ តម្រង់ខួរក្បាលអ្នកទាំងនោះ ត្រូវតែអប់រំដើម្បីឲ្យអ្នកទាំងអស់នោះ ក្លាយទៅជា -- ដូចប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន។ <បើតាមទ្រឹស្តី នេះគឺជាករណីមួយ ហើយ>សូម្បីតែចុងបញ្ចប់នៃរបបនេះ<មានការចេញបញ្ញត្តិថា ការបែងចែកវណ្ណៈត្រកូលនោះ> គឺលែងប្រើតទៅទៀតហើយ។ <ការបែងចែកវណ្ណៈត្រកូលនេះគឺពិតជាហួសហេតុណាស់>។ <ឧទាហរណ៍វាតម្រូវឲ្យមានការរៀប-ការ ហើយយើងអាចរៀប>ការបានតែជាមួយនឹងប្រភេទវណ្ណៈ<ត្រកូលដូចគ្នា។ ប្រជាជនបដិវត្តន៍

រៀបការជាមួយប្រជាជនបដិវត្តន៍ ឯអ្នកដែលមិនមែនជាជនបដិវត្តន៍ រៀបការជាមួយអ្នកដែលមិនមែនជាជនបដិវត្តន៍។ រឿងនេះច្បាស់លាស់ណាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយពិតជាប្រឆាំងនឹងសមភាពជា>មូលដ្ឋាន<ខ្លាំងណាស់>។ <សេរីភាព សមភាព និងភាតរភាព គឺជាអ្វីដែលយើងជឿថា នៅប្រទេសបារាំង គឺជាការសើចចំអកចំពោះ>ការបែងចែក<>ប្រជាជន១៧មេសា <និង>ប្រជាជនចាស់ ឬក៏ខ្លះគេហៅថា <>ប្រជាជន ១៨មីនា។ <ហេតុអ្វី>គេហៅ<>ថា "ប្រជាជន១៨មីនា" <គឺពេលនោះហើយដែលសម្តេចសីហនុបាត់បង់អំណាច>នៅឆ្នាំ១៩៧០ <ដូច្នេះ អ្នកដែលបានចូលរួមចលនាបដិវត្តន៍ភ្លាមៗ>នោះ<គឺប្រជាជនចាស់ នៅថ្ងៃ១៨ មីនា ឆ្នាំ១៩៧០។ ដូច្នេះយើងមានវណ្ណៈត្រកូលពីរខុសគ្នានេះ គឺ១៧ មេសា និង១៨មីនា>។

[១៣:៤៩:៤៧]

**ស៖** ខ្ញុំយល់ឃើញថា លោកកំពុងតែយល់ច្រឡំហើយ។ ដូចនៅប្រទេសចិនយើងដឹងហើយ គេហៅថា សាធារណរដ្ឋប្រជាមានិតចិន។ បើសិនយើងសំដៅទៅលើមនុស្សក្រុមណា<មួយ> អ៊ីចឹងគេមិនចាត់ទុកអ្នកនោះជាខ្មាំងទេ ពីព្រោះ<ប្រជាជននៅក្នុង>មនោគមន៍វិជ្ជាកុម្មុយនីស្តដូចជាមនោគមន៍វិជ្ជា ម៉ៅ សេទុង នេះជាដើម គឺ<ជាអ្វីដែល>បដិវត្តន៍ធ្វើ<សម្រាប់ពួកគេ>។ របបកុម្មុយនីស្តណាមួយក៏ដោយ តែកាលណាគេហៅប្រជាជន ទោះជាប្រជាជនថ្មីក្តី ក៏នៅតែជាប្រជាជន។ អ៊ីចឹងធ្វើបដិវត្តន៍ គេនៅតែហៅប្រជាជនទាំងអស់គ្នា។ អ៊ីចឹងហើយបានជាខ្ញុំយកពាក្យនេះមកសួរ ថាបើមានប្រជាជនថ្មីអ៊ីចឹង យ៉ាងម៉េចដែរ គេហៅប្រជាជនដដែលតើ?

**ឆ៖** នេះជាការបកស្រាយរបស់លោកហើយ។ ខ្ញុំមិនបកស្រាយដូចលោកយ៉ាងដូច្នេះទេ។

**ស៖** ឥឡូវខ្ញុំសួរទៅលោកនូវអ្វីដែល ប៉ុល ពត និយាយដោយផ្ទាល់<នៅពេលដែលឧបនាយករដ្ឋមន្ត្រី>ចិន <ចេន យុងគី> មកកាន់ប្រទេសកម្ពុជា<នៅថ្ងៃទី១ មករា។ ហើយវាឆ្លើយតបទៅនឹងអ្វី>ដែល<លោក>និយាយ<ថា> អង្គការគឺជាព្រះ។ គឺឯកសារ E3/1783, ERN អង់គ្លេស <0049 8181>, បារាំង <00606766>, ខ្មែរ 00659261។ គឺពាក់ព័ន្ធទៅនឹង<គេនិយាយរឿងមួយ>ថា<>ព្រះ<សង្ឃ>ពុទ្ធសាសនា<ធ្លាប់>និយាយថា<>មានតែព្រះទេ ទើប<អាចទប់>ទំនប់ស្ទឹងជីនិតនោះបាន <ហើយបន្ទាប់មកមានពាក្យនិយាយថា {ឥឡូវនេះទំនប់នៅទីនោះហើយ ហើយប្រជាជនចាស់ជាច្រើនបានមកមើលវា>។ ដូចដែលលេខបក្ស ប៉ុល ពត បាននិយាយយ៉ាងច្បាស់ហើយ សូមដកស្រង់ "ប្រជាជនខ្លួនឯងហ្នឹងហើយគឺជាព្រះ"} បញ្ចប់ការដកស្រង់។ នេះ ត្រង់នេះ លោកឃើញហើយគឺថា

ប៉ុល ពត គាត់អមដំណើរប្រតិភូចិន ហើយគាត់និយាយថា ប្រជាជនថ្មី ក៏ជាប្រជាជនដែរ ហើយប្រជាជនហ្នឹងហើយ គឺជាព្រះ។ លោកយល់ដូចម្ដេច?

**ឆ៖** គួរឲ្យចាប់អារម្មណ៍មែនអ្វីដែលលោកលើកឡើងមក។ នេះ គឺជាទ្រឹស្ដីរបស់អង្គការ ឬមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដូច នួន ជា បានលើកឡើងហើយ គឺថា កសិករតែងតែ<>បួងសួងឲ្យមានភ្លៀងធ្លាក់<នៅមុន ឬក្រោយរដូវរាំងស្ងួត ហើយ នួន ជា បាននិយាយថា “ជាជាង>បួងសួងសុំទេវតាឲ្យបង្អុរទឹកភ្លៀងមក <ជាការប្រសើរត្រូវ>ជីកប្រឡាយ <លើកទំនប់ ដូច្នេះហើយប្រជាជនមានការប្រឹងប្រែងផ្ទាល់ខ្លួន ធ្វើការដោយខ្លួនឯង ហើយមានទឹកច្រើន និង>ទទួលបានផ្លែផ្កាល្អ”។ <ដូច្នេះហើយអត់មានអ្វីអាចជំទាស់បានទេ។ អត់មានបញ្ហាអីទេ។>

[១៣:៥៣:០៨]

**ស៖** បាទ ឥឡូវនេះ យើងនៅផ្ដោតនិយាយអំពីខ្មាំងនៅឡើយទេ។ ហើយនៅថ្ងៃទី២ ម៉ោង ០៩:១៨នាទីព្រឹក លោកបានឆ្លើយថា ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ខ្មាំងហ្នឹង ជួនកាលក៏គេហៅថាជាពួកដង្កូវដែរ។ <លោកថា ប្រជាជន១៧ មេសា ត្រូវបានគេចាត់ទុកថាជា>បញ្ញើក្អែក <ហើយនៅក្នុង>ឯកសារ<របស់លោក> “ខ្មែររូស៍ ហ្គូឡាក់” គឺE3/2811, ERN ជាភាសាអង់គ្លេស 00394609, ខ្មែរ 00822600, បារាំង <00796286> គឺលោកសរសេរសំដៅពាក្យថា “ខ្មាំង” ដោយយោងសុន្ទរ-កថារបស់ ប៉ុល ពត ដែលគាត់ប្រើពាក្យថា ជាមេក្រុម។ <សូមដកស្រង់> “ទោះបីជាយើងទទួលបានមហាជ័យជម្នះ<លើ>ពួកមីក្រុប<ក៏ដោយ ក៏>ពួក<នេះ>នៅតែ<បន្តសាយកូនចៅ ដូចជំងឺមហារីកហើយសមាសធាតុប្រតិកិរិយាតែមួយ ឬពីរភាគរយ ហាក់ដូចជាមិនដែលត្រូវបានកម្ចាត់ឲ្យអស់ទេ ទោះបីជាមានការបង្រ្កាបជាបន្តបន្ទាប់ក៏ដោយ>។ តើលោកនៅចាំថា លោកនេះ បានសរសេរពាក់ព័ន្ធទៅនឹងមេរោគ ឬក៏មីក្រុបនេះដែរទេ?

**ឆ៖** បាទ ពិតហើយខ្ញុំបានសរសេរចំណុចនេះ។ នៅក្នុងសៀវភៅចុងក្រោយរបស់ខ្ញុំ *“ពួកវ័រ ឡេ ខ្មែររូស៍”* នេះគឺថា ខ្ញុំសរសេរជាច្រើនទំព័រ ពាក់ព័ន្ធទៅនឹងរូបភាព ការសម្ដែងអត្តន័យរបស់ខ្មែរក្រហមពាក់ព័ន្ធទៅនឹងការបោសសម្អាតនេះឯង។ ពាក្យនេះ គឺខ្ញុំយកចេញមកពីសំណេររបស់លោក ស្ទីវ ហេដឌ័រ ខ្ញុំសរសេរកន្លះទំព័រដែរ ពាក់ព័ន្ធទៅនឹងការរំលោភបំពាន គឺការរំលោភបំពានទៅលើអ្នកដែលគេចាត់ទុកថាជាខ្មាំង ហើយខ្ញុំក៏សរសេរកន្លះទំព័រដែរថា របៀបបោសសម្អាតខ្មាំងធ្វើម៉េច គឺថាបោសសម្អាតឲ្យជ្រះស្រឡះជាដើម។ល។ មិនមែនតែខ្ញុំម្នាក់ទេដែលនិយាយអំពីចំណុចនេះ គឺថាអ្នកនិពន្ធច្រើនណាស់

គឺសរសេរអំពីចំណុចនេះ។ <ខ្ញុំជឿថាអ្នកទាំងអស់គ្នាមានឯកសារនោះហើយ។ ហើយបើសិនជាចង់បានបញ្ចើពេញនោះ> ខ្ញុំ<បានយក>សៀវភៅ<មក>ច្រើន <ប៉ុន្តែខ្ញុំអត់មាន>សៀវភៅថា *"ពួគ័រ ឡេ ខ្មែររូស៍"* <ទេនៅទីនោះ។> ខ្ញុំមិនអាច<ផ្តល់>លេខទំព័រ<>យោងឲ្យបានច្បាស់លាស់នាពេលនេះបានទេ។ ប៉ុន្តែបញ្ជាក់ថា ឃ្លាប្រយោគនេះ មានសរសេរនៅក្នុងសៀវភៅបោះពុម្ពផ្សាយខ្ញុំទាំងពីរលើកនេះមែន។

[១៣:៥៦:១០]

**ស៖** តើ<ការ>ប្រើពាក្យជា មេរោគ ជាជំងឺមហារីក <ជាបញ្ចើក្អែក គឺជាអ្វីដែល>លោកគិតថា<>ជា "ពាក្យស្លោក<>សម្តែងឲ្យឃើញ<>ច្បាស់ចំពោះគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា" យ៉ាងដូច្នោះមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។ មុននឹងកម្ចាត់ប្រជាជន <គេត្រូវតែដកចេញពីមូលដ្ឋានមនុស្សជាតិ។ ពួកគេជាសត្វចម្លែក។ ពួកគេជាសត្វល្អិត>។ <>ពួក<គេជា>ឈ្លើងជញ្ជក់ឈាមជាដើម។ល។

**ស៖** ខ្ញុំសូមទី១ អានឲ្យលោកស្តាប់សិន ហើយសួរមើល ថាតើលោកមានប្រតិកម្មយ៉ាងដូចម្តេច យល់យ៉ាងដូចម្តេចដែរ។ គឺថា<នេះជាការដកស្រង់> "យើងនឹង<បន្ត>បោសសម្អាតកម្ចាត់វីរុសមេរោគទាំងអស់នេះ<ពីគ្រប់ស្ថាប័នរដ្ឋ>ទាំងអស់ <ព្រោះមេរោគនេះបានរីករាលដាលហើយ>។ ក៏ប៉ុន្តែជាអកុសល គឺថាមេរោគនេះក៏ដូចជាមហារីកដែរ វាចេះតែរីករាលដាលនៅទូទាំងប្រទេសតែម្តង។" បញ្ចប់ការដកស្រង់។ តើលោកដកស្រង់សម្រង់នេះ ជាក់លាក់នេះ ចេញមកពីណាដែរ?

**ឆ៖** សូមទោស ខ្ញុំអត់ចាំទេលោក។

**ស៖** ប៉ុន្តែស្តាប់ទៅ វាដូចជាពាក្យស្លោកដែលគេលើកឡើងសម័យខ្មែរក្រហមដែរឬទេ?

[១៣:៥៨:០២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នៅពេលដែលសាក្សីគិត សូមឯកសារយោងមក មេធាវី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បន្ទាប់ពីសួរសំណួរហ្នឹងហើយ ខ្ញុំនឹងផ្តល់នូវឯកសារយោងនៃសម្រង់មួយនេះ។ គឺថាពាក្យស្លោកមួយនេះ គឺជាការបង្ហាញយ៉ាងច្បាស់អំពីគោលនយោបាយកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**លោក ហង់រី ឡូកា៖**

**ឆ៖** បាទ ការពិតទៅការដកស្រង់នេះ មិនមែនជាពាក្យស្លោកអីនោះទេ វាគ្រាន់តែសុន្ទរកថា ឬក៏ការលើកយោបល់ ដែលវាជាផ្នែកមួយនៃបុគ្គលណាម្នាក់ដែលមានសិទ្ធិនៅសម័យនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ការពិតទៅវាត្រឹមត្រូវហើយ។ ខ្ញុំសុំបង្ហាញថា វាជាការដកស្រង់កាលពីពីរសប្តាហ៍មុន នៅពេលដែល<ប្រធានាធិបតី អេឌូហ្គាន និយាយទៅកាន់បក្សប្រឆាំងនៅប្រទេសទួរគី។ សូមអរគុណ>។

[១៣:៥៩:០៦]

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះអ្នកជំនាញ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

ជម្រាបសួរលោក ហង់រី ឡូកា! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្តពីសហភាតារបស់ខ្ញុំ។ សូមលោកប្រយ័ត្នប្រយែង បន្តិច ព្រោះថាយើងនិយាយជាភាសាបារាំងទាំងពីរនាក់។ អ៊ីចឹងសុំឱ្យលោកទុកពេលឱ្យអ្នកបកប្រែផង ហើយខ្ញុំក៏ព្យាយាមសួរឱ្យបានយឺតៗ ទុកពេលឱ្យអ្នកបកប្រែបានបកប្រែទាន់។

**ស៖** ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកសួរលោកដោយសង្ខេបពាក់ព័ន្ធទៅនឹងជម្រើសមួយដែលលោកបានធ្វើឡើងពាក់ព័ន្ធនឹងការស្រាវជ្រាវទៅលើប្រជាជនថា តើគាត់យល់<យ៉ាងណា>អំពីគោលនយោបាយរបស់កម្ពុជា ប្រជាធិបតេយ្យ តាមរយៈពាក្យស្លោកនោះ។ ដូចមេធាវីការពារក្តីលោក នួន ជា បានរៀបរាប់លម្អិតរួចមកហើយ ហើយយើងក៏បានឃើញនៅក្នុងសៀវភៅរបស់លោកផងដែរ ជាពិសេសសៀវភៅ កូនសៀវភៅក្រហមរបស់ ប៉ុល ពត ហើយនិងសៀវភៅ *"ពួក័រ ឡេ ខ្មែររូស៍"* ក៏ដូចជាអត្ថបទផ្សេងៗទៀតហ្នឹង ខ្ញុំចង់ដឹងថាលោកមានប្រភពអ្វីខ្លះ ជាពិសេសពាក់ព័ន្ធនឹងឯកសារពីសម័យនោះ។ ហើយនៅក្នុងទស្សនាវដ្តីទង់បដិវត្ត តាមលោក -- លោកក៏បានដកស្រង់ផងដែរ នៅក្នុងសៀវភៅ *"ពួក័រ ឡេ ខ្មែររូស៍"* របស់លោក។ នៅក្នុងសៀវភៅ *"ពួក័រ ឡេ ខ្មែររូស៍"* នៅក្នុងកំណត់សម្គាល់ លោកបានរៀបរាប់សៀវភៅមួយចំនួន ដូចជាសៀវភៅខ្មៅ ហើយលោកដាក់ថា ប៉ុល ពត ជាអ្នកនិពន្ធ។ ដូច្នេះ ខ្ញុំ

ចង់ដឹងថា តើ<នេះជា>សៀវភៅខ្មៅដែលមាននៅក្នុងសំណុំរឿងយើងហ្នឹង គឺឯកសារ E3/23 ហ្នឹងឬក៏យ៉ាងម៉េច ដែលបង្ហាញអំពីសកម្មភាពឈ្លានពានវាតទីរបស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យនោះ។

ដូច្នេះ លោកប្រធាន ខ្ញុំសុំការអនុញ្ញាតឲ្យមន្ត្រីតុលាការប្រគល់ទំព័រដំបូងនៃសៀវភៅខ្មៅនេះជូនទៅសាក្សីជំនាញ ដើម្បីឲ្យគាត់មើល ថាតើសៀវភៅហ្នឹងជាសៀវភៅ<ដែលគាត់បានដកស្រង់នោះឬ>?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៤:០២:០០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** គឺទំព័រទី១នៃសៀវភៅខ្មៅ។ សៀវភៅហ្នឹងមែនទេ ដែលជាសៀវភៅដែលលោកបានដកស្រង់យកមកសរសេរនៅក្នុងសៀវភៅរបស់លោកហ្នឹង ហើយឯកសារខ្មៅហ្នឹង គឺចេញមកពីក្រសួងការបរទេស?

**លោក ហង់រី ឡូកា៖**

**ឆ៖** បាទ ពិតហើយគឺសៀវភៅហ្នឹងហើយ។ ខ្ញុំក៏មានសៀវភៅថតចម្លងទាំងស្រុងដែរ នៅក្នុងកំណត់ត្រារបស់ខ្ញុំនៅកម្ពុជា។ ប៉ុន្តែមិនមែនគ្រឹះស្ថានបោះពុម្ពផ្សាយដូចគ្នាទេ គឺកាលនោះ គឺបោះនៅបារាំងទេ។ កាលខ្ញុំមានហ្នឹង មិនមែនជា ចំជាសៀវភៅតែម្តងទេ តែជាអត្ថបទវែងមែនទែន ដែលត្រូវបានបោះពុម្ពផ្សាយ ហើយគេផ្សាយថា ប៉ុល ពត ហ្នឹងជាម្ចាស់ ជាអ្នកនិពន្ធសៀវភៅហ្នឹង។

**ស៖** អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់បន្ថែម។ លោកបាននិយាយអំពី អេហ្វ.ប៊ី.អាយ.អេស (ហ្វីប៊ីស) ដែលយើងបានប្រើឯកសារជាច្រើនរបស់ហ្វីប៊ីសនេះនៅក្នុងអង្គជំនុំជម្រះនេះ។ ដូច្នេះ ខ្ញុំចង់សួរសំណួរដំបូងពាក់ព័ន្ធនឹងការផ្សព្វផ្សាយតាមវិទ្យុ ហើយដែលជនបរទេសបានស្តាប់ឮ។ តើលោកឯកភាពជាមួយខ្ញុំទេថា ការផ្សព្វផ្សាយតាមវិទ្យុនេះ គឺជាការឃោសនា ឬជាសុន្ទរកថាដែលផ្សាយជូនជនរួមជាតិក្នុងពេលបុណ្យផ្សេងៗ ក៏ដូចជា ផ្សាយជូនជនបរទេសដែលស្តាប់ព័ត៌មានតាមរយៈវិទ្យុសំឡេងកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ពិតណាស់ការផ្សាយតាមវិទ្យុ ទាំងអស់នេះគឺជាឧបករណ៍ឃោសនារបស់ខ្មែរក្រហម ជា

ពិសេសសម្រាប់ជនបរទេសនិងកម្មាភិបាលបក្ស។ ប្រជាជនទាំងមូល ក្នុងឱកាសមីទ្ទិងម្តងម្កាល ពួកគេអាចស្តាប់ឮផងដែរ នូវការផ្សព្វផ្សាយខ្លីៗ ក៏ប៉ុន្តែជាទូទៅប្រជាជនមិនបានស្តាប់វិទ្យុរបស់របបនោះទេ។ អ្នកនៅក្រសួងឃោសនាការ និងព័ត៌មានជាអ្នកទទួលខុសត្រូវក្នុងការផ្សព្វផ្សាយទាំងអស់នេះ។ ខ្ញុំដឹងថា ស្នួង ស៊ីគឿន គាត់ក៏បានធ្វើការពាក់ព័ន្ធនឹងការផ្សព្វផ្សាយវិទ្យុនេះដែរ។ ការផ្សព្វផ្សាយនេះ គឺជាការនាំឱ្យមានការបកប្រែយ៉ាងធំធេង ពីព្រោះថាភាសាដើមជាភាសាខ្មែរ អ៊ីចឹងត្រូវបកប្រែជាភាសាបារាំង ជាភាសាអង់គ្លេស ឬជាភាសាផ្សេងទៀត។ ដូច្នេះ នេះជាការងារធំធេងសម្បើមណាស់របស់ក្រសួងការបរទេស ក៏ដូចជាក្រសួងឃោសនាការនិងព័ត៌មាន។ ប្រជាជន គឺស្តាប់ឮតិចតួចណាស់ពីការផ្សាយសំឡេងទាំងអស់ហ្នឹង។

**ស៖** ដូច្នេះពាក់ព័ន្ធនឹងបញ្ហាឯកសារជាច្រើននៅសម័យនោះ ដែលលោកបានប្រើប្រាស់នៅក្នុងការស្រាវជ្រាវផ្សេងៗរបស់លោក <ជាពិសេសគឺចម្លើយរបស់សាក្សីពាក់ព័ន្ធនឹង>ពាក្យស្លោក ក៏ដូចជា <ឯកសារ>ផ្សេងៗ<ដែលបានមកពីសម័យកាលនោះ វាជាការឃោសនាដ៏សំខាន់>ដែលកម្ពុជាប្រជាធិបតេយ្យផ្សព្វផ្សាយទៅបរទេស។ ដូច្នេះលោកឯកភាពជាមួយខ្ញុំទេថា លោកបានធ្វើការតិចតួចណាស់ពាក់ព័ន្ធទៅនឹងឯកសារសម្ងាត់ដែលមានទំនាក់ទំនងនឹងរបបនោះ ហើយវាមិន<ស្ថិតនៅក្នុងជំនាញ>របស់លោកទេនៅក្នុងការស្រាវជ្រាវរបស់លោកនោះ?

[១៤:០៥:៥២]

**ឆ៖** ពិតជាអ៊ីចឹងហើយលោកស្រីមេធាវី ដោយសារថាអ្នកដែលធ្វើការពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យដូចជា ដេវីដ ឆេនដ៍ល័រ និង ស្ទីវ ហេដឌ័រ ជាដើម ពួកគាត់បានប្រើប្រាស់ប្រភពទាំងអស់នេះហើយ ជាពិសេស ដេវីដ ឆេនដ៍ល័រ បានបោះពុម្ពសៀវភៅមួយគឺ *"ប៉ុល ពត ផ្តែន ឌឺ ហ្វូធើរ –* ប៉ុល ពត រៀបចំផែនការអនាគត"។ <ហើយនៅក្នុងនោះ យើងមាន>ឯកសារមួយចំនួន ដែលពន្យល់អំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យជាភាសាអង់គ្លេស។ នេះជាប្រភពសំខាន់ វាមានទំហំធំធេងគួរសមដែរ ហើយនៅក្នុងនោះមាន<ប្រភពទីពីរទៀត។ ដូច្នេះខ្ញុំអាចប្រើ>ការបកប្រែជាភាសាអង់គ្លេស<របស់ពួកគេបាន។ ការយកចិត្តទុកដាក់របស់ខ្ញុំគឺដើម្បីបង្កើតការងារដែលជាច្បាប់ដើម ហើយមិនចាំបាច់ធ្វើឱ្យជាន់គ្នាទៅនឹងអ្វីដែលគេធ្វើមុនខ្ញុំនោះទេ>។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីការងារស្រាវជ្រាវរបស់អ្នកនិពន្ធផ្សេងៗទៀតដែលចាប់អារម្មណ៍ទៅលើឯកសារចាស់ៗ<របស់ក្រសួងមហាផ្ទៃ>នៅសម័យកម្ពុជាប្រជាធិបតេយ្យ ដែលខ្ញុំនឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ត្រឡប់មកនិយាយអំពីចំណុចនេះនៅពេលបន្តិចទៀតនេះ។ ប៉ុន្តែឥឡូវនេះខ្ញុំចង់សួរបន្ថែមមួយចំនួនទៀតពាក់ព័ន្ធទៅនឹងឯកសារអំពីមន្ទីរសន្តិសុខដែលលោកបានសិក្សាស្រាវជ្រាវនោះ។ ខ្ញុំយល់ត្រឹមត្រូវទេថាពាក់ព័ន្ធនឹងឯកសារជាក្រដាសដែលលោកបានស្រាវជ្រាវនោះ គឺមានតែនៅក្រាំងតាចាន់ទេ ដូចដែលលោកបានទទួលពីមិត្តភក្តិរបស់លោកដែលជាអ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ។ តើអ៊ីចឹងមែនទេ?

[១៤:០៧:៤០]

**ឆ៖** បាទ ពិតណាស់។ យើងចាំបាច់អីទៅធ្វើការងារដែលគេ -- អ្នកដដែលៗ អ្នកស្រាវជ្រាវមួយចំនួនគេធ្វើរួចមកហើយ ដូចជា ដេវីដ ឆេនឌ័ល័រ ជាដើម គាត់បានសរសេរយ៉ាងច្រើនពាក់ព័ន្ធនឹង ស-២១ អ៊ីចឹងខ្ញុំមិនចាំបាច់ធ្វើការងារដដែលដែលគេធ្វើហើយទេ។ នៅពេលដែលខ្ញុំធ្វើការស្រាវជ្រាវ ឬក៏សិក្សាជាលក្ខណៈទូទៅហ្នឹង គឺខ្ញុំធ្វើការសំយោគពាក់ព័ន្ធទៅនឹងឯកសារនៅក្រាំងតាចាន់ ដែលមានជនជាតិខ្មែរជួយខ្ញុំ នេះជាការងារស្រាវជ្រាវរបស់ខ្ញុំដំបូងដែលមាន៤០ទំព័រជាង។

**ស៖** ខ្ញុំមិន -- សួរមិនយោងទៅលើស-២១ទាំងស្រុងទេ គឺខ្ញុំចង់ធៀបទៅលើឯកសារផ្សេងៗទៀត។ ខ្ញុំចង់ដឹងថាលោកមានឯកសារពាក់ព័ន្ធនឹងមន្ទីរសន្តិសុខហ្នឹង គឺមានតែក្រាំងតាចាន់ទេ លោកអត់មានឯកសាររបស់មន្ទីរសន្តិសុខផ្សេងទៀតទេ មែនទេ?

**ឆ៖** ខ្ញុំក៏ទៅស-២១ដែរ។ ខ្ញុំបានថតចម្លងឯកសារជាច្រើនដែលខ្ញុំចាប់អារម្មណ៍ គឺជាពិសេសពាក់ព័ន្ធនឹងជនបរទេស <គឺ>ជនជាតិអាមេរិកាំង<ពីរនាក់។> ខ្ញុំក៏<បានមើល>ឯកសាររបស់ តាយ៉ាគាត់មកពីព្លៃសាន គឺរតនគិរី។ ដូច្នេះខ្ញុំបានថតចម្លងឯកសារពាក់ព័ន្ធនឹងបុគ្គលមួយចំនួនដែលខ្ញុំស្គាល់។ ខ្ញុំបានស្រាវជ្រាវរក ឯកសាររបស់ ចៅ សេង ដែរ ក៏ប៉ុន្តែទើបតែថ្មីៗនេះទេដែលខ្ញុំដឹងថាចម្លើយសារភាពរបស់ ចៅ សេង ហ្នឹងទៅគេដាក់ឈ្មោះផ្សេងទេ ហើយខ្ញុំក៏ខកចិត្តតិចតួចដែរចំពោះចម្លើយសារភាពរបស់គាត់ ព្រោះថាវាខ្លីពេក ហើយគាត់ថាជាអ្នកស៊ើបការណ៍បារាំង ជាគិញ។ អ៊ីចឹងខ្ញុំមិនដឹងអីច្រើនទេតាមរយៈការអានចម្លើយសារភាពរបស់ ចៅ សេង នោះ។

**ស៖** សូមអត់ទោសផង ខ្ញុំមានពេលខ្លីណាស់ ខ្ញុំនឹងធ្វើដូចភាគីផ្សេងទៀត។ អ៊ីចឹងខ្ញុំព្យាយាម<សួរសំណួរ>ជាក់លាក់បំផុត។ សំណួរខ្ញុំមិនចង់ដឹងថាតើលោកមានបានពិគ្រោះឯកសារនៅ ស-២១ នោះទេ ខ្ញុំគ្រាន់តែចង់ដឹងថាតើក្រៅពីឯកសារនៅមន្ទីរក្រាំងតាចាន់ ដែលលោកបានពិគ្រោះនោះ តើឯកសារណាផ្សេងទៀត ក្រៅពីក្រាំងតាចាន់ហ្នឹង ដែលលោកបានពិគ្រោះដែរនុ៎ង លោកពិគ្រោះតែក្រាំង

តាចាន់ទេ ឬក៏មានឯកសារនៅមន្ទីរសន្តិសុខផ្សេងទៀតដែរ?

[១៤:១០:១៨]

**ឆ៖** ឆ្នាំ៩០ហ្នឹង ខ្ញុំបានស្រាវជ្រាវរកឯកសារ ក៏ប៉ុន្តែខ្ញុំអត់អាចរកឃើញអីទេ។

**ស៖** លោកបានលើកឡើងអំពីការលំបាក ក្នុងការទទួលបានឯកសារចាស់ៗ ពីព្រោះថាឯកសារមួយចំនួនហ្នឹងត្រូវបានកម្ទេចចោលដោយរដ្ឋអំណាចថ្មី ក្រោយពីកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ។ ដូច្នេះខ្ញុំចង់សួរលោកថា នៅពេលដែលលោកនិយាយជាលក្ខណៈទូទៅ ឧទាហរណ៍ ដូចជានៅក្នុងពេលដែលសហព្រះរាជអាជ្ញាសួរលោក លោកថាដំណើរការជាទូទៅ នេះជា នេះខ្ញុំយល់ថា លោកសន្និដ្ឋាននៅទូទាំងប្រទេសតែម្តង គឺថាដំណើរការមន្ទីរសន្តិសុខហ្នឹង គឺមានលក្ខណៈដូចគ្នា គឺមានម្នាក់ជាអ្នកសួរ ម្នាក់ជាអ្នកកត់ត្រា និងម្នាក់ទៀតជាអ្នកវាយដំធ្វើទារុណកម្មអ្នកទោស។ ដូច្នេះខ្ញុំសួរលោកថា នេះជាការសន្និដ្ឋានរបស់លោក តាមរយៈលោកពិគ្រោះឯកសារនៅក្រាំងតាចាន់ និងស-២១ ជាយថាហេតុផងដែរ ឬក៏ជាអ្វីដែលលោកបានដកស្រង់ចេញពីប្រភពណាផ្សេងទៀត? ហើយបើមាន តើប្រភពនុ៎ងប្រភពអីខ្លះ?

**ឆ៖** ខ្ញុំបានមើលឯកសារជាលាយលក្ខណ៍អក្សរ ខ្ញុំមិនមានព័ត៌មានអីច្រើន នូវអ្វីដែលលោកស្រីបានរៀបរាប់ហ្នឹងទេ។ ខ្ញុំមើលតាមរយៈសក្ខីកម្មរបស់ជនរងគ្រោះ អ្នកសួរចម្លើយ ហើយខ្ញុំអាចដឹងបានថាតើវាកើតឡើងយ៉ាងម៉េចនៅពេលគេធ្វើទារុណកម្មហ្នឹង។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គឺ មឿង សុន និងប្រពន្ធរបស់គាត់ មឿង ផល្លី ជាអ្នកផ្តល់នូវព័ត៌មានគន្លឹះមកឲ្យខ្ញុំ ជាអ្នកបើកទ្វារសម្ងាត់ឲ្យខ្ញុំដឹង ដែលគ្មាននរណាម្នាក់ដឹង។ អ៊ីចឹងហើយបានជាខ្ញុំដឹងនៅឆ្នាំ៨៩ ឆ្នាំ៩០។ <នៅឆ្នាំ១៩៩០ ខ្ញុំនៅប្រទេសអង់គ្លេសសម្រាប់រដូវក្តៅ។ ដូច្នេះខ្ញុំមិនបាននៅទីនេះទេ។ ប៉ុន្តែនៅ>ឆ្នាំ៩១ <ខ្ញុំបានមកទីនេះហើយ>ខ្ញុំបានធ្វើដំណើរ<ជាលើកទី១>ទៅជុំវិញបឹងទន្លេសាប។ ហើយ<ជាការយល់ខុសរបស់>ខ្ញុំ<ដែលខ្ញុំ>បាន<ចាត់ទុកថាស្រុកព្រៃនប់ ជាករណីលើកលែង> ហើយខ្ញុំបានរកឃើញថា <នោះគឺជាច្បាប់សម្រាប់គ្រប់ស្រុកទាំងអស់ និងគ្រប់ខេត្ត> ដែលខ្ញុំទៅដល់។

[១៤:១៣:០២]

**ស៖** នៅពេលដែលលោកឆ្លើយទៅនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកថា បើតាមរយៈផ្តែផ្តានៃការស្រាវជ្រាវរបស់លោកទៅលើមន្ទីរសន្តិសុខ គឺមន្ទីរសន្តិសុខហ្នឹង គឺចំណុះឲ្យថ្នាក់ស្រុក។ នេះបើតាមការយល់នូវសក្ខីកម្មរបស់លោក។ ដូច្នេះ លោកអាចបញ្ជាក់បានទេថា លោកបានធ្វើការស្រាវជ្រាវជាក់លាក់អ្វីខ្លះទៅលើអ្នកទទួលខុសត្រូវស្រុកទាំងអស់ហ្នឹង? តើពួកគេឈ្មោះអ្វីខ្លះ

ហើយតើគុកហ្នឹងដំណើរការយ៉ាងម៉េចខ្លះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ពិតណាស់នៅក្នុងកំណត់ត្រារបស់ខ្ញុំ ឬក៏ក្នុងសៀវភៅរបស់ខ្ញុំ ឬក៏នៅក្នុងឯកសារសំយោគ ដែលខ្ញុំបានផ្ដល់ជូនតុលាការ មានឈ្មោះច្រើនណាស់ តានេះ តានោះ ហើយជួនកាលទៅ មានតាជាលេខទៀត ឈ្មោះលេខកូដ។ ហើយឈ្មោះនេះ ភាគច្រើនជាឈ្មោះបដិវត្តន៍ មិនមែនជាឈ្មោះនៅក្នុងបញ្ជីអត្រានុកូលដ្ឋានពិតប្រាកដទេ។ ខ្ញុំមិនមែនជាអ្នកស្រាវជ្រាវរបស់តុលាការទេ ខ្ញុំជាអ្នកស្រាវជ្រាវឯករាជ្យ មិនពឹង មិនស្ថិតនៅក្រោមអំណាចអ្នកណាទេ។ ហើយខ្ញុំបានធ្វើការស្រាវជ្រាវទៅលើគុកនៅពីក្រោយស-២១ នៅពីក្រោយសហករណ៍ ដែលជាកន្លែងឃុំមនុស្ស ក៏ប៉ុន្តែខ្ញុំមិនបានព្យាយាមស្វែងរកឲ្យបានច្បាស់ ថាតើអ្នកណាជាអ្នកទទួលខុសត្រូវ។ ពេលខ្លះទៅ ខ្ញុំបានជួបអ្នកដែលមានឋានៈនយោបាយបច្ចុប្បន្ននេះផងដែរ ដែលពីមុនគាត់ជាកម្មាភិបាលខ្មែរក្រហម។ អ៊ីចឹងខ្ញុំមិនចាំបាច់និយាយអីវែងឆ្ងាយទេ ព្រោះថាអ្នកនៅទីនេះហ្នឹង លោកស្រីដឹងខ្លួនឯងហើយ។ ហើយមេធាវីការពារក្ដី នួន ជា ហ្នឹងក៏លើកឡើងឈ្មោះច្រើនមកហើយ។

ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា ការបង្ក្រាបហ្នឹង ជួនកាលទៅគឺវាមានកើតឡើងទៅលើខ្មែរក្រហមគ្នាឯងផងដែរ។ អ៊ីចឹងជាង៣០ឆ្នាំមកហើយ បើខ្ញុំគិតទៅ គឺ៣៥ឆ្នាំជាងហើយ វាពិបាកណាស់ក្នុងការស្វែងរកមេគុក ឬក៏ចៅហ្វាយស្រុក មេស្រុក ដែលនៅរស់រានមានជីវិតនោះ។ ពីព្រោះថា មានការបោសសម្អាតផ្ទៃក្នុង អ្នកទទួលខុសត្រូវនៅតាមស្រុក ឬក៏គុក ត្រូវបានសម្លាប់ចោល បោសសម្អាតចោលដោយខ្មែរក្រហមគ្នាឯង ហើយឥឡូវនេះ ខ្ញុំគិថា នៅសល់មនុស្សតិចតួចណាស់ គឺស្ទើរតែគ្មានផង។

[១៤:១៥:៥៧]

**ស៖** កាលពីសវនាការថ្ងៃព្រហស្បតិ៍ គឺថ្ងៃទី២៨ ខែមិថុនា <ឆ្នាំ២០១៥>*(ស៊ីក)* គឺក្រោយម៉ោង <១៦:០៤:៥១> វិនាទីបន្តិចលោកបាននិយាយថា "ពិតជាមានឧក្រិដ្ឋជនមួយចំនួនដែលត្រូវបានចាប់ខ្លួន ហើយនិងឃុំនៅមន្ទីរក្រាំងតាចាន់ គឺជាកម្មាភិបាល -- កម្មាភិបាលខ្មែរក្រហម<ដែលបាន>ចោទមនុស្ស<ជា>ច្រើន" សូមបញ្ចប់ការដកស្រង់។ <ខ្ញុំចង់ដឹងថា តើអ្វីដែលនាំឲ្យលោកនិយាយបែបនេះ ហើយតើ>កម្មាភិបាលខ្មែរក្រហមណាដែលចោទមនុស្សច្រើនពេកនោះ?

**ឆ៖** នេះជាអ្វីដែលខ្ញុំសរសេរនៅក្នុងអត្ថបទសំយោគរបស់ខ្ញុំ។ ខ្ញុំគិតថា ដូចជាមានពីរបីនាក់ ហើយ<ខ្ញុំចាំ>ម្នាក់ជាពិសេស គឺប្រហែលជានៅ៧៧ ឆ្នាំ៧៧ ឆ្នាំ៧៨ គឺនៅដំណាក់កាលចុងក្រោយនៃរបបខ្មែរក្រហម គឺនៅភូមិភាគនិរតី។ ច្បាស់ណាស់ <នៅពេលដែល>ការបោសសម្អាត<កើតឡើង

គេ>បានចាប់ផ្ដើមជាមួយនឹង កុយ ធួន <ហើយនិងឧត្តរ ហើយ>បន្ទាប់មកមានការបន្តទៅពាយ័ព្យ បស្ចិម ហើយនិងមានការបោសសម្អាតបន្តទៅភូមិភាគបូព៌ា ក៏ដូចជាឦសាន។ ជាដំបូងហ្នឹង មានការប្រកាសអំពីការបោសសម្អាតកម្មាភិបាលទាំងអស់ហ្នឹង គេថា ដោយសារតែអ្នកហ្នឹងសម្លាប់មនុស្សច្រើនពេក ហើយបន្ទាប់មកគេជំនួសកម្មាភិបាលថ្មី ជាពិសេសកម្មាភិបាលនិរតីហ្នឹង ជាមនុស្សរបស់ តាម៉ុក ហ្នឹងមកជំនួសមនុស្សចាស់ <ហើយពួកគេមានចិត្តល្អជាង>។ <ក្នុងការ>ពិនិត្យមើលឯកសាររបស់ខ្ញុំ <ពីបូព៌ា>ឡើងវិញនោះ ខ្ញុំសង្កេតឃើញថា នៅតាមកន្លែងជាច្រើនគេប្រកាសថា អ្វីៗនឹងល្អប្រសើរឡើង <ហើយថា>ការបោសសម្អាត<នឹងធ្លាក់ចុះ> ហើយប្រជាជននឹងបានហូបចុកល្អប្រសើរជាងមុន ក៏ប៉ុន្តែប្រជាជនមានការខកចិត្តភ្លាមៗ នៅពេលដែលគេឃើញថា ពួកនិរតីដែលមកថ្មីហ្នឹង គឺរឹតតែកាចសាហាវជាងអ្នកចាស់ដែលគេបោសសម្អាតចោលហ្នឹងទៅទៀត។

**ស៖** លោកមានចាំឈ្មោះណាជាក់លាក់ទេ លោកចាំថា ឈ្មោះកម្មាភិបាលណាដែលត្រូវបានចាប់ខ្លួន ហើយចោទប្រកាន់ថា បានប្រព្រឹត្តអំពើកាចសាហាវនោះ?

[១៤:១៨:៤៣]

**ឆ៖** នៅក្នុងអត្ថបទរបស់ខ្ញុំអំពីក្រាំងតាចាន់ គឺខ្ញុំបានសរសេរឈ្មោះជាភាសាអង់គ្លេស ជាភាសាខ្មែរ មានទាំងអាយុ មានទាំងដើមកំណើត ថាពួកគេមកពីណា។ ឥឡូវនេះ ខ្ញុំអត់មានពេលពិនិត្យមើលឡើងវិញទេ ព្រោះថាពេលវេលាចេះតែដើរទៅមុខហើយ ហើយប្រសិនបើលោកស្រីចង់មើលច្បាស់នោះ អាចទៅមើលអត្ថបទហ្នឹងបាន។ ខ្ញុំភ្លេចទៅហើយមិនដឹងថា ម្នាក់ ពីរនាក់ ឬក៏បីនាក់ទេ។ អ្នកហ្នឹងជាប់គុកនៅក្រាំងតាចាន់ គឺក្នុងហ្នឹងមានឧក្រិដ្ឋជនម្នាក់ ពីរនាក់ ឬក៏បីនាក់ ខ្ញុំភ្លេចហើយ។ <មានពីរបីនាក់ដែល>យើងហៅអ្នកហ្នឹងថាជាឧក្រិដ្ឋជន។

**ស៖** ហើយចុះប្រភពរបស់លោកហ្នឹង គឺប្រភពចេញមកពីរបាយការណ៍សួរចម្លើយ ឬក៏ឯកសារដែរទទួលបានតាមរយៈការធ្វើទារុណកម្ម ឬក៏លោកមានសក្ខីកម្មណាផ្សេងទៀតបញ្ជាក់អំពីចំណុចនេះនោះ?

**ឆ៖** បើតាមការចងចាំរបស់ខ្ញុំ ប្រភពទាំងអស់ហ្នឹង គឺជាឯកសារដែលបានមកពីក្រាំងតាចាន់។ អ៊ីចឹងនៅតុលាការ គឺអត់មានតម្លៃអីជាភស្តុតាងទេ ពីព្រោះថាឯកសារទាំងអស់ហ្នឹងទទួលបានតាមរយៈការធ្វើទារុណកម្ម <ឬប្រហែលជាមិនដូច្នោះទេ>។ <ប្រហែលជាវាអាស្រ័យទៅលើថាតើនេះជាសេចក្ដីសង្ខេបនៃការ>សួរចម្លើយ ឬក៏<ពួកគេមាន>ប្រវត្តិរូប <ដែលអមមកជាមួយពួកគេស្រាប់>។

ខ្ញុំគិតថាជាប្រវត្តិរូបរបស់អ្នកទោស<ដែលអមមកជាមួយពួកគេ>ទាំងអស់ហ្នឹង។

**ស៖** ពាក់ព័ន្ធនឹងប្រវត្តិរូបនេះ តើលោកដឹងយ៉ាងម៉េចបានថាប្រវត្តិរូបហ្នឹងមកជាមួយនឹងមនុស្ស ដែលគេចាប់យកមកឃុំនៅមន្ទីរសន្តិសុខហ្នឹង?

**ឆ៖** នេះជាសំណួរដែលត្រូវតែសួរទៅ ប៉ែន យៀរនិន វិញ ព្រោះថាគាត់ជាអ្នករកឃើញ ឯកសារទាំងអស់ហ្នឹង។ ក៏ប៉ុន្តែយើងអាចប៉ាន់ស្មានបានថា ដោយសារតែឯកសារហ្នឹងត្រូវបានរកនៅ ខាងក្រាំងតាចាន់ អ៊ីចឹងគឺឯកសារហ្នឹងមកជាមួយនឹងអ្នកទោសនៅក្រាំងតាចាន់ហើយ គ្មានអ្នកណាទៅ សរសេរបន្ថែមអីទេ។

[១៤:២១:០៨]

**ស៖** ខ្ញុំបានធ្វើការបែងចែក រវាងកំណត់ត្រារបស់អ្នកសួរចម្លើយនិងប្រវត្តិរូប ពីព្រោះថាលោក ក៏លោកបែងចែកច្បាស់ដែរ។ លោកថា មានឯកសារខ្លះធ្វើនៅក្រាំងតាចាន់តែម្តង ហើយមានឯកសារ ខ្លះទៀត គឺអ្នកទោសដែលគេចាប់មកហ្នឹង គឺមានឯកសារជាប់មកហ្នឹងខ្លួនស្រាប់តែម្តង។ អ៊ីចឹង លោក ដឹងយ៉ាងម៉េចបានថាមានភាពខុសគ្នារវាងឯកសារទាំងពីរហ្នឹង? ហើយលោកម៉េចក៏លោកគិតថាប្រវត្តិរូប ហ្នឹងមកជាមួយអ្នកទោសតែម្តង មិនមែនត្រូវបានគេធ្វើនៅក្រាំងតាចាន់ផ្ទាល់ទេ?

**ឆ៖** ឯកសារហ្នឹងរកបាននៅក្រាំងតាចាន់ ហើយ ប៉ែន យៀរនិន ជាអ្នកប្រមូល។ ហើយយើង ដឹងហើយថានៅទូទាំងប្រទេស អ្នកដែលគេចាប់មកគុកហ្នឹង គឺតែងតែមកជាមួយ មានឯកសារភ្ជាប់ ហើយ មិនមែនមកដៃទទេទេ។ ហើយយើងដឹងហើយថា របបកម្ពុជាប្រជាធិបតេយ្យ គឺវាខុសពីប្រពៃណី កម្ពុជា វាមិនមែនជារបបមួយដែលមានប្រពៃណីផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ -- ជាផ្ទាល់មាត់ គឺ មានការសរសេរជាលាយលក្ខណ៍អក្សរ <អ្វីៗត្រូវបានគេកត់ត្រា>។ ខ្ញុំ<គិតថា គេ>បានសួរ ឌុច <សំណួរនេះ>ដែរ <ហើយខ្ញុំមិនដឹងថាតើ>ចម្លើយរបស់គាត់<ច្បាស់លាស់ឬទេ នៅពេលដែលគេសួរ គាត់>ថាតើ គឺមានឯកសារ<ឬ>ប្រវត្តិរូបមកជាមួយមនុស្ស<ដែលគេបញ្ជូនទៅ>ស-២១<ទេ> ឬក៏ <គេ>ធ្វើប្រវត្តិរូបតែម្តងនៅពេល ដែលអ្នកទោសមកដល់គេថតរូប ហើយគេសួរអត្តសញ្ញាណ<ជា ដើម> ហើយគេសរសេរប្រវត្តិរូបហ្នឹងឬក៏យ៉ាងម៉េច។ ខ្ញុំមិនច្បាស់ដែរ ពាក់ព័ន្ធនឹងស-២១ គួរតែទុក នាទីនេះជូនអង្គជំនុំជម្រះជាអ្នកសម្រេច ក៏ប៉ុន្តែ<ខុសគ្នាខ្លាំងណាស់> នៅតាមខេត្ត គឺច្បាស់ គឺអ្នក ទោសមក គឺមានកាន់សំណុំឯកសាររបស់គាត់មក ដោយសារមានហេតុផលពីរ។ ជាដំបូង អ្នកទោស ភាគច្រើននោះ សុទ្ធតែជាប្រជាជនថ្មី ឬប្រជាជន១៧មេសា ហើយអ្នកថ្មីទាំងអស់ហ្នឹងត្រូវបានគេស្នើ

ឲ្យសរសេរប្រវត្តិរូបរបស់ខ្លួន។ <ក៏ដូចគ្នាដែរ សមាជិកបក្សម្នាក់ៗហ្នឹងក៏គេស្នើឲ្យសរសេរប្រវត្តិរូបផ្ទាល់ខ្លួនដែរ ហើយ>គេក៏ប្រាប់ឲ្យ<>សរសេរ<ឡើងវិញ>ទៀត<នៅមួយឆ្នាំ ឬពីរឆ្នាំក្រោយ> រៀបរាប់អំពីជីវិតរបស់ខ្លួនហ្នឹង។ អ៊ីចឹងអ្នកចាស់ប្រហែលជាមិនសូវបានធ្វើទេរឿងប្រវត្តិរូបនេះ។ អ្នកថ្មីគេធ្វើច្រើនដងៗ<>អ៊ីចឹងនៅពេលដែលគេចាប់អ្នកណាម្នាក់ហ្នឹង គេយកទៅសួរនៅតាមសន្តិបាលឃុំអ៊ីចឹងគាត់មានឯកសាររបស់គាត់ហើយ។ គាត់មកហ្នឹង គឺចាប់មកតែងតែមកជាមួយនឹងឯកសារតែម្តង។

[១៤:២៣:៥៩]

**ស៖** ខ្ញុំសូមអភ័យទោស ខ្ញុំសូមសួរជជីកលោកឲ្យបានច្បាស់ ពីព្រោះថា ខ្ញុំចង់យល់ឲ្យបានច្បាស់ត្រង់ចំណុចហ្នឹង។ អ៊ីចឹងអ្នកទោសពេលមកដល់ហ្នឹង គឺគាត់មានប្រវត្តិរូបរបស់គាត់ផ្ទាល់មកហើយហ្នឹង លោកបានអានឯកសារនៅទីណាបានលោកដឹងអ៊ីចឹង ឬក៏អ្នកណាប្រាប់លោក លោកមានប្រភពឲ្យបានច្បាស់ទេដែលលោកហ៊ានអះអាងថា អ្នកទោសដែលមកដល់មន្ទីរសន្តិសុខហ្នឹង គឺមានកាន់ឯកសារផ្ទាល់ខ្លួនមកនោះ?

**ឆ៖** ប្រភពនោះគឺតាមរយៈសក្ខីកម្ម។ សាក្សីគាត់បាននិយាយថា គេចាប់ខ្លួនខ្ញុំ ហើយគេសួរចម្លើយខ្ញុំ។ ហើយមានអ្នកណាម្នាក់អ៊ីចឹងទៅ គាត់អ្នកកត់ត្រានៅពេលដែលខ្ញុំឆ្លើយ។ ខ្ញុំពិបាកនិយាយជាលក្ខណៈទូទៅនៅកម្ពុជាប្រជាធិបតេយ្យណាស់ ពីព្រោះថា វាមានលក្ខណៈខុសៗគ្នា ទៅតាមកន្លែងផ្សេងៗ ដូចជាករណី មឿង សុន ជាដើម។ អ៊ីចឹងគាត់ត្រូវបានគេចាប់ខ្លួននៅផ្ទះគាត់ នៅពេលយប់ហើយគាត់គិតថា គេនាំគាត់ទៅកំពង់សោម ក៏ប៉ុន្តែឡានគឺទៅខាងជើងទេ មិនមែនទេទៅខាងត្បូងទេ។ អ៊ីចឹង អត់គាត់ឆ្លងតាមសន្តិបាលទេ។ ហើយខ្ញុំគិតថា <ករណី> មឿង សុន <គេ>មានព័ត៌មានអំពី<គាត់រួចហើយ ហើយ>នៅពេលដែលគេនាំគាត់ទៅតានៃហ្នឹង គឺគាត់មានឯកសារនៅជាប់នឹងខ្លួនគាត់ហើយ។ ពីព្រោះថា គាត់បានត្រូវបានគេសុំឲ្យធ្វើប្រវត្តិរូបផ្ទាល់របស់គាត់នោះ។

[១៤:២៥:៣៣]

**ស៖** ពាក់ព័ន្ធនឹងឯកសារជាពិសេសនៅក្រាំងតាចាន់ លោកបាននិយាយថា លោកបានទទួលតែឯកសារថតចម្លងទេ។ នេះជា -- ហើយលោកបានថា បើចង់ដឹងសួរ ប៉ែន យៀរនិន ទៅ ពីព្រោះថា ប៉ែន យៀរនិន ជាអ្នកទទួលបានឯកសារហ្នឹងដំបូងគេ មុន ទាំងមុនមជ្ឈមណ្ឌលឯកសារកម្ពុជាទៅទៀត។ អ៊ីចឹង ខ្ញុំចង់សួរលោកថា លោកមាននឹកឃើញឡើងវិញទេ ថានៅពេលដែលលោកពិគ្រោះឯក-សារទាំងអស់ហ្នឹង លោកមានបានឃើញចំនួនតួលេខអ្នកទោសសរុបនៅក្រាំងតាចាន់ទេ?

**ឆ៖** ខ្ញុំមិនបានពិនិត្យមើលឯកសារ<ក្រាំងតាចាន់ ដែលខ្ញុំមានម្តងទៀតទេ មុនពេលខ្ញុំមកទីនេះ>។ មានឯកសារជាច្រើនដែលខ្ញុំត្រូវបានពិនិត្យមើលដែលលោកស្រីបានប្រគល់ឲ្យខ្ញុំ នៅក្នុងចុងសប្តាហ៍នោះ លោកស្រីមិនបានប្រាប់ឲ្យខ្ញុំ<>មើលឯកសារក្រាំងតាចាន់<ឡើងវិញ>ទេ។ អ៊ីចឹងតាមដែលខ្ញុំចាំហ្នឹង គឺមាន មានបញ្ជីឈ្មោះអ្នកទោស ប៉ុន្តែខ្ញុំមិនចាំច្បាស់ថាមានមនុស្សប៉ុន្មាន<នោះទេ។> ខ្ញុំចាំថាមានជាកូឡោន ជាតារាង ក៏ប៉ុន្តែចំនួនសរុបប៉ុន្មានអីប៉ុន្មាន ខ្ញុំដូចជាមិនចាំទេ។ ខ្ញុំជាអ្នកបូកសរុបខ្លួនដែរនូវឈ្មោះដែលបានសរសេរនៅក្នុងបញ្ជីទាំងអស់នោះ។ ខ្ញុំចាំថា ដូចជាកាលហ្នឹង៤៧៧នាក់។ អ៊ីចឹង ខ្ញុំគិតថាវាប្រហែលជា៥០០នាក់ទៅចុះ។ អ៊ីចឹង ចំនួនហ្នឹង<វាឆ្ងាយពីចំនួនសរុបនៃអ្នកដែលបានឆ្លងកាត់ក្រាំងតាចាន់ណាស់> បើខ្ញុំគិតទៅ។

[១៤:២៧:២៣]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតប្រគល់ឯកសារមួយទំព័រគឺឯកសារ E3/2107 ដែលជាអត្ថបទសរសេរដៃ ដែលជាកម្មវត្ថុនៃសំណើរបស់យើងដែរ។ អ៊ីចឹងខ្ញុំចង់ប្រគល់ឯកសារនេះ ជូនទៅអ្នកជំនាញដើម្បីឲ្យគាត់ពិនិត្យមើល ថាតើគាត់ចាំថា គាត់ធ្លាប់ឃើញឯកសារនេះ ឬក៏អត់។ គឺឯកសារ E3/2107 ERN ជាភាសាខ្មែរ 00068049, ជាភាសាបារាំង 00655725, ជាភាសាអង់គ្លេសគឺ 00290205។ លោកប្រធាន សូមមេត្តាអនុញ្ញាតប្រគល់ឯកសារនេះជូនទៅអ្នកជំនាញ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** ក្នុងពេលដែលមន្ត្រីតុលាការប្រគល់ឯកសារនេះទៅអ្នកជំនាញ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងឯកសារជាសំណៅជាភាសាអង់គ្លេស <មានចំណារមួយ> ខ្ញុំនឹងអានជាភាសាអង់គ្លេស គឺមាននិទ្ទេសរបស់ក្រុមអ្នកបកប្រែ ដែលបញ្ជាក់ថា <>ចំណារសរសេរដៃ<មាននៅលើទំព័រដាច់ដោយឡែកមួយទៀត ហើយមាននិយាយច្បាស់ដូច>នៅក្នុង ERN ដែលខ្ញុំបានផ្តល់ជូនហើយ។

(ការអានជាភាសាអង់គ្លេស៖) "<ទំព័រដាច់ដោយឡែក។ ចំណារ>សរសេរអក្សរដៃ<ខៀកខ្ចីខ្ចាមិនមាន>នៅក្នុងឯកសារផ្នែកផ្សេងនោះទេ" សូមបញ្ចប់ការដកស្រង់។ ខ្ញុំដឹងថាមិនច្បាស់ទេ ក្នុងការចងចាំឯកសារទាំងអស់ដែលលោកបានពិនិត្យមើលពាក់ព័ន្ធនឹងក្រាំងតាចាន់នោះ ក៏ប៉ុន្តែទោះជាយ៉ាង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ណាក៏ដោយ តើលោកមានទឹកឃើញថា ធ្លាប់ឃើញចំណាររនៅទំព័រហ្នឹងទេ ដែលជាទំព័រដែលដាច់ពីគេ មានអក្សរខុសគេ ដែលក្នុងនោះមានខ្ទាំងហ្នឹង គឺ១៥.០០០នាក់។

[១៤:២៩:៤៣]

**លោក ហង់រី ឡូកា៖**

**ឆ៖** បាទ ពិតណាស់ គឺមានចំនួន ១៥.០០០នាក់មែន ជាអក្សរឡាតាំង ជាលេខឡាតាំង។

**ស៖** ខ្ញុំមិនចង់ឲ្យលោកបញ្ជាក់ថាមានសរសេរអ៊ីចឹងត្រូវ ឬមិនត្រូវទេ ខ្ញុំគ្រាន់តែសួរថា តើលោកធ្លាប់ឃើញឯកសារហ្នឹង ឬក៏អត់?

**ឆ៖** ខ្ញុំមិនចាំដែរ។ <ខ្ញុំគ្មានយោបល់អីទេ។> ទាល់តែខ្ញុំទៅស-២១ ឬក៏ទៅ ស៊ី.ឌី.ខេម ពិនិត្យមើលឯកសារថតចម្លងរបស់ហ្នឹងឡើងវិញថា តើឯកសារហ្នឹងយ៉ាងម៉េច។ បើជាភាសាខ្មែរនេះ ខ្ញុំមើលទៅ ខ្ញុំអត់ដឹងអីទេ។ ខ្ញុំព្យាយាមស្វែងយល់ដែរ។ <>យើង<ឃើញច្បាស់ណាស់ថាវា>មកពីតំបន់១០៣ <-- ទេ ខ្ញុំគិតថាមកពី៨០៣។>

<**ស៖** គេសរសេរថា ១០៥។>

<**ឆ៖** សូមទោស "៨០៥ -- តំបន់ ១០៥។> ដូចជា <អត់មានន័យ>អីសោះ<សម្រាប់ខ្ញុំ>។

**ស៖** មិនអីទេ បើលោកមិនដឹងអីទេ ខ្ញុំអត់សួរសំណួរអីបន្ថែមទៅលើឯកសារហ្នឹងទេ។ ក៏ប៉ុន្តែខ្ញុំចង់ត្រឡប់មកនិយាយអំពីបញ្ហាលំបាកក្នុងការទទួលបានឯកសារ ដោយសារតែមានការបំផ្លាញឯកសារចាស់ៗពីដើម ជាពិសេសឯកសារឃោសនាពាក់ព័ន្ធនឹងតួលេខ ឬក៏ប្រភេទឯកសារផ្សេងៗដែលអ្នកស្រាវជ្រាវបានទទួលក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្លួនលោកផ្ទាល់ លោកបានសួរសាក្សីជាច្រើននៅពេលដែលលោកធ្វើការស្រាវជ្រាវ ហើយលោកក៏បានធ្វើរបាយការណ៍ ជាពិសេសឯកសារ E3/2071 ដែលមានចំណងជើងថា "ការស្រាវជ្រាវទៅលើបណ្ដាញកម្ពុជាប្រជាធិបតេយ្យភូមិភាគពាយ័ព្យ" ដូចដែលលោកបានជម្រាបជូនសហភាតារបស់ខ្ញុំអម្បាញ់មិញហ្នឹង <លោកបានកត់សម្គាល់ជាច្រើនដង>នៅក្នុងឯកសារមួយនេះ ជាអាទិ៍ ជាពិសេសនៅទំព័រជាភាសាខ្មែរ <00233387> ទៅទំព័របន្តបន្ទាប់ទៀតខាងមុខ ជាភាសាបារាំង 00292779 និងជាភាសាអង់គ្លេស <0087306>។ លោកបានបញ្ចេញមតិយោបល់អាស្រ័យទៅតាមអ្វីដែលគេរាយការណ៍ប្រាប់លោក ដូចជាក្នុងនេះលោកបាននិយាយថា ជាការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា <តើសាក្សីគិតថាចាំបាច់ត្រូវនិយាយឡើងវិញ ឬក៏គេពិតជាជឿវានោះ?> ហើយចំណុចមួយទៀតលោកបានសរសេរនៅក្នុងរបាយការណ៍មួយ

ទៀត។ ហ្នឹងដូចជារបាយការណ៍ដដែលទេ តែនៅទំព័រផ្សេងគឺជាភាសាបារាំង 00292788, ជាភាសាអង់គ្លេស 00087316, ជាភាសាខ្មែរ 00233403។ លោកលើកឡើងអំពីតួលេខមួយដែលគេផ្តល់ជូនលោក។ ហើយលោកថា "នៅក្នុងសម័យ ហេង សំរិន ចំនួនដែលសម្លាប់នៅទីនោះៗគឺមានប្រហែលជា ៥០.០០០ នាក់។ ហើយលោកបើកវង់ក្រចកថា ការសន្និដ្ឋានរបស់ ស៊ី.ឌី.ខេម ហ្នឹងគឺ ២០.០០០ ទៅ ២៥.០០០ នាក់"។ ដូច្នេះខ្ញុំចង់សួរលោកជាលក្ខណៈទូទៅថា នៅពេលដែលលោកធ្វើការទៅលើឯកសារ ឬក៏ព័ត៌មាន ហ្នឹង លោកលើកឡើងអំពីតួលេខហ្នឹងយ៉ាងម៉េច? លោកយកជាការណ៍យ៉ាងម៉េច? លោកផ្ទៀបយ៉ាងម៉េចចំពោះតួលេខដែលគេផ្តល់ជូនហ្នឹង ដែលធ្វើឲ្យលោកជឿថា តួលេខហ្នឹងវាពិតប្រាកដមែននោះ?

[១៤:៣៤:២៧]

**ឆ៖** តួលេខដែលផ្តល់ដោយអាជ្ញាធរសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺជាតួលេខបំផ្លើស ហើយ ស៊ី.ឌី.ខេម <ក៏រកឃើញដែរថា> គឺពួកគាត់ច្រើនតែបំផ្លើសតួលេខហ្នឹងឲ្យបានឃើញច្រើន ចេះតែបំប៉ោងអ៊ីចឹងទៅ។ ហើយយើងឃើញថាមេធាវី ការ សាវុត្ត ជាមេធាវីរបស់ ឌុច ហ្នឹងក៏គាត់បាននិយាយថា ដែរថា នៅគុកហ្នឹង <ពួកគេបានសម្លាប់មនុស្សជាង១០០.០០០នាក់ ហើយខ្ញុំអាចបញ្ជាក់> ថា តួលេខសម្លាប់មនុស្សហ្នឹង គឺជារឿងស្រមើស្រមៃ មិនមានអីជាការពិតទេ<>។ សម្លាប់ច្រើននោះនៅក្រឡាញ់ នៅសៀមរាប ឬក៏នៅស៊ីសុផុន ហើយនៅទីនោះគឺប្រជាជនសុទ្ធតែត្រូវបានចាត់ទុកជាអ្នកថ្មី។ ដូច្នេះមានការបង្ក្រាបបង្ហូរឈាមហ្នឹងខ្លាំងមែនទែននៅសៀមរាបហ្នឹង។<ដូច្នេះ នៅពេលយើងមើលទៅលើកំណត់សម្គាល់ទាំងអស់នេះ> ខ្ញុំគិតថាការសរសេរហ្នឹងដូចជាឆ្នាំ៩០។<>លោកស្រី<មិន>បានប្រាប់ខ្ញុំ<អំពីកាលបរិច្ឆេទ>ទេអម្បាញ់មិញ <ពីព្រោះខ្ញុំតែងតែកត់ចំណាំពីកាលបរិច្ឆេទនៃកិច្ច>សម្ភាស <របស់ខ្ញុំ ហើយខ្ញុំជឿថា>នោះ<គឺនៅ>ពេលខ្ញុំចាប់ផ្តើម<ការស្រាវជ្រាវរបស់ខ្ញុំជាលើកដំបូង។ ខ្ញុំបានទទួលការបណ្តុះបណ្តាលតិចតួចពី ហ្សង់ លុច ដូមេណាច ដែលជាអ្នក>ជំនាញខាងប្រទេសចិន គាត់បានផ្តល់ព័ត៌មានមួយចំនួនមកដល់ខ្ញុំ ហើយគាត់ប្រាប់ថាត្រូវប្រុងប្រយ័ត្នចំពោះតួលេខដែលគេឲ្យមក។ ខ្ញុំព្យាយាមចងចាំ ហើយនៅពេលដែលគេឲ្យខ្ញុំធ្វើសម្មតិកម្មអីអ៊ីចឹង ភាគច្រើនខ្ញុំតែងតែព្យាយាមយកអាចំនួនតិចដែលវាអាចត្រូវនឹងការពិតជាង ព្រោះថាភាគច្រើនគេឲ្យតួលេខមកហ្នឹងច្រើនតែបំផ្លើស។ អ៊ីចឹងវាមានតម្រុយជាច្រើនដែលអាចឲ្យយើងបានកំណត់អំពីកន្លែង សួរចម្លើយ ធ្វើទារុណកម្ម និងការសម្លាប់។ អ៊ីចឹងអ្វីដែលសំខាន់ គឺចំនួនអ្នកទោសដែលមាននៅតាមគុកនីមួយៗ និងៗចំនួនមនុស្សដែលគេ

នាំចូលមកជារៀងរាល់ថ្ងៃ ជារៀងរាល់ខែ ហើយនិងរយៈពេលនៃការដំណើរការនៃស្ថាប័ននីមួយៗ។ ចំពោះខ្ញុំៗអត់ដែលទទួលយកតួលេខដែលផ្តល់ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជាថាយកជាការទេ។ យើងដឹងហើយថាក្រោយពីការបង្កើតរបបថ្មី និងមានរដ្ឋធម្មនុញ្ញថ្មី អាជ្ញាធរហ្នឹងគឺមិនសូវខ្វល់ខ្វាយអ្វីទៅនឹងកម្ពុជាប្រជាធិបតេយ្យទេ ជាពិសេសតាំងពីពេលសម្តេចសីហនុ យាងចូលមកវិញនោះក៏អ៊ីចឹងដែរ គឺមិនសូវមាន-- អ៊ីចឹងខ្ញុំ<មានការងារត្រូវធ្វើជាមួយ>អាជ្ញាធរហ្នឹង<កាន់តែតិចទៅៗ>។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានប្រហែលជាដល់ពេលឈប់សម្រាកហើយនៅពេលនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណដល់លោកអ្នកជំនាញ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីអ្នកជំនាញរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដើម្បីបញ្ចប់ជាមួយនឹងរបាយការណ៍ដែលលោកបានសរសេរ លោកបានសរសេររបាយការណ៍មួយទាក់ទងទៅនឹងខេត្តកំពង់ចាម គឺឯកសារ E3/2649។ ជាពិសេសហ្នឹង គឺលោកចាប់អារម្មណ៍ទៅលើគុកដែលយើងបាននិយាយនៅទីនេះ គឺគុកវត្តអូរត្រកួន។ ERN ជាភាសាបារាំង គឺ00614111, ជាភាសាអង់គ្លេស គឺ 00208395, ជាភាសាខ្មែរ គឺ 00660598។ លោកនិយាយទាក់ទងនឹងតួលេខដដែល។ "នៅពេលដែលខ្ញុំសួរថា តួលេខដែលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ ទុកចិត្តបានដែរឬក៏អត់នោះ គឺ <ជនរងគ្រោះ ៣២.៦៨០នាក់ និងរណ្តៅចំនួន ៤៦៧រណ្តៅ។> គាត់ឆ្លើយថា ចំនួនពិតប្រាកដដែលបានផ្ទៀងផ្ទាត់ហ្នឹង គឺ ៣៩.០០៧ បូកនឹង១ ដោយសារគាត់ជាសាក្សី<ដែលបានឃើញ> អ្នកទោសចុងក្រោយ ត្រូវបានសម្លាប់"។ <>លោកធ្វើអត្ថធិប្បាយដូច្នេះ "ជាក់ស្តែងនោះ គឺជាតួលេខពន្លើសដែលកត់ត្រាដោយអាជ្ញាធរក្នុងដើមសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា។ តួលេខ វាមិនអាចមានលក្ខណៈជាក់លាក់ទេ ដោយសារគេប្រាប់ថា បណ្ណសារដ្ឋានទាំងអស់ត្រូវបានកម្ទេចចោល ហើយនិងបាត់បង់ ជាចម្បងដោយភាពល្ងិតល្ងង់ និងខ្ជីខ្ជា។ ដូចដែលគេនិយាយថា អាជ្ញាធរមិនមានការទទួលខុសត្រូវក្នុងការបាត់បង់បណ្ណសារនេះទេ។ លក្ខណៈស្រាវជ្រាវរបស់ ឌី.ស៊ី.ខេម គឺជាអ្នកស្រាវជ្រាវមិនមានបទពិសោធន៍ គ្រាន់តែកត់តួលេខដែលធ្វើនៅរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាតែប៉ុណ្ណោះ ហើយប្រហែលជាមិនធ្វើការស្រាវជ្រាវដោយលក្ខណៈ ឯករាជ្យរបស់ខ្លួននោះទេ"។ បាទ សូមបញ្ចប់ការដកស្រង់។

អ៊ីចឹងសំណួររបស់ខ្ញុំទី១ គឺខ្ញុំចង់ដឹងថា តើលោកមានបានចោទសំណួរសួរលើបណ្ណសារដ្ឋាននៃវត្តអូរត្រកួននោះដែរឬទេ? ហើយតើបណ្ណសារដ្ឋានទាំងពីរហ្នឹង គឺត្រូវបានបំផ្លាញចោលហ្នឹងដោយសារភាពល្ងង់ខ្លៅ ហើយនិងការធ្វេសប្រហែស?

[១៥:០៣:០៣]

**លោក ហង់រី ឡូកា៖**

**ឆ៖** ខ្ញុំដូចជាធ្លាប់ឆ្លើយនឹងសំណួរបែបហ្នឹងហើយ ព្រោះថាខ្ញុំធ្លាប់បាននិយាយថា មានការបាត់បង់បណ្ណសារដ្ឋានជាច្រើននៅក្នុងប្រទេសនេះ ហើយពីព្រោះថា មានមនុស្សជាច្រើនក្រោយពីថ្ងៃ០៧ <មករា> ឆ្នាំ១៩៧៩នោះ គឺខំត្រដររស់ គឺចារកចំណីអាហារហូបចុក រកបងប្អូនរបស់ខ្លួន ហើយនិងត្រឡប់ទៅស្រុករបស់ខ្លួនវិញជាជាងការគិតពីឯកសារ។ អ៊ីចឹងគឺស្ថានបរិយាកាសនេះ គឺថាជាបរិយាកាស

01344522



មួយដែលលំបាកលំបិនបំផុត។ អ៊ីចឹងការរកឯកសារនោះ មិនមែនជាអាទិភាពរបស់មនុស្សនោះទេ អ៊ីចឹង។ ហើយចំណុចទី២ហ្នឹង គឺថានៅកន្លែងមួយចំនួននោះ គឺថាគេបានបំផ្លាញឯកសារនេះចោលជាប្រព័ន្ធ ពីព្រោះថាទ្រឹស្តី ការយល់ឃើញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាកាលនោះៗ គឺថាៗនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះមានគុកតែមួយទេដែលគេដាក់ឈ្មោះថា "គុកទួលស្លែង" ដែល ស-២១ហ្នឹង គឺឲ្យមានគុកតែមួយហ្នឹងទេ។ ហេតុអីបានគេគិតអ៊ីចឹង ព្រោះថានៅជុំវិញគុកនុ៎ង គឺថាមាន ឌុច មាន ប៉ុល ពត, អៀង សារី ដែលគួរឲ្យស្អប់ខ្ពើម។ អ៊ីចឹង គឺថាមានខ្មែរក្រហមល្អ ខ្មែរក្រហមអាក្រក់។ ហើយខ្មែរក្រហមល្អនោះ គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា។ អ៊ីចឹងរបបថ្មីហ្នឹងមិនមានផលប្រយោជន៍អីត្រូវនិយាយថា<ស-២១ មិនមែនជា>គុក<តែមួយនោះ>ទេ <ប៉ុន្តែតាមពិតទៅ>គឺថា<> មានគុក<នៅគ្រប់ទីកន្លែង។ គ្មានប្រទេសណាដែលមានគុកតែមួយនោះទេ។ ប៉ុន្តែវា>អត់មានបណ្ណសារទេ។ ហើយបន្ទាប់មកទៀត លោកៗស្រីសួរខ្ញុំថា តើនៅក្រាំងតាចាន់ហ្នឹង តើអ្នកណាជាឧក្រិដ្ឋជននោះ? ខ្ញុំរកឃើញ គឺថាមានមនុស្សបីនាក់ដែលជាឧក្រិដ្ឋជននោះ នៅទំព័រ១៦ និង១៧ គឺជាអ្នករំលោភសេពសន្ថវៈ<មានពីរនាក់។ ពួកគេបាន>រំលោភ<>ក្មេងស្រីតូចៗ<>អាយុ៥ឆ្នាំ <និង>១៤ឆ្នាំ ហើយមួយទៀត <>១០<ឆ្នាំ និង>១៣ឆ្នាំ។ ហើយនិងបុគ្គលម្នាក់ទៀតដែលជាអតីតប្រធានគុក នៅក្នុងរបាយ-ការណ៍របស់ខ្ញុំហ្នឹងគឺទំព័រទី១៦-១៧ អ៊ីចឹងគឺថាប្រធានគុកហ្នឹងតែម្តងហ្នឹង ជា -- ដែលគាត់ហ្នឹងពេលចុងរបបខ្មែរក្រហមហ្នឹង គាត់ត្រូវបានគេបោសសម្អាតដែរ។

[១៥:០៥:៣៦]

**ស៖** សំណួរចុងក្រោយ ទាក់ទងទៅនឹងប្រធានបទឯកសារ ហើយនិងតួលេខដែលបានផ្តល់ក្រោយពេលរបបខ្មែរក្រហមរលំទៅ គឺថាយើង នៅក្នុងសំណុំរឿង យើងមាន<ឯកសារ>បី<> ដែលបាន<ផ្តល់ឲ្យដោយមនុស្សរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏អ្នកផ្សេងៗទៀត ដែលបាន>ធ្វើការអំពីរបាយការណ៍នេះ ទាក់ទងទៅនឹងទីតាំងសម្លាប់មនុស្ស គឺឯកសារ E3/10616 ហើយនិង E3/10617 ហើយនិងឯកសារ E3/10618 <ដោយមានឈ្មោះ ដែលខ្ញុំមិនអាចដកស្រង់មកនិយាយបាននៅក្នុងសវនាការនេះ>។ ខ្ញុំ នៅក្នុងឯកសារ E3/10616 នៅចម្លើយទី២៨ ដែលខ្ញុំនឹងដកស្រង់ជាភាសាអង់គ្លេស ព្រោះថាមានតែជាភាសាអង់គ្លេសទេ។ អ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត <សួរ> ទៅសាក្សីទាក់ទងនឹងរបាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង គាត់សួរដូចតទៅនេះ៖

"តើលោកទទួលបានឯកសារ<អំពីឈ្មោះ>ទីតាំងនោះ<បានមកពីកន្លែងណា>ដែរ? <ចម្លើយ

២៨៖> មន្ត្រីមកពីមន្ទីរឃោសនាការវប្បធម៌បានផ្ដល់មកឲ្យយើង។ សំណួរ៖ តើលោកចាំទេថាអ្នកណាអ្នកផ្ដល់ឯកសារហ្នឹងទៅឲ្យលោក? ឆ្លើយ៖ ចម្លើយទី២៩ លោក <ហាប់ សឿន> ដែលប្រធានមន្ទីរ <ស្រុក> ហើយនិងលោក <ថ្លាង ថុង> មកពីមន្ទីរវប្បធម៌បានផ្ដល់ឯកសារហ្នឹងមកឲ្យយើង ហើយនាំយើងទៅដល់ទីតាំង។ របាយការណ៍ដែលផ្ដល់ហ្នឹង គឺត្រឹមត្រូវ ហើយយើងក៏មិនបានទៅកន្លែងមួយចំនួននោះទេ។" សូមបញ្ចប់ការដកស្រង់។

អ៊ីចឹងសំណួរខ្ញុំ គឺសូមបញ្ជាក់ ដោយសារលោកបាននិយាយថា លោកបានធ្វើការស្រាវជ្រាវដោយមានអមដំណើរដោយមនុស្សម្នាក់ដែលលោកថា លោកពិបាកផ្លាស់ទីនៅពេលនោះ។ តើម្នាក់នោះអ្នកដែលឲ្យឯកសាររបស់លោកនោះ គឺជាអ្នកធ្វើការនៅក្រសួងឃោសនាការ ក្រសួងវប្បធម៌ ឬដែលផ្ដល់ឯកសារឲ្យលោកនៅពេលដែលលោកទៅពិគ្រោះឯកសារនៅទីនោះ?

[១៥:០៨:១០]

**ឆ៖** បាទ សូមអរគុណ ដែលបានដកស្រង់ជាភាសាអង់គ្លេសអម្បាញមិញនេះ។ អ្វីដែលខ្ញុំបានលើកឡើងនោះ គឺជាការសន្និដ្ឋានមួយទេ ហើយខ្ញុំសង្ស័យខ្លាំងដែរ។ នេះជាបញ្ជាក់អំពីការសន្និដ្ឋានរបស់ខ្ញុំ។ ខ្ញុំសូមអរគុណ។ ហើយទាក់ទងទៅនឹងទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងអាជ្ញាធរមូលដ្ឋាននោះ ខ្ញុំចង់និយាយថា ការស្រាវជ្រាវរបស់ខ្ញុំនៅទសវត្សរ៍ ដើមទសវត្សរ៍ទី៩០ នុ៎ង គឺថាខ្ញុំមាន ខៀវ កាញារិទ្ធ ចេញលិខិត ជាអ្នកចេញលិខិតអនុញ្ញាតឲ្យខ្ញុំ កាលនោះគាត់ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន ជាអ្នកចេះភាសាបារាំង ចូលចិត្តជាភាសាបារាំង ហើយគាត់ជំរុញឲ្យខ្ញុំធ្វើការងារនេះ។ នេះជាអ្វីដែលអាចឲ្យខ្ញុំបានលិខិតមួយដើម្បីណែនាំខ្លួនទៅខេត្តដែលខ្ញុំទៅស្រាវជ្រាវ ឬក៏ទៅស្រុកណាមួយនោះ។ អ៊ីចឹងលិខិតនេះ ធ្វើឲ្យខ្ញុំមានឋានៈមួយខុសពីអ្នកស្រាវជ្រាវឯករាជ្យបន្តិចដែរ ពីព្រោះថាមានអាជ្ញាធរថ្មីហ្នឹង ដែលអនុញ្ញាតឲ្យខ្ញុំទៅធ្វើការស្រាវជ្រាវ ហើយដែលកាលនោះប្រទេសខ្មែរកំពុងតែប្រែប្រួល ដែលថាជិតចូលដល់ចរចាសន្តិភាពគ្រូវគ្នាហើយ ហើយជិតអ៊ុនតាក់ជិតចូលស្រុកហើយ។ អ៊ីចឹង ដូចមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ គឺខ្ញុំទៅមន្ទីរវប្បធម៌ ហើយនិងព័ត៌មាន ដើម្បីសុំការអនុញ្ញាត។ <ដូច្នេះគឺអាស្រ័យទៅលើទីកន្លែង ហើយខ្ញុំគិតថានៅក្នុងឯកសារដែលលោកស្រីផ្ដល់ឲ្យខ្ញុំនេះ គឺជាការដកស្រង់ចេញពីសៀវភៅចុងក្រោយរបស់ ក្រេក អេតឆេសាន់ ដែលសរសេរអំពី "ក្រោយវាលពិឃាត" -- ទាំងអស់នេះស្ថិតក្នុងចំណោមឯកសារដែលគ្មានអត្តសញ្ញាណ ដែលលោកស្រីបានផ្ដល់ឲ្យខ្ញុំ -- ខ្ញុំគិតថាខេត្ត>ស្វាយរៀង<បានធ្វើការស្រាវជ្រាវទូលំទូលាយណាស់>។ មន្ទីរព័ត៌មាន ហើយនិងវប្បធម៌នោះ គាត់ផ្ដល់កន្លែង ទីតាំងឧក្រិដ្ឋ

ហើយមានព័ត៌មានច្បាស់លាស់ទាក់ទងទៅនឹងគុក ហើយខ្ញុំបានជួបអ្នកដែលចិត្តល្អ ដែលគាត់មិនមានឋានៈធំដុំផ្នែកនយោបាយទេ។ គាត់ពុំមានទំនួលខុសត្រូវនយោបាយ ឬក៏សេដ្ឋកិច្ចអីទេនៅក្នុងស្រុកនោះ។ អ៊ីចឹងជាប្រភពមួយដ៏សំខាន់សម្រាប់ខ្ញុំ អ៊ីចឹង ក៏ប៉ុន្តែវាអាស្រ័យនឹងដោយកន្លែងដែរ។

**ស៖** ខ្ញុំសោកស្ដាយ ខ្ញុំសូមឲ្យឆ្លើយនឹងខ្លីៗ ដោយសារពេលវេលាខ្លី។ ចំពោះអង្គជំនុំជម្រះ និងភាគី ខ្ញុំមិនបានអានផ្នែកនេះទាំងអស់នោះទេ តែខ្ញុំសូមយោងទៅឯកសារ E3/10617 ចម្លើយទី១០ គឺឯកសារ E3/10618 ចម្លើយទី៣ ដូចស្រដៀងនឹងឯកសារ ដែលខ្ញុំទើបនឹងដកស្រង់អំមិញដែរ គឺមាននិយាយអំពីឯកសារដែលផ្ដល់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង គឺផ្ញើចេញពីមជ្ឈមណ្ឌល -- ចេញពីមន្ទីរព័ត៌មាន ហើយនិងឃោសនាការ គឺពីអាជ្ញាធរ។ <ឥឡូវខ្ញុំត្រឡប់មកនិយាយអំពីចំណុចសំខាន់មួយនៃសំណួររបស់ខ្ញុំ>ដែលលោកនិយាយអំពី ខៀវ សំផន។ លោកបានអះអាងប៉ុន្មានឆ្នាំកន្លងទៅនេះនៅក្នុងសៀវភៅរបស់លោក។ អ៊ីចឹងខ្ញុំសុំប្រភពព័ត៌មានរបស់លោក។ ផ្នែកទី១ សំណួរទី១នោះ លោកបានបញ្ជាក់ហើយ ក៏ប៉ុន្តែលោកមិនចាំថាបានធ្វើកំណត់ត្រាអ្វីទេ នៅពេលដែលលោកសម្ភាសជាមួយលោក ខៀវ សំផន រយៈពេលខ្លះនៅប៉ៃលិននោះទេ ដែលកាលនោះ ស៊ីគៀន ហ្នឹងអ្នកណែនាំឲ្យលោកទៅជួបលោក ខៀវ សំផន។ តើលោកយល់ស្របនឹងខ្ញុំដែរឬទេ ថានៅពេលដែលលោកស្រាវជ្រាវនោះ លោកមិនបានធ្វើការស្រាវជ្រាវជាក់លាក់ណាមួយទាក់ទងទៅនឹងរបបរយៈពេលមុនឆ្នាំ១៩៧៥ទេ តើអ៊ីចឹងឬក៏យ៉ាងណា?

[១៥:១២:៣០]

**ផ៖** បាទ មុនឆ្នាំ១៩៧៥ បើសិនជាលោកស្រីមើលសៀវភៅចុងក្រោយរបស់ខ្ញុំ គឺថា *"ពួកវរ ឡេខ្មែរក្រហម"* គឺមានជំពូកជាច្រើនទាក់ទងទៅនឹងប្រវត្តិនៃរបបប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ទាក់ទងនឹងអ្វីដែលកើតមានឡើងនៅប៉ារីស ចំពោះខ្មែរដែលរស់នៅទីនោះមួយចំនួន ហើយខ្ញុំក៏បានធ្វើការវិភាគពីនិក្ខេបបទរបស់លោក ខៀវ សំផន។ អ៊ីចឹងខ្ញុំទាញការសន្និដ្ឋានថា គាត់ជាសមាជិកនៃ<>ក្រុមមួយ<នៃក្រុមសេដ្ឋកិច្ចចម្រុះ ដូចនៅបារាំង ហើយដាច់ខាតមិនមែនជាក្រដាសស ឬក៏កម្មវិធីសេដ្ឋកិច្ច ឬក៏កម្មវិធី>នយោបាយនៃកម្ពុជាប្រជាធិបតេយ្យទេ។ អ៊ីចឹង ខ្ញុំផ្អែកទៅលើការងារជាច្រើនទៀត ដូចជាសិស្ស<>ម្នាក់ឈ្មោះ សះសាស៊ែរ <ជានិស្សិតជនជាតិបារាំង ដែលបានសរសេរនិក្ខេបបទរបស់គាត់> ដែលបានសិក្សាមួយដ៏គួរឲ្យចាប់អារម្មណ៍ គាត់សិក្សាទៅលើបញ្ញាជនខ្មែរដែលបានចូលចលនាខ្មែរក្រហម ហើយដែលបានសិក្សានៅទីក្រុងប៉ារីស។ អ៊ីចឹង ខ្ញុំមិនមានការផ្ដល់ជូននូវអ្វីដែលប្លែកនោះទេ ក៏

ប៉ុន្តែនៅក្នុងជំពូកដំបូងនៃសៀវភៅ *"ពួកគ័រ ឡេ ខ្មែររូស៍"* នោះ ខ្ញុំពន្យល់អស់ហើយ។

**ស៖** មុននឹងចូលនិយាយអំពីសៀវភៅនេះ ខ្ញុំសូមនិយាយពីសៀវភៅរបស់លោក គឺឯកសារ E3/2812 គឺសៀវភៅក្រហមរបស់ ប៉ុល ពត បោះពុម្ពនៅឆ្នាំ១៩៨៦ ERN ជាភាសាបារាំងគឺ 00395 113, ERN ជាភាសាអង់គ្លេសគឺ 00394791។ នេះលោកបាននិយាយនៅក្នុងផ្នែកដែលខ្ញុំនឹងអានជូននេះ។ លោកនិយាយអំពីគុកទួលស្លែង<ដូចតទៅ>។ លោកនិយាយថា "ភារកិច្ចពិសេសរបស់ថ្នាក់ដឹកនាំគ្រប់កម្រិតថ្នាក់ទាំងអស់ហ្នឹង គឺត្រូវវែកមុខអ្នកប្រឆាំង <ដើម្បីសម្លាប់ប្រភពរបស់វា និងគ្រប់ទម្រង់នៃការប្រឆាំងទាំងអស់ ដោយសម្លាប់ទាំងសមាជិក>គ្រួសារ <ដើម្បី>បំផ្លាញ<ការប៉ុនប៉ងបះបោរកុំឱ្យវារីកឡើងទាន់>។ <បេសកកម្ម>នេះគឺ<សឹងតែ>ជាទស្សនវិជ្ជា ព្រោះថាត្រូវបែងចែកអ្វីដែលល្អ ហើយនិងអាក្រក់ ហើយថ្នាក់ដឹកនាំហ្នឹង គឺអង្គការហ្នឹង គេពិចារណាពីចំណុចនេះខ្លាំងណាស់។ ហើយយើងអាចនិយាយបានផងដែរថានេះគឺជា<>សាខាមួយនៃរដ្ឋាភិបាលនៅក្រោមការទទួលខុសត្រូវរបស់ ខៀវ សំផន <ជាមួយនឹង>អ្នកសួរចម្លើយនៅតាមគុកច្រើន ដោយមិនបាច់និយាយអំពីឯកសារ<យ៉ាងច្រើន>ដែលមាន<តួនាទី>ដ៏មានប្រសិទ្ធភាព<នៅគ្រប់កម្រិត>នោះទេ។" សូមបញ្ចប់ការដកស្រង់។ លោកមិនបានបង្ហាញអំពីប្រភពច្បាស់លាស់ទេ។ តើលោកមានអ្វី -- ខ្ញុំដឹងហើយកាលនោះនៅឆ្នាំ១៩៨៦ អ៊ីចឹងវាមានការវិវឌ្ឍហើយស្រុកទេស។ អ៊ីចឹងលោកចង់និយាយយ៉ាងម៉េចដែរថា សាខាមួយនៃរដ្ឋាភិបាលហ្នឹងទទួលបន្ទុកខាងសួរចម្លើយ <និងយាមគុក> ហើយដែលលោកនិយាយថា "នេះជាសាខាតែមួយគត់នៃរដ្ឋាភិបាលដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ខៀវ សំផន"។ លោកចង់សំដៅលើអ្វីដែលពេលដែលលោកសរសេរឃ្លានេះ ហើយមានប្រភពអីដែរ?

[១៥:១៦:០៤]

**ឆ៖** បាទ នៅក្នុងការអះអាងនេះ គឺថាមានកំហុសខ្លះ។ កាលខ្ញុំសរសេរឈ្មោះ ខៀវ សំផន នេះគឺជាការយល់ច្រឡំ ហើយសំដៅទៅលើថ្នាក់ដឹកនាំខ្មែរក្រហមទាំងអស់នោះទេ។ ខៀវ សំផន គាត់អត់មានការងារអីពាក់ព័ន្ធនឹងផ្នែកនេះទេ តែគាត់នៅចំកណ្តាលបេះដូងនៃអំណាចនៅឡើយ។ ក៏ប៉ុន្តែ<អត់មានដឹកនាំការបង្ក្រាបច្បាស់លាស់ទេ។ លើកលែងតែ> ខ្ញុំអាននៅក្នុងសៀវភៅ ហ្វីលីព ស្សូត នោះ ឃើញថាគាត់ពិភាក្សាជាមួយ នួន ជា ជាមួយប៉ុល ពត អំពីភាពចាំបាច់នៃការចាប់បុគ្គលរូបនេះ រូបនោះ។ អ៊ីចឹងវាការច្បាស់លាស់ណាស់ នៅពេលដែលខ្ញុំសរសេរដាក់ឈ្មោះ ខៀវ សំផន នេះនោះ ខ្ញុំសុំទោស នេះខ្ញុំច្រឡំហើយ។ ក៏ប៉ុន្តែការអះអាងទូទៅដែលថា ផ្នែកនេះ ជាផ្នែកតែមួយគត់នៃកម្ពុជាប្រជាធិ

បតេយ្យដែលមានប្រសិទ្ធភាពជាងគេនោះ ខ្ញុំមិនមែនតែម្នាក់ឯងទេ និយាយពាក្យនេះ គឺថា នៅក្នុងសៀវភៅ ដេវីដ ឆេនដ័ល័រ ក៏មានសរសេរអ៊ីចឹងដែរ។ គឺថា មិនមានអ្វី មានដំណើរការនោះទេ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះ។ គឺថា ផ្នែកអប់រំក៏មិនដើរ ផ្នែកវេជ្ជសាស្ត្រក៏មិនដើរ មានតែផ្នែកបង្កបង្កើនផលទេ។ ក៏ប៉ុន្តែមនុស្សនោះមិនមានអាហារហូបចុកគ្រប់គ្រាន់ ហើយទុរ្ភិក្សគ្រប់ទិសទី។

[១៥:១៧:៣៤]

**ស៖** ខ្ញុំសោកស្ដាយ ខ្ញុំសូមផ្ដោតទៅលើផ្នែកដែលពាក់ព័ន្ធនឹងលោក ខៀវ សំផន។ ខ្ញុំមិនទាន់ដកស្រង់ចប់ទេទាក់ទងនឹងប្រធានបទនេះនោះ។ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលកាលពីថ្ងៃព្រហស្បតិ៍កន្លងមកនេះ លោកបាននិយាយអំពីប្រភពនៃផ្នែកដែលខ្ញុំនឹងរំឭកនៅក្នុងសៀវភៅរបស់លោក គឺឯកសារ E3/2812 គឺពាក្យស្លោក៩២ ជាភាសាអង់គ្លេស ហើយនិង<៩០> ជាភាសាបារាំង ERN 00395067 លោកបាននិយាយថា <"ខៀវ សំផន ដែលជាប្រមុខរដ្ឋនៃរបបនោះ មានការខ្វល់ខ្វាយចិត្តក្នុងការ>បោសសម្អាតសង្គមខ្មែរ<ទាំងមូល>។ ហើយគំនិតវីវក់នេះ ជាគំនិតវីវក់របស់ថ្នាក់ដឹកនាំខ្មែរក្រហមទាំងអស់តែម្ដង ដែលវាផ្ទុះបញ្ចាំងអំពីជំងឺត្រដេវរិច"។ នៅពេលដែលសហព្រះរាជអាជ្ញាសួរលោកអំពី<ប្រភពនៃ>ពាក្យអារម្មណ៍វីវក់ គំនិតវីវក់<ដែលលោកប្រើនោះ> កាលនោះ ខ្ញុំដូចជាយល់ថា លោកបាននិយាយអំពីសក្ខីកម្មរបស់មនុស្សម្នាក់ដែលលោកស្គាល់នោះ គឺឈ្មោះ <ហ្សាក់គីលីន ហ្វីលីហ្ស> ដែលគាត់នោះ ចូលរៀនសេដ្ឋកិច្ចជាមួយលោក ខៀវ សំផន។ <ដូច្នេះនៅពេលដែលលោកនិយាយអំពីការខ្វាយខ្វល់ចិត្ត ឬគំនិតវីវក់នេះ គឺលោកនិយាយពីរយៈពេលមុនឆ្នាំ១៩៧៥ ហើយបុគ្គលម្នាក់នេះអាចជា>ប្រភព<របស់លោក។ ដូច្នេះតើខ្ញុំយល់ត្រឹមត្រូវទេ គឺថា ផ្អែកលើមូលដ្ឋាននៃ>សក្ខីកម្មរបស់<សាក្សីនេះ ដែលលោកសរសេរកថាខណ្ឌនេះ។ ជាថ្មីម្ដងទៀត គឺលោកដកស្រង់ជុំវិញ>ពាក្យ "បោសសម្អាត" នោះ ខ្ញុំដាក់នៅក្នុងអព្ភន្តរៈ ពាក្យនេះ។ តើលោកមានតែប្រភពមួយនេះទេ ឬក៏យ៉ាងណា?

**ឆ៖** កាលនោះ គឺប្រើពាក្យ "សម្អាត" ហើយដុសសម្អាតទៀត។ អ៊ីចឹងកាលណាយើង<ចង់និយាយអ្វីមួយ ហើយបញ្ជាក់វាឡើងវិញនោះ យើង>ត្រូវមានប្រភពជាច្រើន។ <ដូច្នេះ នោះមិនមែនជាប្រភពតែមួយរបស់ខ្ញុំទេ។> ខ្ញុំមានប្រភពផ្សេងទៀត គឺថា ខៀវ សំផន នៅសម័យសង្គមរាស្ត្រនិយម នោះគេហៅគាត់ថា លោកស្អាតស្អំ។ បានន័យថា គាត់មិនបណ្ដោយខ្លួនឱ្យគេធ្វើឱ្យគាត់ពុករលួយបាន។ អ៊ីចឹងគាត់ជានិមិត្តរូប ដែលគេហៅថា លោកស្អាត។ គាត់មិនជិះឡាន ជិះតែកង់ទេ កាលនោះ។ ហើយ

នៅក្នុងកិច្ចសម្ភាសន៍មួយរបស់ ហ្វីលីព ស្សូត នោះគាត់និយាយថា "អ៊ូ! ខ្ញុំមិនត្រឹមត្រូវប៉ុន្មានទេ ខ្ញុំមិនមែនជិះតែកង់ទេ ខ្ញុំជិះឡានដែរ ហើយក៏ប៉ុន្តែឡានខ្ញុំកាលនោះឡានចាស់"។ អ៊ីចឹងឈ្មោះគាត់ហ្នឹង គេហៅ "លោកស្អាតស្អំ" កាលនោះនោះ។

[១៥:២០:៥៣]

**ស៖** អ៊ីចឹង បើខ្ញុំមិនច្រឡំទេគឺថា លោកប្រើកត្តា ឬក៏ធាតុផ្សំនេះហើយមកជាសំអាង ឬជាបង្អែកដោយប្រើពាក្យថា "គំនិតរីវក់"នោះ ឬយ៉ាងម៉េច? អារម្មណ៍រីវក់នោះ?

**ឆ៖** ចម្លើយភាសាខ្មែរហ្នឹង បើបោសស្អាត ឬក៏បរិសុទ្ធៗនោះ <គឺការធ្វើឲ្យ>ស្អាត <វាជាគំនិតវក់វីមួយ។ ខ្ញុំគិតថា> នួន ជា <គឺជាមេ>មនោគមន៍វិជ្ជា <ឬមេទ្រឹស្តី>នៃរបបហ្នឹង ដែលគាត់យល់ស្របជាមួយថ្នាក់ដឹកនាំនៃរបបនោះដែរគឺថា ត្រូវធ្វើយ៉ាងណាឲ្យសង្គមហ្នឹងស្អាតស្អំកាលណោះនោះ។

**ស៖** នៅក្នុងការបោះពុម្ពផ្សាយនៅឆ្នាំ២០១៣ *"ពួគ័រ ឡើ ខ្មែររូស៍"* ខ្ញុំមិនទាន់ -- យើងអត់មានលេខ E3<សម្រាប់ការបោះពុម្ពលើកទី១នេះទេ>។ អ៊ីចឹងខ្ញុំសូម<ឲ្យភាគី និងចៅក្រមដឹងថាខ្ញុំនឹង>និយាយអំពីការបោះពុម្ពផ្សាយឆ្នាំ២០១៣ <នៅពេលដែលខ្ញុំសំដៅទៅលើឯកសារនេះ>។ លោកនិយាយពីផ្នែកមួយពាក់ព័ន្ធទៅនឹងសៀវភៅលោកនិយាយអំពីពាក្យស្តោកនេះ។ លោកនិយាយថា ទាក់ទង ខៀវ សំផន នេះគឺលោកនិយាយថា "យើងជួបគាត់ពេលគាត់បង្រៀននៅ<ថ្នាក់>សេដ្ឋកិច្ច<នៅសាកលវិទ្យាល័យភ្នំពេញ>។ គាត់បង្ហាញថាគាត់ហ្នឹង គាត់មិនស្រឡាញ់សិស្សបរទេសទេ ស្រឡាញ់តែសិស្សខ្មែរ។ អ៊ីចឹងត្រូវតែបោសសម្អាត ដុសខាត់សង្គមឲ្យស្អាត ឲ្យចៀសផុតពីឥទ្ធិពលមកពីក្រៅ"។ នៅក្នុងកំណត់ត្រាជើងទំព័រនៅទំព័រ ៨៣ -- ៨៦ នោះគឺ<លោកយោងទៅលើ>ឯកសារ E3/2812 ដដែល ហើយនៅពេលដែលលោកឆ្លើយនឹងសហព្រះរាជអាជ្ញាដដែលហ្នឹង លោកនិយាយពីរឿង--

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់។ បាទ ជាការសំខាន់ណាស់ សុំឲ្យមេធាវី ខៀវ សំផន ហ្នឹងផ្តល់លេខទំព័រផង។ យើងមានលេខកំណត់ត្រាជើងទំព័រ ប៉ុន្តែអត់មានលេខទំព័រទេ អ៊ីចឹងពិបាកតាមលោកស្រីមេធាវីណាស់។ អ៊ីចឹងខ្ញុំសុំឲ្យលោកស្រីអនុវត្តយ៉ាងដូច្នេះ ទោះបីថាយើងនិយាយពីសៀវភៅឆ្នាំ២០១៣នេះក៏ដោយ។

[១៥:២៣:៤៤]

01344528



**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** គឺនៅទំព័រ១០៥។ ខ្ញុំសុំទោសដែលខ្ញុំភ្លេច។ បើខ្ញុំមិនច្រឡំទេគឺ សម្រង់នេះគឺលោកនិយាយរឿងកំប៉ិកកំប៉ុកមួយពី ហ្សាក់គីលីន ហ្វីលីហ្ស ដែលលោកបានរៀបរាប់ពីរឿងនេះកាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះ។ ខ្ញុំចង់ដឹងថា តើលោកនិយាយអំពីព្រឹត្តិការណ៍ណាខ្លះដែលលោកនិយាយថា លោក ខៀវ សំផន នេះគាត់មិនចូលចិត្ត ឬក៏កាចចំពោះសិស្សបរទេស? <នៅក្នុងការបោះពុម្ពនេះ យើងមានការចាប់អារម្មណ៍ថា នេះជាអ្វីដែលបានកើតឡើងផ្ទួនៗ ដែលគាត់បានបង្ហាញចរិតស្អប់ខ្ពើមជាច្រើនដង ហើយនៅទីនេះ មុខអង្គជំនុំជម្រះនេះ លោកនិយាយថា គាត់បានសួរទៅស្ត្រីក្មេងម្នាក់ថា> ម៉េចក៏មិនទៅរៀននៅស្រុកបារាំងទៅ មករៀនអីស្រុកខ្មែរ? អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោក<ទាញការសន្និដ្ឋានទូទៅនេះអំពីធម្មជាតិនៃការស្អប់ខ្ពើមជារឿយៗទៅលើនិស្សិតបរទេស ឬនិស្សិតអឺរ៉ុបនោះមកពីណា>?

**លោក ហង់រី ឡូកា៖**

**ឆ៖** ចម្លើយនោះ គេសួរខ្ញុំហើយៗខ្ញុំឆ្លើយនឹងសំណួរហើយ។ អ៊ីចឹងសំណួរច្រំដែល ហើយលោក<ស្រី>និយាយថាពេលវេលាលោកស្រីនោះខ្លី ឥឡូវៗខ្ញុំៗមិនគួរនឹងនិយាយរឿងហ្នឹងដែរ។ <ទី២ ខ្ញុំមិនបាននិយាយថា មានប្រភពតែមួយនោះទេ> គឺអ្នកស្រី <ហ្សាក់គីលីន> ហ្វីលីហ្ស។ កាលនោះខ្ញុំអត់បានទៅរៀនជាមួយលោក ខៀវ សំផន ទេ ខ្ញុំគ្រូនៅសាលាលីសេដេកាត ទៅហើយ។

**ស៖** លោកបាននិយាយនៅសវនាការនេះដែរ គឺថាលោកជឿជាក់ថា ខៀវ សំផន មានទំនាក់ទំនង<ជាយូរ>មុនពេលដែលគាត់ចូលព្រៃម៉ាគីទៀត <ថាគាត់បានទទួល>ការគំរាមកំហែងពីរបបសីហនុ នោះ <ថា>មានទំនាក់ទំនងតាំងពីយូរយារណាស់មកហើយជាមួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ <តើមានភស្តុតាងអីដែលនាំឲ្យលោកជឿថា គាត់បានរងនូវការគំរាមកំហែងជាយូរពាក់ព័ន្ធនឹង>ទំនាក់ទំនង<របស់គាត់>ជាមួយបក្សកុម្មុយនីស្តកម្ពុជា។ <ហើយលោកថា -- ភស្តុតាងរបស់លោកនោះគឺ គាត់អាចធ្វើការទាក់ទងជាមួយ>អ្នកដឹកនាំ<>ដើម្បីរត់ចេញពីទីក្រុង។ អ៊ីចឹង<ក្រៅពីការសន្និដ្ឋាននេះ> ខ្ញុំសួរលោកថាតើលោកមានភស្តុតាងជាក់លាក់ណាទេ មានសក្ខីកម្មណាជាក់លាក់ទេដើម្បីជាបង្អែកនៃការអះអាងរបស់ លោកនេះ?

[១៥:២៦:៣៣]

**ឆ៖** លោក<ស្រី>បាននិយាយថាលោក<ស្រី>នឹងសួរខ្ញុំអំពី<ភាពខុសគ្នានៃ>សៀវភៅបោះពុម្ពផ្សាយលើកទី១ លើកទី២ *"ពួកវ៉ា ឡេ ខ្មែររូស"*។ ខ្ញុំបាន<ចំណាយពេលយ៉ាងច្រើន>អានសៀវភៅ

ហ្នឹងឡើងវិញកាលពីថ្ងៃអាទិត្យនេះ។ <ជាការពិតហើយ ដែលថា>វាវែង<បន្តិច> ហើយខ្ញុំ<គួរតែធ្វើឲ្យវាខ្លីជាងនោះបន្តិច ហើយខ្ញុំបានរកឃើញចំណុចបញ្ជាក់ពីរ។> ក៏ប៉ុន្តែទន្ទឹមនឹងហ្នឹងនោះ ខ្ញុំអត់បានកត់ទំព័រជាក់លាក់ទេ។ <ប្រភពរបស់>ខ្ញុំ<ក្នុងករណីនេះ>គឺ សួរ ហុង ហៅ សាឡុត បាន។ <មួយរយៈពេលខ្លី>មុនពេល<បាត់ខ្លួនមាររបស់គាត់ឈ្មោះ> សាឡុត ស <ចូលទៅក្នុងព្រៃនៅក្នុង>នៅឆ្នាំ៦៣។ <>ខៀវ សំផន <ត្រឡប់ទៅបារាំងវិញ*(ស៊ីក)* នៅ>ឆ្នាំ<១៩៥៩> អ៊ីចឹងចន្លោះពី<៥៩-៦៣> នេះ បើ ខៀវ សំផន, ប៉ុល ពត, នួន ជា, សុន សេន <ទាំងអស់នេះ>សុទ្ធតែជា<អនាគត>អ្នកមេដឹកនាំខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាហ្នឹង កាលនោះនៅភ្នំពេញទាំងអស់គ្នា។ ហើយ សាឡុត ស គេស្គាល់គាត់ថាត្រឹមជាគ្រូបង្រៀននៅវិទ្យាល័យ<ឯកជនចំនួនពីរ>នៅភ្នំពេញ<>។ តាំងពីឆ្នាំ១៩៦២មកនោះ គាត់ជាលេខានៃបក្សកុម្មុយនីស្តកម្ពុជា គ្រាន់តែជាបក្សលួចលាក់។ ហើយបក្សហ្នឹងបានជ្រើសរើសយកផ្លូវសម្ងាត់ ហើយឈ្មោះបក្សដែលគេដឹងកាលនោះ គឺបក្សប្រជាជន ហើយដែលបាត់រលាយបាត់ទៅវិញទៅក្រោយពេលដែលសង្គមរាស្ត្រនិយមបានជាប់ឆ្នោត។ ហើយខ្ញុំសរសេរនៅក្នុងសៀវភៅខ្ញុំដែរ នៅក្នុងការបោះពុម្ពផ្សាយលើកទី២ ដែលលោកស្រីសួរខ្ញុំថាតើមានភាពខុសគ្នាយ៉ាងណារវាងសៀវភៅបោះពុម្ពផ្សាយលើកទី១ និងផ្សាយលើកទី២នោះ គឺភាពខុសគ្នា គឺថាខ្ញុំបានសួរ សួរ ហុង <យ៉ាងយូរនៅចន្លោះរវាងការបោះពុម្ពលើកទី១ ហើយនិងលើកទី២នោះ>ហើយគាត់ឆ្លើយថាអង្កាល់នោះ គាត់សប្បាយណាស់ កាលសម័យនោះគាត់នៅជាមួយពូគាត់ឈ្មោះ សាឡុត ស ហ្នឹង ហើយនិងមីងគាត់ឈ្មោះ ខៀវ ប៉ុណ្ណារី ក៏ប៉ុន្តែគួរឲ្យសោកស្ដាយដែរដែលគាត់មិនអាចមានកូនដោយសារគាត់វះកាត់។ ហើយចំពោះគាត់នោះ សួរ ហុង ហ្នឹងគឺគាត់រស់នៅដោយសប្បាយរីករាយណាស់ជាមួយ សាឡុត ស នោះ ហើយ សាឡុត ស នោះជួយគាត់ក្នុងការរៀនសូត្រ ហើយ សាឡុត ស ឲ្យកង់គាត់មួយឲ្យនាំសារសម្ងាត់ កាលនោះគាត់ជំទង់ អ៊ីចឹងអត់មានអ្នកណាគេចាប់អារម្មណ៍លើគាត់ទេ អ៊ីចឹងគេ -- គាត់នាំសារហ្នឹងទៅ ខៀវ សំផន និង នួន ជា។ នេះ សួរ ហុង ហ្នឹងប្រាប់ខ្ញុំ។

**ស៖** អ៊ីចឹងនៅ៥៣ ឬក៏នៅពេលឆ្នាំ៥៣ ឬក៏យ៉ាងម៉េច?

**ឆ៖** អត់ទេ ៥៣ហ្នឹង ខៀវ សំផន ត្រឡប់ -- ប៉ុល ពត ត្រឡប់ពីបារាំង ហើយ ខៀវ សំផន នៅស្រុកបារាំង <៥៤-៥៩>។ មិនមែនទេគឺនៅឆ្នាំ ចន្លោះឆ្នាំ១៩៥៩ និង៦៣។

**ស៖** <តើ>លោកមានខ្សែអាត់ កិច្ចសម្ភាសន៍របស់លោកជាមួយ សួរ ហុង ហ្នឹង<ទេ>បើសិនតុលាការសុំហ្នឹង តើលោកឲ្យទេ?

**ឆ៖** បាទ ឲ្យ។

[១៥:២៩:៥៨]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំ<មិនដឹងថា តើខ្ញុំអាចធ្វើសំណើសុំដោយផ្ទាត់មាត់ទាក់ទងនឹង>ចំណុចនេះ<បានដែរឬទេ?> យើងខ្ញុំសុំស្តាប់ខ្សែអាត់នៃកិច្ចសម្ភាសន៍របស់លោក ហង់រី ឡូកា ជាមួយនឹង សួរ ហុង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<តើខ្ញុំអាចស្នើសុំមួយបានទេ> គឺថា យើងអាចទុក<ដល់ពេល>ចុងក្រោយ <ដូច្នេះហើយ យើងដឹងថាកន្លែងណាដែលត្រូវរកមើលវា ហើយចំពោះភាគី>ពាក់ព័ន្ធ<ទាំងអស់ មិនថា>ឯកសារស្នើសុំបន្ថែមណាមួយ<ទេ ឲ្យតែពាក់ព័ន្ធនឹងលោក ឡូកា ពួកគេចង់ស្នើសុំទាំងអស់ បើធ្វើដូច្នេះ វានឹងនៅមួយកន្លែង ឬក៏>លោកស្រីលើកបង្ហាញផ្ទាល់មាត់?<>។ លោកស្រីយល់ទេ គឺថាយើងមិនចង់ឲ្យ មិនចង់ធ្វើតាមសំណើលោកស្រីនៅកណ្តាលទីអ៊ីចេះទេ <ប៉ុន្តែគឺធ្វើនៅពេលណាមួយគ្រប់គ្នាតែម្តង>។

**កញ្ញា អង់តា ហ្គីសសេ៖**

មិនបញ្ហាទេលោកស្រី ខ្ញុំនឹងធ្វើ<>នៅពេលក្រោយ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកអ្នកជំនាញ តើលោក<នៅចាំថាលោក>បាននិយាយអំពីខ្មោចទាំងបី <ហើយនិងអង្គហេតុដែល>លោកយល់ឃើញ កាលនោះៗ លោកយល់ឃើញថា ទាំងបីនាក់ហ្នឹងស្លាប់ហើយ ឬយ៉ាងម៉េច គឺខ្ញុំសំដៅលើ ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ នេះ? ហើយលោកបាននិយាយថា នៅចន្លោះ គឺថាមុនៗពេលរដ្ឋប្រហារនៅឆ្នាំ១៩៧០ហ្នឹង លោកបាននិយាយថា មនុស្សទាំងបីនាក់ហ្នឹង គឺអាចឲ្យគេយល់ឃើញថា គាត់ទាំងបីនាក់ហ្នឹង ជាអ្នកដឹកនាំចលនាលួចលាក់ហ្នឹង? តើចន្លោះឆ្នាំ៧០ ទៅ៧៥ហ្នឹង តើអាចមានការវិវត្តន៍ដែរឬទេ ថាតើអ្នកណាអាច<>ជាមេដឹកនាំចលនាលួចលាក់ហ្នឹង <បើមាន តើប្រភពរបស់លោកគឺអ្វី>?

**លោក ហង់រី ឡូកា៖**

**ឆ៖** បាទ ខ្ញុំមិនយល់ស្របនឹងសំណួរ -- ផ្នែកទី១នៃសំណួររបស់លោក<ស្រី>ទេ។ មិនមានរដ្ឋប្រហារ ប្រឆាំងនឹងសីហនុទេ គឺថាគាត់ត្រូវបានគេផ្តួលរលំនៅ ១៨ មីនា ឆ្នាំ១៩៧០ ដោយសភាទេ ទម្លាក់ស្របច្បាប់ដោយសភាទេ ដោយសារមានការគាំទ្រភាគច្រើន សំឡេងគាំទ្រភាគច្រើន ហើយយល់

ស្រប វាស្របតាមរដ្ឋធម្មនុញ្ញឆ្នាំ៤៧ផង។

[១៥:៣២:៤៦]

អ៊ីចឹងនៅពេលនោះ ជាពិសេស សីហនុ ផ្ទាល់ហ្នឹង គាត់មិនដឹងអំពីអត្តសញ្ញាណ ហើយនិង <ធម្មជាតិនៃមេដឹកនាំរបស់>ចលនាបដិវត្តន៍នុ៎ងទេ <តាំងពី>មានអំពើហិង្សា<>នៅខែមករា ឆ្នាំ១៩៦៨ ហើយ ដោយសារមាន នួនជា ហ្នឹងជាអ្នកជំរុញនៅភូមិភាគ<បស្ចិម ហើយនៅ>ចន្លោះខែមេសា-ឧសភា <១៩៦៨ តាមបញ្ជារបស់> ប៉ុល ពត <ដែលពេលនោះ>គាត់នៅរតនគិរី។ <អ្នកទាំងអស់នេះ> កាលនោះ គ្មានអ្នកណាគេស្គាល់គាត់ទេ។ សីហនុ ក៏មិនស្គាល់គាត់ដែរ មហាជនក៏មិនស្គាល់គាត់ដែរ អ្នកកាសែតក៏មិនស្គាល់គាត់ដែរ។ អ៊ីចឹង<អ្នកនយោបាយ>បីនាក់ដែល<>គួរសរសើរ<នោះ គឺជាមេដឹកនាំចលនាល្បួចលាក់នោះ។ ពួកគេបានទទួលការបណ្ដុះបណ្ដាលពីប្រទេសបារាំង ហើយ>សុទ្ធតែជាបណ្ឌិត ហើយគាត់មានប្រជាប្រិយច្រើន ហើយគាត់សុទ្ធ កាលនោះសុទ្ធតែជារដ្ឋលេខាធិការផង។

**ស៖** តើការស្រាវជ្រាវរបស់លោក អាចឲ្យលោកកំណត់បានទេថា នៅក្នុងចំណោមក្រុមស៊ើបការណ៍បស្ចិមប្រទេសហ្នឹង តើគេមាននិយាយអំពីអត្ថិភាពរបស់ ប៉ុល ពត មុនពេលការបង្កើបឲ្យពិភពលោកដឹង នៅឆ្នាំ៧៧ដែរឬទេ? លោកមានបានព័ត៌មានហ្នឹងទេ?

**ឆ៖** ប៉ុល ពត ត្រូវបានគេស្គាល់ច្បាស់នៅក្នុងចលនាបដិវត្តន៍។ គាត់មានប្រជាប្រិយភាព។

**ស៖** សុំអភ័យទោស ខ្ញុំមានពេលខ្លីណាស់ ខ្ញុំព្យាយាមសួរសំណួរលោកច្បាស់ៗណាស់។ ខ្ញុំចង់ដឹងថា តើលោកមានព័ត៌មានទេ លោកមានបានធ្វើការលើចំណុចហ្នឹងទេ? ទោះបីជាអ្នកខាងក្រៅហ្នឹងមិនដឹង មិនស្គាល់គាត់ក៏ដោយ ចុះខ្ញុំចង់ដឹងថាតើក្រុមស៊ើបការណ៍បស្ចិមប្រទេសហ្នឹង គេដឹងអំពីវត្តមានរបស់ ប៉ុល ពត ទេ នៅមុនឆ្នាំ៧៧នោះ?

**ឆ៖** ខ្ញុំមិនដឹងទេ។ ខ្ញុំមិនបានធ្វើការឲ្យក្រុមស៊ើបការណ៍បារាំង ចក្រភពអង់គ្លេស ឬក៏អាមេរិកអីទេ។

[១៥:៣៥:១៩]

**ស៖** នៅពេលដែលខ្ញុំសួរពាក់ព័ន្ធទៅនឹងក្រុមស៊ើបការណ៍សម្ងាត់នេះ ខ្ញុំមិនចង់ថា លោកធ្វើការឲ្យ ឬមិនឲ្យទេ។ ខ្ញុំគ្រាន់តែចង់ដឹងថា ពេលដែលលោកធ្វើការស្រាវជ្រាវនុ៎ង <តើលោកបានជួបព័ត៌មានហ្នឹងទេ។ ខ្ញុំនិយាយដូច្នេះ ព្រោះ ស្ទីវ ហេដឌ័រ បានផ្ដល់សក្ខីកម្ម>នៅក្នុងសំណុំរឿង ០០២/០១ ឯកសារ <E1/225.1> <>គាត់មានវត្តមាននៅកម្ពុជាមុន<ថ្ងៃទី១៧ ខែមេសា> ឆ្នាំ៧៥ គាត់ជាអ្នកកាសែត គឺ

មុន -- សូមទោស គឺស្ទីវ ហេដឌ័រ គាត់បានឆ្លើយនៅសវនាការ<ថ្ងៃទី១៧ ខែកក្កដា ២០១៣ នៅម៉ោង ០៩:៤២:១២> ថា “ដូចដែលខ្ញុំបាននិយាយនៅក្នុងសក្ខីកម្មខ្ញុំពីមុនអ៊ីចឹង ខ្មោច -- ហាក់ដូចជាមានតែការទទួលស្គាល់ថាខ្មោចទាំងបីហ្នឹង មិនមែនជាមេដឹកនាំកំពូលទេ ហើយមនុស្សដូចជា សាឡុត ស, នួន ជា, តាម៉ុក, វន វ៉េត ឬ កុយ ធួន ជាដើម អ្នកទាំងអស់ហ្នឹង គឺជាថ្នាក់លើ ហើយខ្ញុំកាន់តែឮថា ខ្មែរក្រហមហ្នឹងមិនស្ថិតនៅក្រោមការត្រួតត្រារបស់វៀតណាមទេ ជាពិសេសនៅស្ថានទូតអាមេរិកជាដើម ខ្ញុំឮ<ក្រុមគិញសម្ងាត់នៅស្ថានទូតហ្នឹងនិយាយថា ខ្មែរក្រហមមិននៅក្រោមការគ្រប់គ្រងរបស់វៀត-ណាមទេ”។ បញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំសួរគឺ --> លោកបានឆ្លើយជូនខ្ញុំថា លោកមិនដឹងថា តើក្រុមស៊ើបការណ៍ហ្នឹងអាចដឹងអំពី<ស្ថានការណ៍មុនថ្ងៃ១៧ មេសា ១៩៧៥>ឬក៏អត់ទេ។ អ៊ីចឹង សក្ខីកម្មនេះមាននៅក្នុងសំណុំរឿង០០២/០១។ ដូច្នេះនៅក្នុងក្របខ័ណ្ឌនៃការសរសេរសៀវភៅរបស់លោក *“ពូត័រឡេ ខ្មែររូស”* តើលោកមានបានសិក្សាស្រាវជ្រាវទៅលើសវនាការនៃសំណុំរឿង០០២/០១ ហ្នឹងសាលក្រមនៃសំណុំរឿង០០២/០១ទេ? ឬក៏លោកមិនបានសិក្សាលម្អិតអីទៅលើឯកសារសវនាការក្រៅតែពីបុគ្គលមួយចំនួន ដូចជា ឌុច ជាដើមនោះ?

[១៥:៣៧:៣០]

**ឆៈ** ពិតណាស់ មុនឆ្នាំ៧៥ មុនទីក្រុងភ្នំពេញដួលរលំ ក្រុមស៊ើបការណ៍អាមេរិកដឹង<អំពីស្ថានការណ៍នោះ។> ដោយសារ តែមានរបាយការណ៍ល្បីល្បាញរបស់ ឃ្វីន ដែលក្រោយមកក្លាយជាឯកអគ្គរដ្ឋទូតអាមេរិក<> គាត់ពន្យល់យ៉ាងលម្អិតនៅក្នុងតំបន់ដែលត្រួតត្រាដោយខ្មែរក្រហមថា ការដាក់រួម ការបង្កើតជាកងចល័ត ការបង្ក្រាប គឺកើតមានរួចទៅហើយ--

**សៈ** សូមអភ័យទោសៗ លោកអ្នកជំនាញ! សូមអភ័យទោស ខ្ញុំសួរសំណួរហ្នឹងពាក់ព័ន្ធនឹងក្រុមស៊ើបការណ៍ ដែលថាដឹងអំពីអត្ថិភាពនៅសម័យនោះឬក៏អត់ ហើយលោកថា លោកមិនដឹងទេ ហើយខ្ញុំបានអានទូវចម្លើយរបស់ ស្ទីវ ហេដឌ័រ ដែលគាត់មានព័ត៌មានមួយចំនួន ក្រោយមកទៀត ខ្ញុំសួរផ្សេងទៀត។ ខ្ញុំសួរថា នៅក្នុងក្របខ័ណ្ឌនៃការងារ<របស់>លោក<អំពីខ្មែរក្រហម តើ>លោកមានបានសិក្សាជាក់លាក់ទៅលើឯកសារនៃសវនាការលើសំណុំរឿង០០២/០១ ហើយនិងសាលក្រមនៃសំណុំរឿង០០២/០១ ដែរឬក៏អត់? សូមលោកផ្តោតទៅលើសំណួរនេះ។

**ឆៈ** បាទ ពិតណាស់។ ខ្ញុំអានសាលក្រមនៃសំណុំរឿង០០២/០១ យ៉ាងលម្អិត ខ្ញុំក៏បានតាមដានសវនាការ<ផ្នែកដំបូងនៃសំណុំរឿង០០២/០២នេះ>ដែរ ជាពិសេសគឺសក្ខីកម្មរបស់ ស្ទីវ ហេដឌ័រ។ ពិត

ណាស់ យើងដឹងអំពីសារធាតុនៃមេដឹកនាំខ្មែរក្រហមនៅមុនឆ្នាំ៧៥ ក៏ប៉ុន្តែប្រជាជនជាទូទៅមិនដឹងអ្វីទេ ហើយអ្នកកាសែតភាគច្រើនហ្នឹងក៏មិនដឹងដែរ។

[១៥:៣៩:៣៧]

**ស៖** ចំណុចមួយទៀត ដែលខ្ញុំចង់ត្រឡប់មកពិភាក្សាជាមួយលោក ក្នុងពេលបោះពុម្ពសៀវភៅលើកដំបូង គឺនៅឆ្នាំ២០១៣ សៀវភៅ *"ពួត់រ ឡៅ ខ្មែរក្រហម"* នៅទំព័រ៨៥ ដល់ ៨៦ លោកបានសរសេរដូចតទៅ៖ "គេបង្ហាញពីឥស្សរជនដែលគេគោរព និងស្គាល់ ដូចជា ខៀវ សំផន ជាដើម ហ៊ូ នឹម, ហ៊ូ យន់ ឬក៏ ជួន ម៉ុម ជាអ្នករៀន និងទទួលសញ្ញាប័ត្រនៅប៉ារីស<គឺជាអ្នកដែលលេចធ្លោ> ក៏ប៉ុន្តែនៅក្នុងភាពលួចលាក់នោះ គឺមាន នួន ជា, សាឡុត ស និង សុន សេន ដែលជាអ្នកមានអំណាច ហើយនិងជាអ្នកសម្រេចលើបញ្ហាសំខាន់ៗ នោះ"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះនៅក្នុងសៀវភៅបោះពុម្ពលើកទី១ នៅឆ្នាំ២០១៣ នោះ លោកបាននិយាយថា គេបង្ហាញ ខៀវ សំផន ឱ្យគេស្គាល់គ្រប់គ្នា ក៏ប៉ុន្តែនៅក្នុងឆាក នៅក្នុងក្រោយឆាកនោះ គឺមិនមែនជា ខៀវ សំផន ទេ។ ហើយនៅក្នុងសំណៅបោះពុម្ពលើកទី២ គឺឯកសារ E3/10640 លោកបានសរសេរកថាខណ្ឌដែលហ្នឹង ក៏ប៉ុន្តែក្នុងលក្ខណៈផ្សេង គឺនៅទំព័រ៩២ ជាភាសាបារាំង "គេបង្ហាញឥស្សរជន ដែលគេស្គាល់ច្បាស់ ដូចជា ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ឬក៏ ជួន ម៉ុម ជាដើម ជាអ្នករៀន និងទទួលបានសញ្ញាប័ត្រនៅទីក្រុងប៉ារីស ក៏ប៉ុន្តែនៅក្រោយឆាកឯណោះ គឺមាន សាឡុត ស, នួន ជា, ខៀវ សំផន និង សុន សេន ដែលមានអំណាច និងសម្រេចលើបញ្ហាសំខាន់ៗ។" ដូច្នេះ នៅក្នុងសំណៅបោះពុម្ពលើកទី១ និងសំណៅបោះពុម្ពលើកទី២ហ្នឹង នៅមនុស្សនៅខាងក្រោយឆាកហ្នឹង លោកបន្ថែមឈ្មោះលោក ខៀវ សំផន នៅសំណៅបោះពុម្ពលោកទី២ នោះ។ តើលោកអាចពន្យល់បានទេ អំពីភាពខុសគ្នារវាង អ្វីដែលលោកសរសេរនៅក្នុងសំណៅបោះពុម្ពលើកទី១ និងលើកទី២នេះ? ហើយលោកចង់មានន័យថាម៉េច នៅពេលដែលលោកបន្ថែមឈ្មោះលោក ខៀវ សំផន ទៅក្នុងចំណោមមេដឹកនាំនៅក្រោយឆាកនោះ?

**ឆ៖** ក្នុងឆ្នាំ២០១៣ និង២០១៦ នេះ ខ្ញុំបានសម្ភាស សួរ ហុង យ៉ាងយូរ ហើយក៏ ភី ភួន ផងដែរ។ ពួកគាត់បានផ្តល់ព័ត៌មានច្រើនមកឱ្យខ្ញុំពាក់ព័ន្ធនឹងសង្គ្រាមស៊ីវិល និងអ្វីដែលបានកើតឡើងនៅស្ទឹងជីនិត ជាពិសេសថាតើថ្នាក់ដឹកនាំចលនាខ្មែរក្រហមចូលមកភ្នំពេញយ៉ាងម៉េច ដោយចូលមកតាមទន្លេសាប ហើយចេះតែខិតរំកិលចូលមកដល់ភ្នំពេញ។ ពេលនោះ ខ្ញុំដឹងថា ពេលវាយយកភ្នំពេញបាន ខៀវ សំផន ទទួលបន្ទុកខាងភស្តុភារ ពីព្រោះថាជាវិស័យទទួលខុសត្រូវរបស់គាត់។ គាត់ជាអ្នកទទួលខុស

ត្រូវក្នុងការចែកចាយសម្ភារៈផ្សេងៗ គឺគាត់នេះហើយជាអ្នកគ្រប់គ្រងទៅលើការបែងចែកគ្រឿងអាវុធគ្រឿងរំសេវនោះ។ ដូច្នេះគាត់មានតួនាទីសំខាន់ ហើយគេប្រាប់ខ្ញុំផងដែរថា គាត់មានតួនាទីសំខាន់ជាងខ្មោចទាំងពីរទៀត គឺ ហ៊ូ នឹម និង ហ៊ូ យន់។ ហ៊ូ យន់ មិនដែលចូលរួមក្នុងសកម្មភាពធ្វើសង្គ្រាម និងប្រព្រឹត្តអំពើហិង្សាទេ។

[១៥:៤៣:២៣]

**ស៖** នៅពេលដែលលោកនិយាយថា <>គាត់<ទទួលខុសត្រូវ>ចែកគ្រឿងរំសេវហ្នឹង គឺលោកសំដៅទៅលើសក្ខីកម្មដែលលោក ភី ភួន និង សួរ ហុង បានឆ្លើយនៅក្នុងសវនាការនេះ លោកសំដៅទៅលើអ្វីដែលគាត់និយាយនៅមុនពេលវាយចូលទីក្រុងភ្នំពេញ ឬក៏យ៉ាងម៉េច? ព្រោះថាខ្ញុំចង់ត្រឡប់មកអ្វីដែលលោកនិយាយវិញនេះ <នៅក្នុងសវនាការមួយនោះ> សាឡុត បាន ហ្នឹង<មិន>បាននិយាយអំពីការបែងចែក<>គ្រឿងរំសេវទេ <ប៉ុន្តែគឺនិយាយពីការផ្តល់ជំនួយដោយលោក ខៀវ សំផន ព្រោះគាត់អាចអាន សរសេរ និង>ធ្វើបញ្ជីសម្ភារៈផ្សេងៗទៀត <ដែលវាខុសពីអ្វីដែលលោកកំពុងនិយាយនេះ>។ លោក<>និយាយថា <>សួរ ហុង ឬក៏ សាឡុត បាន <ហ្នឹងបាន>ប្រាប់<ព័ត៌មាន>លោក<បន្ថែមលើអ្វីដែលលោកបានសម្ភាសគាត់> ហើយលោកថតសំឡេង<> ឬក៏លោកទទួលបានព័ត៌មានហ្នឹងពីសវនាការលើសំណុំរឿង០០២/០១ទេ?

**ឆ៖** បើចំពោះអ្នកទាំងពីរនេះ ជាពិសេស ភី ភួន គាត់ពូកែចាំណាស់ <គាត់មិនបានចូលរៀនទេ តែ>គាត់ៗនឹកឃើញទាំងអស់ តាំងពីឈ្មោះអ្នកនេះ អ្នកនោះ ទីកន្លែងអីចឹង គឺថាគាត់ពូកែចាំមែនទែន ហើយចាំច្បាស់ទៀត។ ហើយខ្ញុំបានពិនិត្យមើលកំណត់ហេតុសក្ខីកម្មរបស់គាត់<យ៉ាងយកចិត្តទុកដាក់។ ដូចខ្ញុំបានប្រាប់លោកស្រីហើយថា> ខ្ញុំបានសម្ភាសគាត់រាប់ខែ គឺខ្ញុំសម្ភាសគាត់ហ្នឹងយូរជាងពេលដែលគាត់មកផ្តល់សក្ខីកម្មឱ្យតុលាការទៅទៀត។ អីចឹងខ្ញុំបានព័ត៌មានច្រើនណាស់ពីគាត់។ ហើយចំពោះ សាឡុត បាន វិញ គាត់រៀនជាលក្ខណៈប្រពៃណី ហើយគាត់រៀនជាមួយនឹងអ៊ំៗទាំងបី ដែលជាមេដឹកនាំកំពូល<នៅភ្នំពេញ>។ <ការអប់រំរបស់គាត់មានលក្ខណៈបុរាណខ្លាំង។>

**ស៖** បាទ សុំឱ្យលោកឆ្លើយឱ្យបានច្បាស់ លោកអ្នកជំនាញ។

**ឆ៖** សាឡុត បាន អ្វីដែលខ្ញុំចង់និយាយហ្នឹងគឺថា គាត់បាននិយាយច្រើនណាស់ វាលើសពីអ្វីដែលគាត់បានប្រាប់តុលាការនៅទីនេះទៅទៀត។ <គាត់បន្តនិយាយថា គាត់នឹកមិនឃើញទេ។>តុលាការប្រហែលជាមិនសូវជឿគាត់ប៉ុន្មានទេ។ ក៏ប៉ុន្តែ<វាជាការពិត>គាត់ចងចាំ<តិច>ជាង ភី ភួន ទៅទៀត។

**សៈ** នៅពេលដែលលោកនិយាយថា ខៀវ សំផន មានអំណាចជាង ហ៊ូ នឹម, ហ៊ូ យន់ ក្នុងអំឡុងរយៈកាលនោះ ហើយដែលគាត់ទទួលបន្ទុកខាងការចែកចាយគ្រឿងរំសេវនោះ តើអ្នកណាជាអ្នកប្រាប់លោក សាឡុត បាន ឬក៏ ភី ភួន?

**ឆៈ** ខ្ញុំគិតថា ភី ភួន។ គាត់នៅជាមួយនឹងអ្នកដែលដឹកនាំសង្គ្រាមស៊ីវិល។

[១៥:៤៦:២៤]

**សៈ** ព័ត៌មានហ្នឹង គឺមាននៅក្នុងកំណត់ត្រារបស់លោករបស់លោក ក៏ដូចជាខ្សែអាត់ដែលលោកបានសម្ភាស ភី ភួន មែនទេ?

**ឆៈ** បាទ គឺមាននៅក្នុងខ្សែអាត់ស្ដាប់ចម្លើយ ភី ភួន។

**សៈ** ការចូលរួមនៅក្នុងការបែងចែក ចែកចាយគ្រឿងរំសេវហ្នឹង នៅក្នុងសំណៅបោះពុម្ពផ្សាយលើកទី២ ហ្នឹង លោកថា នួន ជា, ខៀវ សំផន, សុន សេន មានអំណាចទាំងអស់ ហើយនិងជាអ្នកសម្រេចលើរឿងរ៉ាវសំខាន់ៗ។ <តើហ្នឹងឬជាមូលដ្ឋានដែលលោកបញ្ជាក់នោះ>?

**ឆៈ** ពិតណាស់។ ពេលនោះ គឺជាសម័យសង្គ្រាម។ អ៊ីចឹងការទទួលបានជ័យជម្នះ គឺដោយប្រើកាំភ្លើងទៅបាញ់គ្នា។ ដូច្នេះ<នៅសប្ដាហ៍ចុងក្រោយនៃខែមករា និងខែមេសា> ខៀវ សំផន គាត់នៅទីនោះ។ យើងមានរូបថតផងដែរ។ ហើយប៉ុល ពត គឺជាមេទាហាន ដូចជា អ៊ីុស្តែរអ៊ីចឹង។ នៅពេលអ៊ីុស្តែរគាត់ដឹកនាំសង្គ្រាមជាមួយសូវៀតហ្នឹង គឺជាគាត់ជាអ្នកបញ្ជាទៅឧត្ដមសេនីយ៍ផ្សេងៗ។

**សៈ** លោកនិយាយអំពី ប៉ុល ពត និងវត្តមានរបស់លោក ខៀវ សំផន នៅតាម ប៉ុល ពត។ ចំណុចណាដែលធ្វើឲ្យលោកប៉ានិយាយថា លោក ខៀវ សំផន ហ្នឹង<ចូលរួមគ្រប់ការសម្រេចចិត្តហើយ>មិន<ត្រឹមតែ>ជាមនុស្សដែលគេបង្ហាញ ឲ្យតែមានប្រជាប្រិយទេ គាត់ថែមទាំងមានអំណាចទៀតផង? គឺវាខុសពីអ្វីដែលលោកសរសេរនៅក្នុងសៀវភៅរបស់លោកក្នុងការបោះពុម្ពផ្សាយទី១នេះដែលលោកថា ខៀវ សំផន គ្រាន់តែជាមនុស្សដែលគេបង្ហាញដើម្បីទទួលបានប្រជាប្រិយភាពទេ ក៏ប៉ុន្ដែនៅក្នុងសំណៅទី២ នេះគឺលោកនិយាយថា គាត់មានអំណាច។ អ៊ីចឹង <តើលោកអាចប្រាប់យើងបានទេថាលោកបានប្រភពព័ត៌មានហ្នឹងមកពីណា ហើយលោកនិយាយអំពី>សិទ្ធិក្នុងការសម្រេចលើបញ្ហាសំខាន់ៗហ្នឹង សម្រេចលើរឿងអីខ្លះ?

[១៥:៤៨:៤០]

**ឆៈ** គឺវាដូចគ្នា ខ្ញុំបាននិយាយហើយ។ លោក ខៀវ សំផន ក៏បានប្រាប់<និងបញ្ជាក់តាមរយៈ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មេធាវីរបស់គាត់>ថា គាត់ជាអ្នកផ្តល់ជំនួយ។ គាត់ដូចជា<ស្រមោល គាត់ដូចជាទេពអប្សរភ្លឺត្រចង់> ។ គាត់នៅអមជាមួយនឹងថ្នាក់ដឹកនាំ <ហើយគាត់មិនដែលចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តទេ>។ <ទាំងអស់នេះជាសេចក្តីសន្និដ្ឋានរបស់>លោកស្រី <អនុញ្ញាតឲ្យខ្ញុំបញ្ចេញទស្សនៈផ្សេងទៀតផង>។

**ស៖** ខ្ញុំយកសៀវភៅរបស់លោកមកអានតើ គឺខ្ញុំចង់ដឹង ថាលោកផ្អែកទៅលើមូលដ្ឋានអីខ្លះ ដែលលោកបាននិយាយថា គាត់សម្រេចហ្នឹង? ឥឡូវនេះ ខ្ញុំនិយាយអំពីឯកសារបោះពុម្ពលើកទី២ E3/10640 ដដែលនោះ។ លោកបានសរសេរបន្ថែម បើធៀបទៅនឹងការបោះពុម្ពផ្សាយឆ្នាំ២០១៣ ERN ជាភាសាបារាំង <01303587>។ ឯកសារហ្នឹងមានតែជាភាសាបារាំងទេ។ លោកនិយាយអំពីលោក ខៀវ សំផន។ លោកថា “ក្នុងឋានៈជាលេខាគណៈអចិន្ត្រៃយ៍បក្សដែលគេហៅថា ម-៨៧០ គាត់ស្ថិតនៅចំចំណុចកណ្តាលនៃអំណាច។” តើលោកផ្អែកទៅលើមូលដ្ឋានអ្វី ដែលលោកបាននិយាយថា គាត់ជាលេខាគណៈអចិន្ត្រៃយ៍បក្សនោះ?

**ឆ៖** ក្រោយពី ឌឿន និង ប៉ង ត្រូវបានចាប់ខ្លួន ដេវីដ ឆេនដ័ល័រ ក៏ដូចជា ហ្វីលីព ស្សូត បានសរសេរថាគឺ ខៀវ សំផន នេះហើយជាអ្នកដើរតួជំនួសអ្នកទាំងពីរដែលគេចាប់ខ្លួនហ្នឹង។ ខ្ញុំបាននិយាយច្រើនដងមកហើយនៅតុលាការនេះថា យើងមិនមែនស្ថិតនៅក្នុងរបបធម្មតាទេ។ វាជារបបពិសេស របបលើកលែង ជារបបកុម្មុយនីស្តនៅក្នុងពេលសង្គ្រាម មិនមាននរណាមានកិច្ចសន្យាការងារអីទេ អត់មានប្រាក់ខែទេ អត់មានសរសេរជាឯកសារក្រដាសថា អ្នកនេះមានភារកិច្ច មានតួនាទីអ្វីខ្លះទេ។ អ៊ីចឹង យើងគ្មានភស្តុតាងអីបញ្ជាក់ឲ្យច្បាស់ថា តើគាត់នៅក្នុងឋានានុក្រមហ្នឹង គាត់មានឋានៈអ្វីខ្លះ ហើយមុខងារគាត់ធ្វើអ្វីខ្លះទេ។ យើងដឹងរឿងច្រើនថា លោក ខៀវ សំផន ជាអ្នកទទួលខុសត្រូវខាងសេដ្ឋកិច្ច... ។ល។ ក៏ប៉ុន្តែគ្មានឯកសារច្បាស់លាស់ទេនៅសម័យនោះ។ ក៏ប៉ុន្តែខ្ញុំផ្អែកទៅលើកត្តាដែលថា គាត់ហ្នឹងមានវត្តមាននៅមន្ទីរក-៣<ពេញមួយរបបនោះ>។

[១៥:៥១:៣៥]

**ស៖** អ៊ីចឹង នេះហើយជា<មូលដ្ឋានដែល>លោកនិយាយថា គាត់ហ្នឹងជាលេខាមន្ទីរ៨៧០។ លោកបានឆ្លើយថា លោកបានអានយ៉ាងយកចិត្តទុកដាក់នៅសាលក្រម <ដែល>លោកបានតាមដាន<កិច្ចដំណើរការនីតិវិធីនោះ>។ ដូច្នេះយើង<យល់ស្រប>ថា នៅពេលដែល<លោក>ធ្វើការស្រាវជ្រាវហ្នឹង វាតែងតែមានការវិវត្តន៍ ហើយនៅពេលណាមួយនោះ លោកមានព័ត៌មានប៉ុននេះ ប៉ុន្តែទៅមុខលោកមានព័ត៌មានផ្សេងទៀតដែលមានការវិវត្តន៍។ ដូច្នេះ ក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវរបស់លោក

លោកមិនអាចពិនិត្យឯកសារទាំងអស់ ដូចជាតួលេខ ឬកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ទេ។ ដូច្នេះ លោកឯកភាពជាមួយខ្ញុំទេថា សេចក្តីសន្និដ្ឋានរបស់លោក នៅក្នុងសៀវភៅនោះគឺលោកផ្អែកទៅលើព័ត៌មាន ដែលលោកមិនបានសិក្សាដោយយកចិត្តទុកដាក់ទេ មែនទេ?

**ឆ៖** រាល់ឯកសារដែលលោកស្រីលើកឡើងហ្នឹង ខ្ញុំមិនអាច ខ្ញុំមិនបានពិគ្រោះមើលទេពីមុនមកនោះ។ នេះជាចំណុចទី១។ ហើយទី២ ខ្ញុំអត់អាច ខ្ញុំមិនបានធ្វើការ<ស្រាវជ្រាវ>មុនគេទេ ខ្ញុំគ្រាន់តែយកឯកសាររបស់គេយកមកសិក្សាតែប៉ុណ្ណោះ។ នៅពេលដែលខ្ញុំនិយាយថា <ខៀវ សំផន> ជាលេខាការិយាល័យនយោបាយនោះ គឺខ្ញុំផ្អែកទៅលើព័ត៌មានដែលខ្ញុំទទួលបានពីអ្នកនិពន្ធផ្សេងទៀតដែរទេ។ ខ្ញុំអត់មានព័ត៌មានអីថ្មីសន្លាងសម្រាប់ផ្តល់ជូនលោកស្រីទេ។

[១៥:៥៣:០៨]

**ស៖** ខ្ញុំសួរលោកបែបនេះហ្នឹង ពីព្រោះថាខ្ញុំ<ចង់ទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះ និងភាគីឲ្យយកចិត្តទុកដាក់ទៅលើអង្គហេតុថា> នៅក្នុងកថាខណ្ឌ<៣៨៩ នៃសាលក្រមបង្ហាញថា> អង្គជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានផ្សេង។ ដូច្នេះហើយខ្ញុំសូមទាញចំណាប់អារម្មណ៍លោកទៅលើចំណុចហ្នឹង។ នៅក្នុងសៀវភៅបោះពុម្ពផ្សាយលើកទី២ នៅERN ដែលខ្ញុំបានប្រាប់នោះ <0103580>*(ស៊ីក)* លោកបាននិយាយអំពីអំណាចហ្នឹងដូចជាពស់ក្បាលពីរ។ ក៏ប៉ុន្តែនៅក្នុងការបោះពុម្ពលើកទី១ហ្នឹង លោកនិយាយតែពី នួន ជា, ប៉ុល ពត ទេដែលថាពស់ក្បាលពីរនោះ។ ក៏ប៉ុន្តែនៅក្នុងសំណៅបោះពុម្ពលើកទី២ លោកបានបញ្ចូល ខៀវ សំផន ដែរ។ អ៊ីចឹងនៅក្នុងសៀវភៅបោះពុម្ពលោកទី១នោះ លោកបាននិយាយអំពីលោក ខៀវ សំផន។ហើយក្នុងពេលបោះពុម្ពលើកទី២ ហ្នឹង លោកដំឡើងឋានៈលោក ខៀវ សំផន មកចូលក្នុងពស់ក្បាលពីរដែរ បើអ៊ីចឹង បើបូកលោក ខៀវ សំផន មួយទៀត ត្រូវតែដាក់ពស់ក្បាលបីបានត្រូវ មិនត្រូវដាក់ពស់ក្បាលពីរទេ។ ដូច្នេះខ្ញុំចង់សួរលោកថា តើសាលក្រមសំណុំរឿង០០២/០១ ដែលលោក -- ធ្វើឲ្យលោកផ្លាស់ប្តូរព័ត៌មាននៅក្នុងសៀវភៅរបស់លោកក្នុងការបោះពុម្ពទី២នេះ លោកលើក ខៀវ សំផន ពីមនុស្សដែលមានឋានៈរាយរងនោះ មកឡើងមកជាពស់ក្បាលពីរ ហើយយើង -- ហើយខ្ញុំមិនដឹងថា ក្បាលពីរហ្នឹង ក្បាលមានអីខ្លះទេ។ អ៊ីចឹងសូមលោកឆ្លើយជូនអង្គជំនុំជម្រះពាក់ព័ន្ធនឹងចំណុចនេះ។

[១៥:៥៥:០០]

**ឆ៖** ខ្ញុំដូចមិនបានសរសេរថាពស់ក្បាលបីទេ ព្រោះខ្ញុំដាក់តែត្រឹមក្បាលពីរទេ។ <ប៉ុន្តែនៅពេល

យើងពិនិត្យមើល>សក្ខីកម្មជាពិសេសរបស់ ភី ភួន <>សក្ខីកម្មរបស់ អុង ថុងហឿង ក៏ដូចជាសក្ខីកម្មរបស់លោក ឡុង វិសាឡូ <ដែលធ្វើរបាយការណ៍>ដោយ ហ្វីលីព ស្សូត គឺថានៅក្នុងវគ្គអប់រំរៀនសូត្រធំៗ ឬក៏នៅក្នុងមីទ្ទិងរបស់បក្ស វាគ្មិនសំខាន់បំផុតនោះគឺ ប៉ុល ពត ដូចដែលយើងដឹងគ្រប់គ្នាហើយ គាត់និយាយឲ្យអ្នកស្ដាប់ហ្នឹងជក់ចិត្តមែនទែន គាត់ពូកែនិយាយណាស់ គាត់និយាយយូរៗ ហើយមានការសម្រាកដូចនៅតុលាការនេះអ៊ីចឹង។ មនុស្សគឺជក់ចិត្តនឹងសម្ដីរបស់គាត់ណាស់ គាត់តែងតែនិយាយផង ញញឹមផង ហើយគាត់ពូកែនិយាយរឿងកំប្លែង និយាយលេងសើច អ៊ីចឹងទៅធ្វើឲ្យអ្នកស្ដាប់ហ្នឹងជក់ចិត្តមែនទែន គាត់និយាយអ៊ីចឹងដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នកស្ដាប់។ បន្ទាប់មកគឺ នួន ជា ជាអ្នកនិយាយ ជាវាគ្មិនដូចដែលលោកស្រីកត់សម្គាល់ឃើញនៅតុលាការនេះហើយគាត់និយាយម៉ាត់ៗណាស់ ហើយគាត់មិនសូវប្រើប្រាស់ពាក្យសើចចំអកអីទេ--

[១៥:៥៦:៣៨]

**ស៖** ខ្ញុំសូមកាត់ផ្ដាច់លោកហើយ ព្រោះថាសល់តែ៤នាទីទៀតទេ អ៊ីចឹងខ្ញុំមានពេលខ្លីណាស់ សូមឲ្យលោកឆ្លើយខ្លីៗបានហើយ លោកបានរៀបរាប់មនុស្សដែលនៅក្នុងឋានៈខ្ពស់ ហើយលោកបានបញ្ចូលលោក ខៀវ សំផន នៅក្នុងពស់ក្បាលពីរ ហើយលោកបានលើកឡើងអម្បាញ់មិញ អំពី អុង ថុងហឿង គាត់ក៏មកបានផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការនេះដែរនៅក្នុងសក្ខីកម្មគាត់គឺថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/107.1 គឺចន្លោះម៉ោង១៤:៣៣:២២វិនាទី ហើយនិងម៉ោង១៤:៣៤:១២ វិនាទី គាត់និយាយអំពីបទអន្តរាគមន៍របស់លោក ខៀវ សំផន នៅចំពោះមុខក្រុមបញ្ញាជន។ ពេលនោះលោក អុង ថុងហឿង គាត់បាននិយាយដូចតទៅខ្ញុំសូមដកស្រង់៖ “ឈ្មោះខ្ញុំមិនមាននៅក្នុងបញ្ជីដែលអ្នកដែលត្រូវបានគេជ្រើសរើសឲ្យស្ដាប់សុន្ទរកថារបស់គាត់ទេ ប៉ុន្តែមិត្តខ្ញុំ គឺត្រូវបានគេជ្រើសរើស។ គាត់បានប្រាប់ខ្ញុំថា ខៀវ សំផន មកជាមួយអ្នកផ្សេងទៀត ហើយគេមិនទទួលគាត់ដូចអ្នកធំអីទេ ដែលហើយគេអត់មានឲ្យកៅអីអីគាត់អង្គុយទេ។ អ្នកមកពីបរទេសគេសួរ គេឆ្ងល់ថាគាត់ប្រមុខរដ្ឋដែរ ម៉េចក៏គេធ្វើអ៊ីចឹង ម៉េចក៏អត់មានអ្នកណាស្វាគមន៍អីលោក ខៀវ សំផន អ៊ីចឹង? ពេលនោះ អ្នកចូលរួមនៅ នៅក្នុងប្រជុំហ្នឹងគេចេះតែឆ្ងល់អ៊ីចឹងដែរ អ៊ីចឹងបានជាខ្ញុំលើកឡើងហ្នឹង។” ហើយគាត់ក៏បន្តទៅទៀត អុង ថុងហឿង គាត់សរសេរសៀវភៅមួយដែរនៅក្នុងសៀវភៅរបស់គាត់ៗបានពន្យល់ផងដែរថាស្របពេលហ្នឹង គឺនៅមុនម៉ោង១៤:៣៧:១០វិនាទីបន្តិច គាត់ថា “ច្បាស់ណាស់ ខៀវ សំផន គាត់មានឥទ្ធិពលនយោបាយដែរ ក៏ប៉ុន្តែគាត់គ្រាន់តែជាអាយ៉ងរបស់ ប៉ុល ពត ទេ។” សូមបញ្ចប់ការដកស្រង់

ចេញពីសៀវភៅរបស់ អុង ថុងហឿង។ ហើយពេលនោះគេសួរទៅគាត់ទៀតថា "តើពាក្យសម្ដីហ្នឹង គឺអ្នកដែលចូលរួមនៅក្នុងការស្ដាប់សុន្ទរកថាគាត់ពេលបើកវិទ្យាស្ថានបច្ចេកទេសហ្នឹង គេប្រាប់លោកហ្នឹងមែនទេ? គាត់ឆ្លើយនៅពេលនោះថា៖ បាទ គឺគេប្រាប់ខ្ញុំអ៊ីចឹង។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះនេះជាសក្ខីកម្មរបស់ អុង ថុងហឿង ជូនអង្គជំនុំជម្រះ<នេះមិនបានពន្យល់នូវអ្វីដែលលោកអះអាងនោះទេ ដែលថាគាត់ជាវាគ្មិនដ៏អស្ចារ្យបន្ទាប់ពី ប៉ុល ពត>។ ដូច្នេះតើលោកមានប្រភពណាផ្សេងទៀតទេ? ហើយឬក៏លោកមានខ្សែអាត់ ឬក៏មានកំណត់ត្រាការសម្ភាសរបស់លោកជាមួយនឹង អុង ថុងហឿង ពាក់ព័ន្ធនឹងចំណុចហ្នឹងទេ?

[១៥:៥៩:៥៧]

**ឆ៖** បាទ ពិតណាស់ ខ្ញុំស្គាល់ អុង ថុងហឿង នេះច្បាស់មែនទែន។ គឺ ស្ទីវ ហេដឌ័រ ជាអ្នកប្រគល់សក្ខីកម្ម<របស់គាត់>ដែលវាយជាដាក់ទីឡូ<មិនទាន់រួចរាល់មក>ឲ្យខ្ញុំ<នៅទីក្រុងឡុងដ៍។> ខ្ញុំជក់ចិត្តនឹងសក្ខីកម្មរបស់គាត់នេះមែនទែន។ គាត់បានបង្ហើបអំពីព័ត៌មានសំខាន់អំពីកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំបានសុំឲ្យគាត់សរសេរឲ្យចប់<ព្រោះគាត់សរសេរសៀវភៅនោះដើម្បីកូនចៅរបស់គាត់> ហើយពេលនុ៎ងក៏គាត់សរសេរចប់ទៅ។ ហើយខ្ញុំជាអ្នកស្វែងរក អ្នកបោះពុម្ពផ្សាយសៀវភៅរបស់គាត់ហ្នឹង។ ខ្ញុំមានឃ្លាមួយផ្សេងទៀត គឺនៅក្នុងសៀវភៅ "ខ្ញុំជឿលើខ្មែរក្រហម – *ហ្សែ គ្រុយ អូ ខ្មែររូស៍*" <គាត់និយាយថា> គាត់ខ្លួនឯងហ្នឹង <នៅពេលដំបូងនៃការរស់នៅប្រទេសកម្ពុជា> គាត់បានចូលរួមនៅក្នុងវគ្គរៀនសូត្រ ដែលបង្រៀនដោយ ខៀវ សំផន ហើយពេលនុ៎ង គឺ ខៀវ សំផន បានពន្យល់ថាអ្នកមកពីបរទេស ដែលគេហៅថាជាបញ្ញាជនហ្នឹង គឺសុទ្ធតែជាអ្នកការទូត ជានិស្សិតដែលទៅធ្វើការកម្មសិក្សាការី ឬក៏អ្នកដែលទៅរៀននៅអាមេរិកជាដើមហ្នឹង គឺអ្នកដែលចូលមកស្រុកវិញហ្នឹង ត្រូវតែលះបង់ទ្រព្យសម្បត្តិឯកជនចោល ហើយត្រូវតែលះបង់គ្រួសារចោល ជាពិសេស គឺលះបង់ខ្លួនឯងហ្នឹងផ្ទាល់តែម្ដង។ ខ្ញុំមិនបានយកសៀវភៅរបស់ ហ្វីលីព ស្បូត មកទេ ក៏ប៉ុន្តែនៅក្នុងសៀវភៅរបស់គាត់ គាត់និយាយអំពីលោក ឡុង វិសាឡូ គាត់ក៏មានតំណែងនៅក្នុងរបបបច្ចុប្បន្នដែរ។ គាត់នៅរស់ទេសព្វថ្ងៃនេះ។ លោក ឡុង វិសាឡូ បាននិយាយច្រើនអំពីសុន្ទរកថារបស់លោក ខៀវ សំផន ដែលគេថា ត្រូវតែលះបង់នូវបុគ្គលភាពរបស់ខ្លួនចោល ត្រូវប្រគល់បុគ្គលភាពទៅឲ្យអង្គការ គឺអង្គការជាអ្នកគ្រប់គ្រងមនុស្ស។ <នេះគឺជាសាររបស់លោក ខៀវ សំផន នៅក្នុងរបបនោះ។> ខ្ញុំសូមបញ្ជាក់ផងដែរថា នៅខែសីហា ឆ្នាំ៧៦ នៅក្នុងសន្និសីទលើក ទី៥នៃប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងកូឡុំបូ គឺលោក ខៀវ

សំផន ជាអ្នកតំណាងប្រទេសកម្ពុជាប្រជាធិតតេយ្យ ហើយគាត់ការពារយ៉ាងខ្លាំងក្លានូវសមិទ្ធផលដ៏ល្អរបស់ប្រទេសកម្ពុជា ហើយនិងលទ្ធិកុម្មុយនីស្ត។ ពេលនោះ គាត់ជាអ្នកនាំពាក្យរបស់កម្ពុជាប្រជាធិប-តេយ្យ មិនមែន អៀង សារី ទេ គាត់ជាប្រមុខរដ្ឋ។ គឺជា -- គាត់និយាយតាំងនាមឲ្យកម្ពុជាប្រជាធិប-តេយ្យ គឺនៅខែសីហា ឆ្នាំ៧៦ គឺគាត់តំណាងកម្ពុជាប្រជាធិបតេយ្យទាំងមូលតែម្តង នៅសន្និសីទនៅទីក្រុងកូឡុំបូ។

[១៦:០២:៤៤]

**ស៖** លោកប្រធាន ខ្ញុំគិតថា យើងជិតដល់ចប់ហើយ ប៉ុន្តែខ្ញុំសួរបញ្ជាក់ចំណុចចុងក្រោយ។ លោកបាននិយាយអំពីសុន្ទរកថាជាសាធារណៈរបស់លោក ខៀវ សំផន ដែលយើងមាននៅក្នុងសំណុំរឿង ហើយដែលមានការជជែកច្រើននៅក្នុងសវនាការនេះ គឺមិនមានអីថ្មីទេ សុន្ទរកថាទាំងអស់ហ្នឹង។ ដូច្នេះខ្ញុំចង់ដឹងថា ផ្អែកទៅលើតួនាទីរបស់គាត់នៅក្រៅប្រទេស តួនាទីគាត់ជាអ្នកតំណាងកម្ពុជាប្រជាធិបតេយ្យនៅក្រៅប្រទេសទាំងអស់ហ្នឹង ទើបធ្វើឲ្យលោកសន្និដ្ឋានបែបហ្នឹងនោះ? គឺមិនមែនព័ត៌មានដែលលោកបានសិក្សាស្រាវជ្រាវនៅក្នុងក្របខ័ណ្ឌនៃឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យទេ ដែលធ្វើឲ្យលោកសន្និដ្ឋានបែបហ្នឹងនោះ គឺគ្រាន់តែលោកយកភាពជាតំណាងរបស់លោក ខៀវ សំផន នៅក្រៅប្រទេសមក បានលោកធ្វើការសន្និដ្ឋានបែបហ្នឹងមែនទេ?

**ឆ៖** បាទ គឺខ្ញុំយកការងារស្រាវជ្រាវរបស់អ្នកផ្សេងដែរ ដូចជារបស់លោក វ៉ាអ៊ូល ម៉ាកចេនណា គាត់សរសេរសៀវភៅមួយអំពីលោក ខៀវ សំផន។ ហើយនៅក្នុងសៀវភៅនោះ គាត់បានពន្យល់ច្រើនណាស់ពីតួនាទីរបស់លោក ខៀវ សំផន។ គាត់មានឯកសារគាំទ្រច្បាស់លាស់ណាស់។ គាត់ថា គឺលោក ខៀវ សំផន ពិតជាចូលរួមពាក់ព័ន្ធនៅក្នុងការដឹកនាំកម្ពុជាប្រជាធិបតេយ្យមែន។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ដោយសារតែឥឡូវនេះ ដល់ម៉ោងហើយ ខ្ញុំសូមផ្អាកត្រឹមហ្នឹងសិន ហើយសូមបន្តនៅថ្ងៃស្អែកទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការ លើកទីបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០២ ខែសីហា ឆ្នាំ

២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មអ្នកជំនាញ ហង់រី ឡូកា បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-976។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។ អង្គជំនុំជម្រះអរគុណលោកអ្នកជំនាញ ហង់រី ឡូកា សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាអ្នកជំនាញនៅថ្ងៃនេះមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោកអ្នកជំនាញវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ មកចូលរួមសវនាការនៅថ្ងៃស្អែកវិញ។ ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកវិញ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*